ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ព្រះមហាក្សត្រ ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី

◆ រូបថត១00សន្លឹក ដើម្បីការចងចាំ និងការអប់រំ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១៦ ខែធ្នូ ឆ្នាំ២០១៧

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២១៦ ខែធ្នូ ឆ្នាំ២០១៧

## មាតិកា

◆ ព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ជូនចំពោះ លោក ឆាំង យុ ............ ១

◆ រូបថត១០០សន្លឹកដើម្បីការចងចាំ និងការអប់រំ ............ ៣

**ផ្នែកឯកសារ**

◆ អ៊ុយ ប៉េងឡេង នាទីជំនួយការវរសេនាធំ៣៣ កងពល៧០៣ ............ ៨

◆ បន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យខ្លាំងក្លា និងជ្រាលជ្រៅថែមទៀត ដើម្បីការពារបក្សបដិវត្តន៍ ការពារប្រទេសជាតិ ការពារប្រជាជនយើង ............ ១៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ពិព័រណ៍រូបថតនៅសារមន្ទីរអន្លង់វែង (អតីតផ្ទះតាម៉ុក) ............ ១៨

◆ រូបថតរម្លឹកពីអតីតកាល ............ ២០

◆ វេទិកាថ្នាក់រៀនស្តីពី សារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ ............ ២៤

◆ ពិធីសំពះដឹមក្នុងព្រះវិហារ នៅឃុំវិហារសួគ៌ ............ ២៨

**ផ្នែកច្បាប់**

◆ អំពើប្រល័យពូជសាសន៍ៈ ការធ្វើទុកបុកម្នេញលើជនជាតិ ............ ៣៧

**វេទិកាពិភាក្សាសាធារណៈ**

◆ រូបសំណាករម្លឹកអំពីការចងចាំ ............ ៤៦

◆ ដាំង និងអត្ថន័យរបស់ពាក្យស្លោកនៃការចងចាំពីអំពើប្រល័យ ............ ៥១

◆ កម្ពុជា ដំណើរដ៏វែងឆ្ងាយឆ្ពោះទៅរកភាពសះស្បើយ ............ ៥២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ព្រលឹងមាសម្តាយ ............ ៥៥



សិស្សវិទ្យាល័យ ជា ស៊ីម ចំរើនរដ្ឋ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១៣ម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះ** ៖ ហូលីយ៉ូ ជែលជ្រេស, លី សុខឃាង, ឆេង វើង, ឃាង សេងហឿន, វ៉ូនិត អារី, ជេង ពង្សរ៉ាស៊ី, លី លីលី, ណាតាលី ប៉ាំងួ, កុរី តាំ, អ៊ឹង វណ្ណា **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ ទាវ សារៈមុនិន្ទ និង ហូ ថុនា **អ្នកបកប្រែ** ៖ យូ វលក្ខណ៍ **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ** ៖ សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ** ៖ សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, khmerrougehistory.org www.truthcambodia.com**

# ព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ធិបឌិន្ទ ជូនចំពោះ លោក ឆាំង យុ



រូបនៅខាងឆ្វេងដៃ៖ បណ្ឌិត ហ្វូលីយ៉ូ ដែលជ្រេស អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ជាមួយនឹងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា អមព្រះរាជដំណើរ សម្តេចម៉ែ នរោត្តម មុនីនាថ សីហនុ ទតសួនច្បារនៅក្នុងព្រះបរមរាជវាំង ។

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិសុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី ទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន ចំពោះ លោក ឆាំង យុ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាថ្នាក់ធិបឌិន្ទ ។

គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយព្រះមហាក្សត្រ ព្រះបាទនរោត្តមទី១ នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៨៦៤ ដើម្បីផ្តល់រង្វាន់ដល់ប្រជាជនកម្ពុជា និងជនបរទេសដែលមានស្នាដៃល្អ ធ្វើការបម្រើដល់ព្រះរាជាណាចក្រកម្ពុជា ។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៨៩៦ គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ក្រោមការគ្រប់គ្រងដោយមន្ត្រីជាន់ខ្ពស់អាណានិគមបារាំង និងបានផ្ទេរទៅរដ្ឋាភិបាលបារាំងតាមរយៈអធិការបតីជាន់ខ្ពស់ជាកិត្តិយសនាទីក្រុងប៉ារីស ។

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៤៨ គ្រឿងឥស្សរិយយសនៃរដ្ឋបាលកម្ពុជា គឺបានផ្ទេរត្រឡប់មកប្រទេសកម្ពុជាវិញ តាមរយៈការស្នើសុំរបស់ព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ ។ គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា គឺមានវ័យចំណាស់ជាងគេ និងមានតម្លៃខ្ពស់ជាងគ្រឿងឥស្សរិយយសណាទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាបែងចែកចេញជា៥ថ្នាក់ រួមមានៈ ថ្នាក់មហាសិរីវឌ្ឍន៍ ថ្នាក់មហាសេនា ថ្នាក់ធិបឌិន្ទ ថ្នាក់សេនា និងថ្នាក់អស្សឫទ្ធិ ។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ ព្រះមហាក្សត្រព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជាថ្នាក់ធិបឌិន្ទ ជូនចំពោះ លោក ឆាំង យុ នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាបនិកនៃវិទ្យាស្ថានស្លឹករឹត ចំពោះភាពថ្លៃថ្នូរនៃស្នាដៃបម្រើជាតិមាតុភូមិ ។

**បណ្ឌិត ហ្វូលីយ៉ូ ដែលជ្រេស អតីតលេខាផ្ទាល់ និងជាអ្នកសរសេរប្រវត្តិរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។**





# រូបថត១០០សន្លឹកដើម្បីការចងចាំ និងការអប់រំ

ពិព័រណ៌រូបថត១០០សន្លឹក បានចាប់ផ្តើមដាក់តាំងបង្ហាញជូនសាធារណជនជាលើកដំបូងបង្អស់ នៅក្នុងសារមន្ទីរស្រុកអន្លង់វែង (អតីតផ្ទះតាម៉ុក) ។ រូបថតនីមួយៗបាន និងកំពុងពាំនាំនូវរឿងរ៉ាវដ៏ច្រើនអនេកស្តីពីអតីតកាលដ៏អន្ធការរបស់ប្រទេសកម្ពុជា ។ ពិព័រណ៌រូបថតនេះត្រូវបានធ្វើឡើងដើម្បីបម្រើឲ្យការចងចាំ និងការអប់រំ ដែលអាចជួយលើកកម្ពស់ការយល់ដឹង និងបង្កើតបានជាការឆ្លុះបញ្ចាំងដ៏ស៊ីជម្រៅចំពោះសម័យកាលនោះ ។ ខណៈដែលការដាក់តាំងពិព័រណ៌បាន និងកំពុងក្លាយជារំឭកឡើងវិញអំពីអតីតកាល ពិព័រណ៌នេះក៏ជាភ័ស្តុតាងដាក់ស្តែងចំពោះព្រឹត្តិការណ៍ប្រកបដោយសោកនាដកម្ម ដែលប្រជាជនកម្ពុជាបានឆ្លងកាត់ ។

បន្ទាប់ការធ្វើសមាហរណកម្មរបស់តំបន់អន្លង់វែងនៅក្នុងឆ្នាំ១៩៩៨ ផ្ទះតាម៉ុក ត្រូវបានប្រែក្លាយទៅជាសារមន្ទីរពីរឆ្នាំក្រោយមក ។ ចំណុចចាប់ផ្តើមនៃសារមន្ទីរនេះ គឺមានត្រឹមតែជាសម្បកផ្ទះរបស់ តាម៉ុក តែប៉ុណ្ណោះ ប៉ុន្តែគ្មានព័ត៌មានផ្សេងៗនៅឡើយទេ ។ តែទោះជាយ៉ាងណាក៏ដោយ សារមន្ទីរនេះបានក្លាយជាទីតាំងដែលមានមនុស្សចូលទស្សនាច្រើនបំផុត បើប្រៀបធៀបទៅនឹងទីតាំងទេសចរណ៍ប្រវត្តិសាស្ត្រចំនួន១៨កន្លែងផ្សេងទៀតនៅក្នុងស្រុកអន្លង់វែង ។ សារមន្ទីរនេះ ទទួលបានភ្ញៀវចូលទស្សនារាប់ម៉ឺននាក់ក្នុងមួយឆ្នាំៗ ដែលភាគច្រើនគឺជាប្រជាជនកម្ពុជា ។ ដោយសារតែមានភាពចាំបាច់ដើម្បីធ្វើឲ្យសារមន្ទីរនេះមានភាពរស់រវើកឡើងវិញ តាមរយៈការស្វែងយល់ឲ្យកាន់តែគ្រប់ជ្រុងជ្រោយថែមទៀតអំពីប្រវត្តិសាស្ត្រនៃសង្គ្រាម និងសន្តិភាពនៅក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលជាគំនិតផ្តួចផ្តើមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងទេសចរណ៍ កំពុងបោះមួយជំហានទៅមុខទៀត ក្នុងការដាក់តាំងពិព័រណ៌រូបថត១០០សន្លឹកនេះ ។ **លី សុខឃាង**



ប្រជាជននៅស្រុកអន្លង់វែងកំពុងមើលពិព័រណ៌រូបថត១០០សន្លឹក ដែលដាក់តាំងបង្ហាញជូនសាធារណជនទស្សនាលើកដំបូងបង្អស់នៅក្នុងសារមន្ទីរស្រុកអន្លង់វែង (អតីតផ្ទះតាម៉ុក) ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៧ ។

# ពិធីសម្ពោធ ពិព័រណ៍រូបថត១០០សន្លឹក នេ









# ជាសារមន្ទីរស្រុកអន្លង់វែង (អតីតផ្ទះតាម៉ុក)



















# អ៊ុយ ប៉េងឡេង នាទីជំនួយការវរសេនាធំ៣៣ កងពល៧០៣

*ដកស្រង់ចេញពីឯកសារលេខ J០០០៤៨*

អ៊ុយ ប៉េងឡេង ភេទប្រុស មានស្រុកកំណើតនៅភូមិថ្មី ឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្តាល ។ គាត់មានឪពុកឈ្មោះ អ៊ុយ សយ និងម្តាយឈ្មោះ អៀង ទៀង ។ ប៉េងឡេង បានចូលបដិវត្តន៍នៅខែឧសភា ឆ្នាំ១៩៧០ ។ សេចក្តីកំណត់ហេតុអំពីប្រវត្តិរបស់ អ៊ុយ ប៉េងឡេង មានចំនួនសរុប៨២ទំព័រ ព្រមទាំងមានស្នាមផ្តិតមេដៃសាមីខ្លួន ដែលបានរៀបរាប់អំពីសកម្មភាពប្រឆាំងបក្សកុម្មុយនីស្តកម្ពុជាចាប់តាំងពីឆ្នាំ១៩៧០ រហូតដល់ថ្ងៃអង្គការចាប់ខ្លួនបាននៅថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៧ ។ សេចក្តីសង្ខេបដែលដកស្រង់ចេញពីចម្លើយសារភាពរបស់ អ៊ុយ ប៉េងឡេង មានដូចខាងក្រោម ៖

អ៊ុយ ប៉េងឡេង បានចូលបដិវត្តន៍ដំបូងមាននាទីជាកងឈ្លបនៅឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្តាល ។ កន្លះខែក្រោយមក ប៉េងឡេង បានផ្លាស់ទៅធ្វើជាឈ្លបស្រុក១៨ ក្រោមការដឹកនាំរបស់ជនជាតិយួនម្នាក់ឈ្មោះ វ៉ាង អាង ។ ប៉េងឡេង បានធ្វើការនៅទីនោះ ប្រហែលពីរខែ វ៉ាង អាង បានណែនាំគាត់ឲ្យរៀនអក្សរយួន និងនិយាយភាសាយួន ម្យ៉ាងទៀតត្រូវដឹងគុណបំណាច់ចំពោះ



កងយោធាខ្មែរក្រហម នៅសមរភូមិមុខ

ជនជាតិយួនដែលបានជួយរំដោះទឹកដីកម្ពុជា ។ ក្រោយមក ប៉េង ឡេង អាចប្រើប្រាស់ភាសាយួនបានបន្តិចបន្តួច ។ បន្ទាប់មក ចាន់ ស៊ីថន ជាគណៈស្រុកកោះធំ បានហៅ ប៉េងឡេង ឲ្យទៅរៀនបច្ចេកទេសនៅវត្តព្រែកឫស្សី ក្នុងឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ។ ប៉េងឡេង បានបញ្ជាក់ថា កាលរៀននៅសាលាបច្ចេកទេស មានសិស្សចូលរួមប្រហែល៥០នាក់ ។ អ្នកដែលបង្ហាត់បង្រៀនកាលនោះ គឺជាជនជាតិយួនមានឈ្មោះ សៅ ភាង ។ ចំពោះវគ្គសិក្សាមានរយៈពេលជិតមួយខែ ។ ក្រោយពេលបញ្ចប់វគ្គសិក្សា ប៉េងឡេង បានឃើញ ចាន់ ស៊ីថន ចងទង់សញ្ញាញញួរ និងកណ្តៀវ ដែលមានពណ៌ក្រហមទៀតផង ។ ក្រោយមក ចាន់ ស៊ីថន បានប្រកាសបិទវគ្គសិក្សា រួចហើយគាត់បានឲ្យ ប៉េងឡេង និងសិស្សទាំងអស់នោះ ធ្វើសច្ចាប្រណិធានចំពោះទង់ពលករវៀតណាម ។ ចាន់ ស៊ីថន ជាអ្នកសូត្រមុន រីឯអ្នកទាំង អស់នោះជាអ្នកសូត្រតាមក្រោយ ដោយប្រើពាក្យថា ប្តេជ្ញាស្មោះត្រង់ចំពោះទង់បក្សពលករវៀតណាម គោរពស្រឡាញ់ និងសាមគ្គីភាពជាមួយជនជាតិវៀតណាមដែលបានរំដោះនូវទឹកដីកម្ពុជា ។ រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៧០ ជនជាតិវៀតណាម-ខ្មែរ បានបែកបាក់សាមគ្គីភាពគ្នា ។ ក្រោយពីការបែកបាក់ វ៉ាង អាង ជាអ្នកដឹកនាំក្នុងអង្គភាព ឈ្លបបានណែនាំថា តំបន់២៥ គឺជាតំបន់ សេ.អ៊ី.អា ឬជាតំបន់របស់បក្សពួក លន់ នល់ ។ បក្ស លន់ នល់ បានបង្កើតតំបន់នេះឡើង គឺដើម្បីជិះជាន់ប្រជាជនដណ្តើមដីរំដោះ ។ ពេលនោះ វ៉ាង អាង បានណែនាំបន្ថែមថា យើងត្រូវរៀបចំផែនការកម្ទេចតំបន់២៥ចោល ។ មួយរយៈក្រោយមក បងរបស់ ប៉េងឡេង បានមកយក ប៉េងឡេង ឲ្យទៅនៅផ្ទះវិញ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧១ ប៉េងឡេង ក៏បានចូលបដិវត្តន៍ម្តងទៀត នៅក្នុងកងទ័ពតំបន់២៥ កងអនុសេនាធំគ២ ។

ក្រោយពេលចូលបដិវត្តន៍ ប៉េងឡេង បានទទួលភារកិច្ចខាងសេដ្ឋកិច្ច ។ កន្លះខែក្រោយមក អង្គភាពអនុសេនាធំគ២នេះក៏បានរំសាយ រួចរៀបចំជាបីអនុសេនាធំ ពេលនោះ ប៉េងឡេង បានមករស់នៅក្នុងសេដ្ឋកិច្ចរួមតំបន់ ក្រោមការដឹកនាំរបស់ សុខ ។ ក្រោយមក សុខ បានហៅ ប៉េងឡេង និងអ្នកផ្សេង១៨នាក់ទៀត ដើម្បីធ្វើការណែនាំមានដូចជា លើកអំពីបញ្ហារបស់បក្ស សឺន សាន ថាក្រុមនេះគឺ សុទ្ធតែល្មោភបុណ្យស័ក្តិ ឬចង់ដណ្តើមរដ្ឋអំណាចនៅតំបន់ ម្យ៉ាងទៀតត្រូវធ្វើបដិវត្តន៍ ដើម្បីបុណ្យស័ក្តិ ប្រាក់ខែ ឬសិទ្ធិសេរីភាពចំពោះខ្លួន និងត្រូវជួយលើកឥទ្ធិពលចំពោះ សុខ ផ្ទាល់ ដើម្បីឲ្យអ្នកដទៃឃើញគាត់ជាមនុស្សល្អត្រឹមត្រូវនៅក្នុងតំបន់ ។ បន្ទាប់មក ប៉េងឡេង បានធ្វើសកម្មភាពជាក់ស្តែងនៅក្នុងឃុំកំពង់ស្វាយលើ ដោយធ្វើការឃោសនាអំពីឥទ្ធិពលរបស់ សុខ និងបំបាត់នូវឥទ្ធិពលក្រុមដែលមកពីហាណូយ ជាពិសេស សូ ពុំ និង សឺន សាន ។ លុះត្រាតែប្រជាជនមានភាពកក់ក្តៅទៅលើ សុខ រួចហើយ ប៉េងឡេង នឹងផ្អាកធ្វើសកម្មភាពនេះ ។ នៅខែឧសភា ឆ្នាំ១៩៧១ សុង លី បានយក ប៉េងឡេង មកធ្វើសេដ្ឋកិច្ចនៅកងអនុសេនាធំគ១៩៥ (សុង លី គឺជាសមាជិកម្នាក់ ក្នុងចំណោមអ្នកទាំង១៨នាក់ខាងលើ ដែលត្រូវបាន សុខ ហៅមកណែនាំ) ។ ក្រោយមក សុង លី បានណែនាំ ប៉េងឡេង ជាបន្តបន្ទាប់ រីឯ ប៉េងឡេង ផ្ទាល់ បានធ្វើសកម្មភាពបបួលប្រជាជននៅភូមិត្រែង ស្រុកស្អាង រាំច្រៀងសប្បាយធ្វើឲ្យប្រជាជនទាំងនោះមិនគិតពីបញ្ហាអ្វីទាល់តែសោះ ។ ឯសកម្ម ភាពម្យ៉ាងទៀតរបស់ ប៉េងឡេង គឺបានលួចកិបកេងប្រាក់ខែរបស់យុទ្ធជន ឬកម្មាភិបាលប្រចាំខែ ដោយយកទៅទិញនំចំណីសម្រាប់បុគ្គលផ្ទាល់ខ្លួន ។ មកដល់ខែមិថុនា ក្នុងឆ្នាំ១៩៧១ដដែល សុង លី បានឃើញសកម្មភាពរបស់ ប៉េងឡេង មមាញឹក និងធ្វើបានល្អជាបន្តបន្ទាប់ ពេលនោះ គាត់បានចាត់តាំង ប៉េងឡេង ធ្វើជាសមាជិក សេ.អ៊ី.អា ។ បន្ទាប់មក សុង លី បានធ្វើការណែនាំ ប៉េងឡេង អំពីភារកិច្ចរបស់ សេ.អ៊ី.អា មានដូចជា ត្រូវបង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍តាមរូបភាពផ្សេងៗ ដោយស្របច្បាប់របស់បដិវត្តន៍ ម្យ៉ាងទៀតកសាងកម្លាំង សេ.អ៊ី.អា នៅក្នុងជួរបដិវត្តន៍ ដើម្បីពង្រីកកម្លាំងនេះ សម្រាប់ត្រៀមវាយបដិវត្តន៍នាពេលខាងមុខ និងត្រូវបំផុសយុទ្ធជន ឬកម្មាភិបាលឲ្យចេះសប្បាយ ភ្លើតភ្លើនពីមុខមាត់ បុណ្យស័ក្តិ និងបំផ្លិចបំផ្លាញផលប្រយោជន៍បដិវត្តន៍ ។ ក្រោយពីទទួលការណែនាំរួចហើយ ប៉េងឡេង បានធ្វើសកម្មភាពទាំងនោះ ជាបន្តបន្ទាប់ រហូតដល់ខែសីហា ក្នុងឆ្នាំដដែល អង្គភាពអនុសេនាធំគ១៩៥ បានផ្លាស់មកនៅប្រចាំការ ដើម្បីទប់ទល់ជាមួយខ្មាំងដែលមានទីតាំងនៅម្តុំស្រុកស្អាង ។ ពេលនោះ ប៉េងឡេង បានធ្វើសកម្មភាពធ្វើឲ្យបាត់លុយកាក់របស់អង្គការ ដោយភូតកុហកថាលុយបានធ្លាក់ចូលទៅក្នុងទឹក ។ អំឡុងពេលនោះ ប៉េងឡេង បាន

កសាងកម្លាំង សេ.អ៊ី.អា ពីរនាក់បន្ថែមទៀត ១) ឈ្មោះ សឹម ម៉ាន (នៅក្នុងស-២១) ២) ឈ្មោះ រដ្ឋ (អង្គការកម្ទេចចោលនៅមូលដ្ឋាន២៥) ។ បន្ទាប់មក ប៉ែនឡេង បានណែនាំអ្នកទាំងពីរឲ្យធ្វើសកម្មភាព គឺត្រូវចូលទៅបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ និងត្រូវកសាងកម្លាំងថ្មីបន្ថែមទៀត ។

នៅឆ្នាំ១៩៧២ អង្គការបានដកអង្គភាពអនុសេនាធំ១៩៥ ចេញពីតំបន់ ហើយបានបញ្ចូលទៅក្នុងអង្គភាពវរសេនាតូច១១២ ប្រចាំភូមិភាគពិសេសនៅខាងត្បូងភ្នំពេញ ។ នៅខែមករា ក្នុងឆ្នាំដដែល ប៉ែនឡេង បានធ្វើសកម្មភាពធ្វើឲ្យខូចអង្ករអស់៩បាវ ដោយធ្វើឲ្យលេចទឹកខូច បណ្ដាលឲ្យខ្វះស្បៀងដល់កងទ័ព ។ សកម្មភាពនេះ ប៉ែនឡេង ធ្វើចាប់តាំងពីខែមករាដល់ខែមេសា រហូតដល់ ប៉ែនឡេង ធ្លាក់ខ្លួនឈឺ ។ បន្ទាប់មក ប៉ែនឡេង បានសម្រាកនៅមន្ទីរពេទ្យកំពង់គ ។ ខណៈនោះ ប៉ែនឡេង បានធ្វើសកម្មភាពជេរប្រមាថពេទ្យសព្វគ្រប់បែបយ៉ាង និងបានរិះគន់អំពីបញ្ហាហូបចុក មិនព្រមគោរពវិន័យពេទ្យ ធ្វើឲ្យមានទំនាស់នៅក្នុងមន្ទីរពេទ្យ ដើម្បីឲ្យមានភាពស្មុគស្មាញ ឲ្យអង្គការពិបាកដោះស្រាយ ។ មួយរយៈក្រោយមក ប៉ែនឡេង បានវិលត្រឡប់មកអង្គភាពវិញ រួចអង្គការបានស្នើសុំកងកម្លាំងនៅក្នុងអង្គភាពអនុសេនាធំ១៩៥ ប្រាំពីរនាក់ដើម្បីឲ្យទៅរៀនស៊ើបការណ៍ ក្នុងនោះ មាន ប៉ែនឡេង ម្នាក់ដែរ ។ មុននឹងទៅរៀនសូត្រ សុង លី បានណែនាំអ្នកទាំងប្រាំពីរនាក់នោះថា ត្រូវបង្កទំនាស់ជាមួយអ្នកដែលទៅចូលរៀនជាមួយគ្នា បំផុសឥទ្ធិពលរបស់ សុខ ដើម្បីឲ្យសិក្ខាកាមទាំងអស់នៅក្នុងសាលាបានដឹង និងបំផុសអំពីបញ្ហាមុខមាត់ បុណ្យស័ក្តិនៅក្នុងសាលា ។ ក្រោយមក ប៉ែនឡេង និងបក្ខពួកបានទៅរៀនបច្ចេកទេសស៊ើបការណ៍នេះ ដែលមានទីតាំងស្ថិតនៅខាងត្បូងវត្តខ្ពប ឃុំខ្ពប ស្រុកស្អាង ។ ក្រោយពីបានទៅដល់កន្លែងសិក្សារួចមក ប៉ែនឡេង និងបក្ខពួកបានធ្វើសកម្មភាពដូចដែល សុង លី បានរៀបរាប់ខាងលើ ប៉ុន្តែសិក្ខាកាមទាំងអស់មិនសូវខ្វល់ពីការបំផុសរបស់ ប៉ែនឡេង និងបក្ខពួកឡើយ ដោយអ្នកទាំងនោះយល់ថា ឈ្មោះ សុខ នេះ ពួកគេធ្លាប់ស្គាល់ធាតុពិតរួចមកហើយ ។ ទន្ទឹមនេះ ប៉ែនឡេង និងសមាជិកក្រុមបានធ្វើសកម្មភាពបង្កទំនាស់ ធ្វើឲ្យបែកបាក់សាមគ្គីភាព ដោយលើកហេតុផលថា អង្គភាពនេះមិនល្អ អង្គភាពនោះមិនល្អ រួចលើកអង្គភាពរបស់ខ្លួនដាក់អង្គភាពដទៃ ធ្វើឲ្យគណៈសាលាពិបាកដោះស្រាយ ។ ក្រោយពេល ប៉ែនឡេង បញ្ចប់វគ្គសិក្សារយៈពេលជិតពីរខែ រហូតដល់ចុងខែមិថុនា ក្នុងឆ្នាំ១៩៧២ អង្គការបានបិទសាលារៀនបច្ចេកទេសស៊ើបការណ៍តំបន់២៥នេះ រួចអង្គការបានបើកសមរភូមិខាងកើតទន្លេបាសាក់ សមរភូមិប៉ាវ៉ែន ព្រែកតាដ័រ ព្រែកតានុក និងសមរភូមិព្រែកតាតិន ។ ចំពោះសកម្មភាពរបស់ ប៉ែនឡេង វិញ នៅក្នុងសមរភូមិអង្គការបានចាត់តាំងគាត់ឲ្យយកមីនទៅដាំចរបងនៅសមរភូមិព្រែកតាដ័រ ។ ប៉ុន្តែ កាលនោះ ប៉ែនឡេង បានធ្វើឲ្យមីនមិនផ្ទុះ រីឯរបងក៏មិនដាច់ បណ្ដាលឲ្យកងទ័ពសម្រុកចូលមិនដល់ទីតាំង ហើយផែនការរបស់អង្គការក៏ត្រូវបានបរាជ័យ ។ បន្ទាប់ពីធ្វើសកម្មភាពនេះរួចមក ប៉ែនឡេង បានជួប សុង លី ហើយបានពិភាក្សាគ្នាអំពីបញ្ហាផ្ទៃក្នុង និងរៀបចំផែនការខ្លះៗ ដើម្បីប្រឆាំងនឹងបដិវត្តន៍បន្តទៅទៀត ។ មួយរយៈក្រោយមក ប៉ែនឡេង បានឮដំណឹងថា សុង លី បានស្លាប់ ចំពោះខ្សែរយៈរវាង ប៉ែនឡេង និង សុង លី ក៏ត្រូវបានដាច់ចាប់តាំងពីពេលនោះមក ។ រីឯអង្គភាពស៊ើបការណ៍វិញ ក៏ត្រូវបានបញ្ជប់ឲ្យធ្វើសកម្មភាពនៅខាងកើតទន្លេបាសាក់ រួចផ្លាស់មកនៅក្នុងតំបន់១៥វិញ ។ ចំពោះការមករស់នៅក្នុងតំបន់១៥ ប៉ែនឡេង បានធ្វើការខាងក្រោយឈូងលាបនៅត្រើយខាងលិចទន្លេបាសាក់ ។ ពេលនោះ ប៉ែនឡេង បានបន្តសកម្មភាពធ្វើឲ្យការជម្លៀសប្រជាជនរបស់អង្គការមានការយឺតយ៉ាវ ដោយភូតកុហកថា នៅមុំឈូងលាបមានខ្មាំង និងទាហានជាច្រើនដែលធ្វើឲ្យការជម្លៀសប្រជាជនមានការលំបាក ។ រហូតដល់ខែមីនាឆ្នាំ១៩៧៣ អង្គការមានផែនការ វាយនៅថ្នល់ជាតិ ២១ ពេលនោះ ប៉ែនឡេង បានជួបជាមួយឈ្មោះ ពិសេស ផល ។ បន្ទាប់មក ផល បានណែនាំ ប៉ែនឡេង អំពីភារកិច្ចដែលត្រូវធ្វើនៅពេលដែលអង្គការ ចាប់ផ្ដើមវាយនៅផ្លូវជាតិ២១ គឺត្រូវឲ្យគាត់ទៅទាក់ទងជាមួយ នី (អនុលេខាវរសេនាតូច៧០៦ ក្នុងកងពល៧០៣) និង ភា (វរសេនាតូច៧០៥ ក្នុងកងពល ៧០៣) ។ ចំពោះការទាក់ទងរវាងអ្នកទាំងពីរនេះ គឺដើម្បីឲ្យការវាយសម្រុករបស់អង្គការ ប្រព្រឹត្តទៅមិនបានសម្រេច ។ បន្ទាប់មក ប៉ែនឡេង, នី និង ភា បានធ្វើសកម្មភាពនេះរហូតមកដល់ខែមិថុនា ឆ្នាំ១៩៧៣ ដដែល ។ អំឡុងពេលនោះ អង្គការបានបញ្ឈប់ការវាយនៅផ្លូវជាតិ

២១ រួចបានផ្លាស់មកវាយនៅផ្លូវជាតិលេខ២ នៅសមរភូមិស្អាង រលួយ ។ ពេលនោះ ប៉ែនឡេង បានធ្វើសកម្មភាពដោយត្រួតពិនិត្យមើលទីតាំងដែលត្រូវវាយ រួចប្រាប់អង្គការថាមើលមិនច្បាស់ នាំឲ្យកងទ័ពវាយសម្រុកចូលទៅ បណ្តាលឲ្យកងទ័ពស្លាប់ជាច្រើន ។ រហូតដល់ខែកក្កដា ឆ្នាំ១៩៧៤ ប៉ែនឡេង បានជួបជាមួយឈ្មោះ សឿន ។ ពេលនោះ សឿន បាននិយាយណែនាំ ប៉ែនឡេង ថា ត្រូវបង្កប់ខ្លួនបន្តទៀត ដើម្បីស៊ីរូងផ្ទៃក្នុងរបស់បដិវត្តន៍ ឲ្យកាន់តែស៊ីជម្រៅ និងត្រូវខិតខំកសាងខ្លួនឲ្យបដិវត្តន៍ជឿទុកចិត្ត ។ ពាក់កណ្តាលខែកក្កដា អង្គការបានចាត់តាំង ប៉ែនឡេង និង សឿន ឲ្យទៅរៀនខាងផ្នែកនយោបាយ ដែលមានរយៈពេលមួយខែ ។ ក្រោយពេលបញ្ចប់វគ្គសិក្សាខ្លីមួយនេះ អង្គការបានប្រគល់ ភារកិច្ចឲ្យ ប៉ែនឡេង យកកាំជ្រួច១០៧ទៅបាញ់ទម្លាក់នៅម្តុំពោធិ៍ចិនតុង នៅវត្តពុទ្ធនិពាន ក្នុងតំបន់១៥ ។ ក្រោយពេល ប៉ែនឡេង ធ្វើសកម្មភាពនេះរួចមក អង្គការបានហៅគាត់មកអង្គភាពនៅទន្លេបាសាក់វិញ ។ នៅពេលដែលគាត់ត្រឡប់មកដល់អង្គភាព អង្គការបានចាត់តាំងគាត់ឲ្យទៅពិនិត្យមើលនៅសមរភូមិម្តុំទួលសុភី ដើម្បីរៀបផែនការវាយកម្ទេចទីតាំងនោះ ។ រីឯ ប៉ែនឡេង វិញនៅតែបន្តកុហកអង្គការដូចកាលមុនៗ ដោយពិនិត្យមើលមិនច្បាស់ ធ្វើឲ្យវាយសម្រុកមិនបានសម្រេច ។

រហូតដល់ឆ្នាំ១៩៧៥ ប៉ែនឡេង បានកសាងកម្លាំងថ្មីបានពីរនាក់ទៀត ឈ្មោះ វ៉ាង (ស-២១) និង ភន (ស-២១) រួចគាត់បានបញ្ចូលអ្នកទាំងពីរជាសមាជិក សេ.អ៊ី.អា ។ បន្ទាប់មក ប៉ែនឡេង បានណែនាំអ្នកទាំងពីរអំពីគោលជំហររបស់ សេ.អ៊ី.អា គឺត្រូវស៊ីរូងផ្ទៃក្នុងបដិវត្តន៍ កសាងកម្លាំងនៅក្នុងជួរបដិវត្តន៍ វាយបដិវត្តន៍នៅពេលបក្សពួកគេមិនដឹងខ្លួន និងធ្វើសកម្មភាពបំផ្លិចបំផ្លាញបដិវត្តន៍ ។ ដល់ខែមីនា ឆ្នាំដដែល អង្គការបានចាត់តាំង ប៉ែនឡេង ឲ្យទៅជួយធ្វើការនៅក្នុងអនុសេនាធំមួយទៀត ក្នុងអង្គភាពវរសេនាតូចដដែល ។ ប៉ែនឡេង បានធ្វើការនៅក្នុងអង្គភាពនោះបានមួយរយៈអង្គការក៏ចាត់តាំងគាត់ មកនៅអង្គភាពចាស់វិញ ។ ដោយពេលនោះ អង្គការបានប្រគល់ភារកិច្ចថ្មីមួយទៀតនៅផ្លូវជាតិលេខ២ ។ បន្ទាប់មក ប៉ែនឡេង បានចុះត្រួតពិនិត្យមើលសកម្មភាពខ្មាំងអស់រយៈពេលកន្លះខែ រួចហើយរាយការណ៍ទៅអង្គការ ។ ពេលនោះ អង្គការចាប់ផ្តើមវាយរំដោះទីក្រុងភ្នំពេញ រហូតដល់ខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ។ អំឡុងពេលនោះ ប៉ែនឡេង បានត្រូវរបួសហើយបានសម្រាកនៅពេទ្យព្រែកថ្មី ក្នុងភូមិភាគពិសេសអស់រយៈពេលមួយខែ ។ ពេលនោះ ប៉ែនឡេង បានជួបជាមួយ ផល ហើយបានពិភាក្សាគ្នាអំពីបញ្ហា ផ្ទៃក្នុងខ្លះៗ ទន្ទឹមនេះ ផល បានរាយការណ៍ប្រាប់ ប៉ែនឡេង ថាបច្ចុប្បន្ន សុខ មានផែនការធ្វើបាតុកម្មក្នុងខែកក្កដា ឆ្នាំ១៩៧៥ នេះ ដោយមានផែនការដណ្តើមរដ្ឋអំណាចនៅទីក្រុងភ្នំពេញ ដែលត្រូវប្រើកម្លាំងមូលដ្ឋានតំបន់២៥ គឺកម្លាំងរបស់ សុខ ដែលនៅភូមិភាគពិសេស ម្យ៉ាងទៀត គាត់បានបញ្ជាក់ប្រាប់ថា ប្រសិនបើ ប៉ែនឡេង មានកម្លាំងប៉ុន្មានគឺគាត់ស្នើសុំឲ្យរៀបត្រៀម ដើម្បីគាំទ្របាតុកម្មខាងមុខនេះ ។ មួយរយៈក្រោយមក ប៉ែនឡេង បានចេញពីមន្ទីរពេទ្យ មិនបានប៉ុន្មានថ្ងៃ ក៏ឮដំណឹងថា អង្គការមានវិធានការចាប់ សុខ ដោយអង្គការស៊ើបដឹងថា សុខ ជារនុកក្នុងធ្វើការប្រឆាំងនឹងបដិវត្តន៍ចំពោះ ប៉ែនឡេង វិញក៏បានដាច់ខ្សែរយៈជាមួយ សុខ ចាប់តាំងពីពេលនោះមក ។ ដល់ខែមិថុនា ឆ្នាំ១៩៧៥ដដែល អង្គការបានចាត់តាំង ប៉ែនឡេង ឲ្យមកនៅក្នុងអង្គភាពថ្មើរជើង ក្នុងកងវរសេនាតូច២៦៥ វរសេនាធំ២៧០ កងពល១២ ។ កាលនោះ ប៉ែនឡេង បានជួប ឈ្មោះ ខាត់ នាទីលេខាវរសេនាតូច និង ឈុន នាទីវរសេនាធំ ។ បន្ទាប់មក ឈុន បានបើកអង្គប្រជុំពិភាក្សាមួយ ដោយលើកអំពីភារកិច្ចដែលត្រូវធ្វើប្រឆាំងនឹងបដិវត្តន៍ គឺត្រូវពិនិត្យមើលសភាពការរបស់បដិវត្តន៍ ឬការកសាងកម្លាំងនៅក្នុងកងទ័ព និងពិនិត្យមើលអំពីបញ្ហាផ្សេងៗ ។ ខណៈនោះ ខាត់ បានលើកឡើងថា កម្លាំងរបស់គាត់មានពីរនាក់ទៀត ១) ផល្លី នាទីអនុសេនាធំ នៅក្នុងកងវរសេនាតូច២៦៥ បច្ចុប្បន្ននៅ ស-២១ ២) គីម នាទីអនុសេនាធំនៅក្នុងវរសេនាតូច៧០៦ កងពល៧០៣ ។ ក្រោយពេលពិភាក្សាគ្នាចប់ ឈុន ក៏បានប្រកាសបិទអង្គប្រជុំ ។

នៅចុងខែសីហា ឆ្នាំ១៩៧៥ អង្គការបានផ្លាស់ ប៉ែនឡេង ឲ្យមកនៅអង្គភាពវរសេនាតូច១៨៣ ដោយប្រគល់ភារកិច្ចឲ្យធ្វើស្រែនៅគោកអំពិល ។ ពេលនោះ ប៉ែនឡេង បានកសាងកម្លាំងថ្មី៦នាក់បន្ថែមទៀត ១) ប៉ូច នាទីអនុសេនាធំ បច្ចុប្បន្ននៅស-២១, ២) ជន នៅស-២១, ៣) លន់ នៅស-២១, ៤) ឆន នៅស-២១,

៥) កុយ នៅស-២១, ៦) លី នៅស-២១ ។ បន្ទាប់មក ប៉េងឡេង បានបញ្ចូលអ្នកទាំងអស់នោះចូលជាសមាជិក សេ.អ៊ី.អា ។ អំឡុងពេលនោះ ប៉េងឡេង បានដាក់ភារកិច្ចឲ្យអ្នកទាំងនោះធ្វើនៅក្នុង ស-២១ គឺត្រូវក្ដាប់សភាពការណ៍នៅស-២១ ប្រសិនបើអង្គការមានវិធានការឃាត់ខ្លួនចំពោះកម្លាំងក្បត់បដិវត្តន៍ថាតើមានអ្នកណាខ្លះ គឺត្រូវរាយការណ៍ទៅគាត់ មួយទៀតត្រូវពង្រីកកម្លាំងនៅក្នុង ស-២១ ដើម្បីស៊ីរូងផ្ទៃក្នុងនៅស-២១ និងត្រូវបង្កទំនាស់ក្នុង ស-២១ ។

រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៦ មានឈ្មោះ ប៉ូច បានរាយការណ៍ទៅ ប៉េងឡេង ថា ខ្មែរក្បត់ដែលអង្គការចាប់បានភាគច្រើនគឺសុទ្ធតែជាសមាជិកនៅក្នុងមូលដ្ឋានតំបន់២៥ រីឯការកសាងកម្លាំងថ្មីវិញ គឺមិនទាន់ធ្វើបាននោះទេ ។ ដល់ខែមីនា ឆ្នាំដដែល មានឈ្មោះ ឆន បានរាយការណ៍ទៅ ប៉េងឡេង ដែរថា ខ្មែរក្បត់ដែលអង្គការរកឃើញភាគច្រើនគឺនៅក្នុងកងទ័ពកង១៧០ ហើយនៅមូលដ្ឋានបូព៌ា និងនៅមូលដ្ឋានតំបន់២៥ ។ ម្យ៉ាងទៀត ឆន បានធ្វើសកម្មភាពបំផុសអំពីបញ្ហាមុខមាត់បុណ្យស័ក្តិដោយនិយាយអំនួតអួតអាងពីបុគ្គលខ្លួន វាយប្រហារដល់អ្នកដទៃ ធ្វើយ៉ាងម៉េចបង្កទំនាស់ឲ្យបាន ដើម្បីបែកបាក់សាមគ្គីភាពគ្នា ។

រហូតមកដល់ដើមឆ្នាំ១៩៧៧ ប៉េងឡេង បានកសាងកម្លាំងថ្មីបាន២១នាក់ថែមទៀត រីឯកម្លាំងទាំងអស់នេះគឺកសាងសម្រាប់ត្រៀមធ្វើសកម្មភាព ក្នុងការវាយបដិវត្តន៍នាពេលខាងមុខ ។ នៅខែមីនា ឆ្នាំដដែលអង្គការត្រូវការកងកម្លាំងរបស់ ប៉េងឡេង មកធ្វើការនៅស-២១ ។ ពេលនោះ ប៉េងឡេង បានចាត់តាំងកម្លាំងចាស់របស់ខ្លួន៥នាក់ មានឈ្មោះ វ៉ាង, ជ្រីវ, ម្រិច, ភន និង ទឹម ។ ពេលដែលអ្នកទាំង៥នាក់ មកដល់ស-២១ អ្នកទាំងនោះមានភារកិច្ចត្រូវបង្កប់ស៊ីរូងផ្ទៃក្នុងនៅស-២១ និងរាយការណ៍ពីសកម្មភាពរបស់បដិវត្តន៍ដូចដែលធ្លាប់ធ្វើកន្លងមក ។ ដល់ខែកក្កដា ឆ្នាំ១៩៧៧ ដដែល អង្គការបានស៊ើបដឹងអំពីសកម្មភាពរបស់ ផល ដែលធ្វើការប្រឆាំងនឹងបដិវត្តន៍ ។ មិនយូរប៉ុន្មាន អង្គការមានវិធានការចាប់ខ្លួន ផល ។ ដោយពេលនោះ ប៉េងឡេង មានការព្រួយបារម្ភ យ៉ាងខ្លាំង ពីព្រោះ ផល បានធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ជាមួយខ្លួន រហូតដល់ថ្ងៃ អង្គការចាប់ខ្លួន ផល ។ អំឡុងពេលនោះ អង្គការបាន ចាត់តាំង ប៉េងឡេង ឲ្យសួរចម្លើយ ផល ផ្ទាល់ ដើម្បីរកខ្សែរយៈក្បត់ជាមួយគាត់ ។ ពេលនោះ ប៉េងឡេង មានផែនការចំពោះ ផល ដោយជម្រៀសគាត់ឲ្យនៅឆ្ងាយពីអ្នកដទៃ ឬត្រូវសួរចម្លើយ និងធ្វើទារុណកម្មគាត់ ឲ្យជ្រុលរហូតដល់ស្លាប់ ។ ផែនការទាំងនេះ ប៉េងឡេង មិនទាន់បានអនុវត្តផង ថ្នាក់លើក៏បានចាត់តាំងគាត់ ឲ្យទៅរៀបចំកម្លាំងដើម្បីការពារស្តាត សម្រាប់អង្គការបើកវគ្គរៀនសូត្រផ្សព្វផ្សាយ អំពីខ្សែក្បត់របស់ខ្មាំងនៅក្នុងឆ្នាំ១៩៧៧នេះ ។ ទន្ទឹមនេះ អង្គការបានអប់រំ ប៉េងឡេង បន្ថែមថា ការការពារនៅស្តាតនេះវាពិតជាមានសារសំខាន់ណាស់ ដូច្នេះ ប៉េងឡេង ឯង ត្រូវឈរជើងនៅទីនេះជាប្រចាំ ដោយមិនចាំបាច់ទៅណាទៀតទេ ។ ពេលនោះ ប៉េងឡេង ក៏បានធ្វើតាមការណែនាំរបស់ថ្នាក់លើ និងបានរៀបចំកម្លាំង ១៥០នាក់ទៀតក្នុងការការពារទីកន្លែងនោះ ។ មួយអាទិត្យក្រោយមក ប៉េងឡេង បាន ឆ្លៀតឱកាសមកអង្គភាពរបស់ខ្លួន ដើម្បីពិភាក្សាជាមួយបក្ខពួក អំពីរឿងរ៉ាវរបស់ ផល ដែលត្រូវបានអង្គការចាប់ខ្លួន ពីព្រោះថា អំឡុងពេលដែល ប៉េងឡេង ទៅបំពេញភារកិច្ចនៅស្តាត ថ្នាក់លើបាននិយាយប្រាប់គាត់ថា អង្គការមានបំណងបញ្ជូន ផល ទៅស-២១ ដើម្បីឲ្យស-២១ អ្នកសួរចម្លើយ ផល វិញ ។ ពេលនោះ ប៉េងឡេង និងបក្ខពួកមានការព្រួយបារម្ភ និងស្មុគស្មាញយ៉ាងខ្លាំង ក៏ចាត់វិធានការលួចដោះលែង ផល ឲ្យទៅលាក់ខ្លួននៅកន្លែងស្ងាត់ ដើម្បីឲ្យអង្គការរកមិនឃើញ ។ បន្ទាប់មក ប៉េងឡេង និងបក្ខពួក បានធ្វើសកម្មភាពនេះបានសម្រេច រីឯ ប៉េងឡេង ក៏វិលត្រឡប់មកស្តាតវិញ ។ ទន្ទឹមនេះ អង្គការបានឮដំណឹងថា ផល ត្រូវបានបក្សក្បត់ជួយរំដោះ រួចហើយបានរៀបចំកម្លាំងតាមចាប់ ផល ម្តងទៀត ។ មួយរយៈក្រោយមក អង្គការបានស៊ើបដឹងពីកន្លែងស្នាក់នៅរបស់ ផល ហើយបានចាត់តាំងកងកម្លាំងបដិវត្តន៍មួយចំនួនឲ្យទៅចាប់ ផល ។ ពេលនោះ អង្គការបានយក ផល ទៅស-២១ ដើម្បីសួរចម្លើយរកបក្ខពួកក្បត់ ។ ទន្ទឹមនេះ ផល បានឆ្លើយសារភាពប្រាប់អង្គការអំពីខ្សែរយៈក្បត់ សេ.អ៊ី.អា ជាបន្តបន្ទាប់ រហូតដល់ថ្ងៃមួយ ផល បានសារភាពប្រាប់អង្គការថា ប៉េងឡេង ក៏ជាខ្សែរយៈក្បត់ សេ.អ៊ី.អា ប្រឆាំងនឹងបដិវត្តន៍ដែរ ។ ភ្លាមៗនោះ អង្គការក៏បានចាត់វិធានការចាប់ ប៉េងឡេង នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៧ ។ **ហួ ចុនា**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អន វណ្ណារ៉ា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthvannara@dccam.org ។





















# បន្តធ្វើបដិវត្តន៍សង្គមនិយមឱ្យខ្លាំងក្លា និងជ្រាលជ្រៅថែមទៀត ដើម្បីការពារបក្សបដិវត្តន៍ ការពារប្រទេសជាតិ ការពារប្រជាជនយើង ឱ្យបានល្អប្រសើរ

*ដកស្រង់ចេញឯកសារយុវជន និងយុវនារីបដិវត្តន៍លេខ ៣-៤ ខែមីនា-មេសា ឆ្នាំ១៩៧៨ D២១៤០៧*

ចាប់ពីក្រោយថ្ងៃ១៧ មេសា ១៩៧៥ មក ប្រទេសជាតិ និងប្រជាជនកម្ពុជា ត្រូវបានរំដោះទាំងស្រុង និងជាស្ថាពរហើយ ។ បក្សបានលើកទិសបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យកាន់តែខ្លាំងក្លា និងជ្រាលជ្រៅថែមទៀត ដើម្បីជាមូលដ្ឋានដ៏រឹងមាំ ក្នុងកិច្ចការពារប្រទេសជាតិ និងកសាងសង្គមនិយមគ្រប់ផ្នែកនៅកម្ពុជាប្រជាធិបតេយ្យយើង ។

**តើធ្វើបដិវត្តន៍សង្គមនិយម គឺធ្វើអ្វី វាយខ្មាំងនៅឯណា?**

ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ចក្រពត្តិអាមេរិក និងបរិវារ ត្រូវវិនាសខ្ចាត់ខ្ចាយអស់ពីលើទឹកដីកម្ពុជាយើងហើយ ។ ពួកវណ្ណៈសក្តិភូមិ វណ្ណៈនាយទុន និងវណ្ណៈជិះជាន់ផ្សេងទៀតទាំងអស់ក៏ត្រូវរលំរលាយ ទាំងរបបនយោបាយ ទាំងមូលដ្ឋានសេដ្ឋកិច្ច ។ ប៉ុន្តែ ឥទ្ធិពលដ៏ពិសពុលរបស់ចក្រពត្តិ វណ្ណៈនាយទុន និងវណ្ណៈសក្តិភូមិ នៅពុំទាន់សាបរលាបអស់នៅឡើយទេ ។ ឥទ្ធិពលដ៏ពិសពុលរបស់ខ្មាំងសត្រូវទាំងនេះ ស្ថិតនៅពាសពេញក្នុងសង្គមជាតិយើងទាំងមូល ។ ខុសគ្នាតែត្រង់តិចឬច្រើន នៅតាមកន្លែងនីមួយៗតែប៉ុណ្ណោះ ។ នៅក្នុងប្រជាជនក៏នៅមានសេសសល់ឥទ្ធិពលនៃសង្គម



កម្មាភិបាលខ្មែរក្រហមនៅតាមក្រសួងមន្ទីរធ្វើការផ្សារពលកម្មបន្ថែម បន្ទាប់ពីសម្រាកពីការផ្សារប្រចាំថ្ងៃ

ចាស់នេះដែរ សល់ជាទស្សនៈ គោលជំហរ សល់ជាទម្លាប់ចាស់ ជារបៀបរបបរស់នៅធ្វើការងារ និងគិតគូពិចារណា សល់ជាលោកទស្សនៈ សល់ជាសតិអារម្មណ៍កម្មសិទ្ធិបុគ្គលសួនតួ មុខមាត់ នាទីតំណែង បក្ខពួកនិយម តំបន់និយម បុណ្យស័ក្តិនិយម ការិយាល័យនិយម នាម៉ឺននិយម អំណាចអជ្ញា ។ល។ សំណល់ចាស់ទាំងអស់នេះហើយ ដែលជាខ្មាំងសត្រូវនៃបដិវត្តន៍សង្គមនិយម ។ ដូច្នេះបន្តធ្វើបដិវត្តន៍សង្គមនិយម ម៉្យាងបន្តវាយកម្ចាត់ និងបោសសម្អាតនូវសំណល់ចាស់ទាំងអស់ខាងលើនេះ ដែលជាឥទ្ធិពលដ៏ពិសពុលរបស់ចក្រពត្តិនិយម អាណានិគមនិយម និងរបបសក្តិភូមិ-នាយទុន ឲ្យអស់រលីងពីក្នុងជួរបក្ស ជួរបដិវត្តន៍ ជួរយុវជន-យុវនារីបដិវត្តន៍យើង និងពីក្នុងសង្គមជាតិយើងទាំងមូល ។ ម៉្យាងទៀត បន្តធ្វើបដិវត្តន៍សង្គមនិយម គឺបន្តកសាងពង្រឹងពង្រីកនូវរបបសមូហភាពនូវទស្សនៈ គោលជំហរ សតិអារម្មណ៍ សមូហភាពវណ្ណៈអធនរបស់បក្ស ឲ្យកាន់តែរឹងប៉ឹង ខ្លាំងក្លាឡើងទាំងខាងការចាត់តាំង ទាំងខាងខ្លឹមសារ ។

**តើហេតុអ្វីបានជាយើងត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យកាន់តែខ្លាំងក្លាជ្រាលជ្រៅថែមទៀត?**

ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ប្រទេសជាតិ និងប្រជាជនកម្ពុជា ត្រូវបានរំដោះទាំងស្រុង និងជាស្ថាពរ ហើយត្រូវឯករាជ្យមួយរយភាគរយហើយ គឺឯករាជ្យទាំងខាងនយោបាយ យោធា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ។ល។ ប៉ុន្តែ ខ្មាំងសត្រូវគ្រប់ប្រភេទ ជាចក្រពត្តិនិយមក្តី ជាវាតទីនិយមក្តី ពិសេសខ្មាំងយួនលោភលន់វាតទីលេបទឹកដី វាប៉ុនប៉ងបំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជា ប្រជាជនកម្ពុជា ហើយវាយកកម្ពុជាទៅធ្វើជាខ្ញុំកញ្ជះវាវិញជារៀងរហូត ។ បើប្រសិនជាយើងមិនបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យខ្លាំងក្លាជ្រាលជ្រៅទេ នោះរបបឯកជននឹងងើបក្បាលឡើងវិញ ។ វណ្ណៈនាយទុនចាស់ក្តី ឬជាវណ្ណៈនាយទុនដែលទើបកើតមានថ្មីក្តី នឹងងើបក្បាលឡើងវិញនៅកម្ពុជាយើង ។ ដូច្នេះ របបមនុស្សជិះជាន់មនុស្សដូចកាលពីសង្គមចាស់ ក៏នឹងវិលត្រឡប់មកវិញ ។ ប្រទេសជាតិនឹងធ្លាក់ទៅជាខ្ញុំបញ្ចះគេវិញ ។ ប្រជាជនកម្ពុជាត្រូវធ្លាក់ទៅជាប្រជាជនខ្ញុំគេទៀត ដូច្នោះ រងទុក្ខវេទនា ឈឺចាប់ខ្លោចផ្សា ក្រខ្សត់អត់ឃ្លានរកទីបំផុតគ្មានឡើយ ។ ខ្ញុំគេម្តងនេះ គឺប្រាកដជាខ្ញុំយួន និងបក្ខពួកវា ។

**តើប្រជាជនកម្ពុជា យុវជន-យុវនារីបដិវត្តន៍កម្ពុជាយើងដែលខំធ្វើពលិកម្មសព្វបែបយ៉ាង បង្ហូរញើសឈាម បោលសាច់បោលឆ្អឹងច្រើនឥតគណនាក្នុងពេលកន្លងមក ដើម្បីរំដោះប្រទេសជាតិ រំដោះប្រជាជន និងរំដោះខ្លួនឲ្យរួចផុតពីភាពខ្ញុំគេនោះ ក្រោយពេលដែលរំដោះបានហើយ តើសុខចិត្តមកធ្វើខ្ញុំយួនទៀតទេ?**

ប្រជាជនកម្ពុជា យុវជន-យុវនារីបដិវត្តន៍កម្ពុជាយើងទាំងអស់ ដាច់ខាតមិនព្រមជាខ្ញុំកញ្ជះនរណាទៀតឡើយ ។ ខ្ញុំកញ្ជះមហាអំណាចចក្រពត្តិក៏មិនព្រម ខ្ញុំកញ្ជះយួន និងបក្ខពួកវា ក៏រឹតតែមិនសុខចិត្តទៀត ។ អាស្រ័យហេតុផលទាំងនេះហើយ បានជាប្រជាជនកម្ពុជា យុវជន-យុវនារីបដិវត្តន៍កម្ពុជាយើង ត្រូវតែបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យកាន់តែខ្លាំងក្លា ជ្រាលជ្រៅថែមទៀត ដើម្បីការពារបក្ស បដិវត្តន៍ ការពារប្រទេសជាតិ ការពារទឹកដី និងការពារប្រជាជនកម្ពុជាយើង ឲ្យបានគង់វង្ស ស្ថិតស្ថេរ និងក្រហមឆ្អិនឆ្អៅជារៀងរហូតទៅ ។ បច្ចុប្បន្ននេះ ក៏ត្រូវការពារ តទៅអនាគតរាប់រយរាប់ពាន់ជំនាន់ទៀត ក៏ត្រូវការពារទៀត ។

**តើចលនាបដិវត្តន៍សង្គមនិយមយើងមកទល់សព្វថ្ងៃនេះមានការវិវត្តដល់ណាហើយ ហើយនៅមានការខ្វះខាតយ៉ាងណាខ្លះ?**

និយាយរួម មកទល់ថ្ងៃនេះ ចលនាបដិវត្តន៍សង្គមនិយមនៅកម្ពុជាយើង មានដំណើរវិវត្តទៅមុខវែងឆ្ងាយហើយ ។ ពិនិត្យខាងចាត់តាំង ឃើញថា ក្នុងសង្គមជាតិកម្ពុជាយើងទាំងមូល គ្មានការចាត់តាំងជាឯកជនទៀតឡើយ ។ ប្រជាជនយើងរស់នៅធ្វើការងារជាសមូហភាពអស់ហើយ ។ នៅជនបទ យើងមានសហករណ៍កសិករនៅទូទាំងប្រទេសហើយ ។ ពីមុន សហករណ៍នេះ មានត្រឹមតែក្រុមពី១៣-១៤ ទៅ១៥គ្រួសារប៉ុណ្ណោះ ។ តែបច្ចុប្បន្ននេះ ក្រុមសហករណ៍តូចៗនេះ បានរីកចម្រើនឈានដល់សហករណ៍ឃុំពី៧០០-៨០០ គ្រួសារ ដល់១.០០០គ្រួសារជាទូទៅហើយ ។ ឯនៅទីក្រុង យើងមានសហជីពកម្មករ ។ កម្មករ យុទ្ធជន-យុទ្ធនារីកងទ័ពបដិវត្តន៍យើង សុទ្ធតែរស់នៅធ្វើការងារជាសមូហភាពនៅក្នុងសហជីព និងតាមអង្គភាព មន្ទីរ ក្រសួងទាំងអស់គ្នាហើយ ។ បើពិនិត្យខាងនយោបាយ-សតិអារម្មណ៍វិញ ក៏ឃើញថា ប្រជាជន

កម្មករ-កសិករ កងទ័ពបដិវត្តន៍ យុទ្ធជន-យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍យើង កាន់តែយល់ជ្រួតជ្រាបអំពីបដិវត្តន៍សង្គមនិយម កាន់តែឃើញនូវសារសំខាន់ និងការចាំបាច់ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យកាន់តែខ្លាំងក្លា ជ្រាលជ្រៅថែមទៀត ដើម្បីការពារបក្សបដិវត្តន៍ ការពារទឹកដី និងដើម្បីប្រទេសជាតិ និងប្រជាជនកម្ពុជារស់រានមានជីវិតក្នុងកិត្តិយសថ្លៃថ្នូរ ក្នុងឯករាជ្យជាតិ អធិបតេយ្យភាព ក្នុងបូរណភាពដែនដីដ៏ពិសិដ្ឋរបស់ខ្លួនជារៀងរហូតទៅ ។ ដូច្នេះប្រជាជនយើង យុវជន-យុវនារីបដិវត្តន៍កម្ពុជាយើង ក៏កាន់តែជ្រះថ្លា ហើយពេញចិត្ត ពេញថ្លើម និងរបបសម្ហូហភាព ។ បងប្អូនស្រឡាញ់ ហើយយកអស់កម្លាំងកាយចិត្ត ការពាររបបសម្ហូហភាពនេះ ពង្រឹងពង្រីករបបសម្ហូហភាពនេះ ឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លាឡើងជាប់ជានិច្ច ។ អាស្រ័យដោយរបបសម្ហូហភាពសង្គមនិយមយើងមានការរីកចម្រើនទាំងខាងការចាត់តាំង រឹងប៉ឹង ខ្លាំងក្លា ទាំងខាងខ្លឹមសារ ហើយប្រជាជន យុវជន-យុវនារីយើង ក៏មានគោលជំហរសម្ហូហភាព សង្គមនិយមកាន់តែខ្ពស់ឡើង កាន់តែជ្រះថ្លាឡើងយ៉ាងនេះហើយ បានជាខ្មាំងសត្រូវគ្រប់ទិសទី ពិសេសខ្មាំងយួនវៀតទីនិយមលេបទឹកដី មិនត្រឹមតែពុំអាចលេបត្របាក់កម្ពុជាយើងបានប៉ុណ្ណោះទេ តែវាថែមទាំងត្រូវកងទ័ពបដិវត្តន៍ និងប្រជាជនកម្ពុជាយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា វាយបំបាក់ឲ្យបរាជ័យវិនាសខ្ទាត់ខ្ទាយអស់តែរាល់លើក ។ ពិសេសការបរាជ័យយ៉ាងធ្ងន់ធ្ងរ និងយ៉ាងអាម៉ាសបំផុតរបស់ខ្មាំងយួនឈ្លានពានវៀតទីលេបទឹកដី កាលពីថ្ងៃទី០៦ មករា ១៩៧៨ កន្លងទៅថ្មីៗនេះ ។ ទាំងអស់នេះបញ្ជាក់ឲ្យឃើញច្បាស់ថា បើប្រសិនជាយើងមិនបានបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យខ្លាំងក្លាជ្រាលជ្រៅជាប់រហូតមកទេ ពោលគឺ បើប្រសិនជាយើងគ្មានរបបសម្ហូហភាពសង្គមនិយម រឹងប៉ឹងខ្លាំងក្លាទេនោះប្រហែលជានឹងគ្មានមហាជ័យជម្នះថ្ងៃ០៦ មករា ១៩៧៨ លើខ្មាំងយួនឈ្លានពានវៀតទី លេបទឹកដីនោះឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ មិនដឹងជាប្រទេសជាតិ និងប្រជាជនកម្ពុជាយើងត្រូវវិនាសហិនហោចខ្ទេចខ្ទីយ៉ាងណាទេ ហើយធ្លាក់ខ្លួនទៅជាខ្ញុំកញ្ជះយួនទៀតផង ។

សរុបមក ចលនាបដិវត្តន៍សង្គមនិយម នៅកម្ពុជាយើងបច្ចុប្បន្ននេះបានវិវត្តទៅមុខ តាមទិសល្អត្រឹមត្រូវឆ្ងាយណាស់ទៅហើយ ។ យុវជន-យុវនារីបដិវត្តន៍យើង ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យកាន់តែខ្លាំងក្លាជ្រាលជ្រៅទៅថែមទៀត ដើម្បីជំរុញចលនាបដិវត្តន៍សង្គមនិយមយើងបច្ចុប្បន្ននេះ ឲ្យវិវត្តទៅមុខលឿនស្ទើរបានដល់ទិសដៅឆាប់រហ័ស ដើម្បីជាមូលដ្ឋានរឹងមាំក្នុងកិច្ចការពារប្រទេសជាតិ និងកសាងសង្គមនិយមគ្រប់ផ្នែកនៅកម្ពុជាប្រជាធិបតេយ្យយើង ឲ្យរីកចម្រើនថ្កុំថ្កើងរុងរឿងយ៉ាងឆាប់រហ័ស ។ ប៉ុន្តែទន្ទឹមនឹងគុណសម្បត្តិទាំងខាងលើនេះ យើងក៏នៅមានការខ្វះខាតមួយចំនួនដែរ នៅតាមអង្គភាពខ្លះ និងតាមបុគ្គលខ្លះៗ ដែលយើងត្រូវតែមើលឃើញ ហើយចាប់អារម្មណ៍ឲ្យខ្ពស់ដើម្បីវាយកម្ទាត់វា ឲ្យបានឆាប់រហ័សទាន់ពេលវេលា និងឲ្យអស់រលីងពីក្នុងជួរបដិវត្តន៍យើង ពីក្នុងសង្គមជាតិយើង ក៏ដូចពីក្នុងខ្លួនយើងម្នាក់ៗដែរ ។

ទស្សនៈខុសឆ្គងមួយចំនួនចំពោះការបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យកាន់តែខ្លាំងក្លា និងជ្រាលជ្រៅថែមទៀតក្នុងពេលបច្ចុប្បន្ននេះ:

១) មានមិត្តយើងខ្លះ "ចំនួនតិច" មានទស្សនៈខុសឆ្គងថា យើងជ័យជម្នះហើយ យើងឯករាជហើយ តើចាំបាច់បន្តធ្វើបដិវត្តន៍សង្គមនិយមធ្វើអ្វីទៀត នាំតែតឹងតែងចង្អៀតចង្អល់ក្នុងចិត្ត នាំតែបែកបាក់សាមគ្គី ។ មិត្តយើងមើលមិនឃើញនូវតួនាទីនៃការបន្តធ្វើបដិវត្តន៍សង្គមនិយមនៅក្រោយជ័យជម្នះ ១៧ មេសា ១៩៧៥ ឡើយ ។ បើប្រសិនជាយើងមិនបានបន្តធ្វើបដិវត្តន៍សង្គមនិយម បោសសម្អាតរបបឯកជន វាយកម្ទាត់កម្មសិទ្ធិបុគ្គលសួនតួឲ្យអស់ពីក្នុងជួរបដិវត្តន៍ ពីក្នុងសង្គមជាតិ និងពីក្នុងខ្លួនយើងម្នាក់ៗទេនោះខ្មាំងសត្រូវជាចក្រពត្តិ ជាវណ្ណៈនាយទុន-សក្តិភូមិ ជាវៀតទីនិយមពិសេសខ្មាំងយួនវៀតទីលេបទឹកដី ប្រាកដជានឹងងើបក្បាលឡើងវិញនៅក្នុងសង្គមជាតិយើង ធ្វើសកម្មភាពញុះញង់ បង្កហេតុបំបែកបំបាក់សាមគ្គីភាព-ឯកភាពផ្ទៃក្នុងជួរបដិវត្តន៍យើង ជួរយុវជន-យុវនារីបដិវត្តន៍យើង និងក្នុងសង្គមជាតិយើងទាំងមូលមិនខានឡើយ ។ តាមរយៈនេះ ពួកខ្មាំងសត្រូវគ្រប់ប្រភេទវាបំផ្លិចបំផ្លាញ និងវាយកម្ទេចបដិវត្តន៍កម្ពុជា ហើយដណ្តើមយកកម្ពុជា និងប្រជាជនកម្ពុជា ទៅធ្វើជាខ្ញុំកញ្ជះវាវិញបានជាដាច់ខាត ។ ប៉ុន្តែដោយយើងបានបន្តធ្វើបដិវត្តន៍សង្គមនិយម កាន់តែខ្លាំងក្លាជ្រាលជ្រៅឡើង យើងរក្សាការពារសាមគ្គីភាព-ឯកភាពផ្ទៃក្នុងនេះក៏

បានល្អទៀត ។ ព្រមជាមួយនេះយើងរកឃើញថាខ្មាំងដែលបង្កប់ស៊ីរូងផ្ទៃក្នុង១០-២០ឆ្នាំមកហើយ ក៏ឃើញហើយបានវាយកម្ចាត់ និងបោសសម្អាតខ្សែខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងគ្រប់ប្រភេទបានជាបន្តបន្ទាប់ ។ អាស្រ័យហេតុនេះហើយ បានជានៅពេលដែលខ្មាំងយួនវាតទីលេបទឹកដី វាលើកទ័ពចូលឈ្លានពានចូលកម្ពុជាយើងដោយទ្រង់ទ្រាយធំ ដោយមិនឲ្យយើងដឹងខ្លួនជាមុនយ៉ាងណាក្តី កាលពីចុងឆ្នាំ៧៧ និងដើមឆ្នាំ៧៨កន្លងទៅនេះ ក៏វាពុំអាចលេបត្របាក់យើងបានដែរ ។ ដូច្នេះបដិវត្តន៍សង្គមនិយមនេះហើយ ដែលធ្វើឲ្យផ្ទៃក្នុងយើងស្អាតល្អថ្កូវផង់ ហើយតាមរយៈនេះ សាមគ្គីភាព-ឯកភាពផ្ទៃក្នុងរបស់យើងត្រូវបានពង្រឹង និងពង្រីកកាន់តែរឹងមាំ និងកាន់តែល្អបរិសុទ្ធជាងពេលណាៗទាំងអស់ ។

២) មានមិត្តយើងខ្លះទៀតយល់ស្របថាត្រូវតែបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យខ្លាំងក្លាជ្រាលជ្រៅទៀត តែគេមើលឃើញតែចលនានៅក្នុងមហាជនតែប៉ុណ្ណោះ គេទិតៀនកសាងឲ្យមហាជនឲ្យសមូហភាពបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យជ្រាលជ្រៅខ្លាំងក្លា តែចំពោះខ្លួនគេគឺឋិតនៅខាងក្រៅចលនាដ៏សន្ធោរសន្ធៅរបស់មហាជនទៅវិញ ។ ដូច្នេះគេឲ្យមហាជនធ្វើបដិវត្តន៍សង្គមនិយម នៅក្នុងចលនាសមូហភាពតែខ្លួនគេ គឺចង់រស់នៅជាឯកជនដាច់ដោយឡែក ។

៣) គេយល់ស្របថា ត្រូវធ្វើបដិវត្តន៍សង្គមនិយមដើម្បីវាយខ្មាំងឈ្នះ តែគេធុញទ្រាន់នឹងការប្រជុំជីវភាព គេចង្អៀតចង្អល់ក្នុងចិត្តពេលធ្វើការទិទៀន និងស្វ័យទិតៀន ពីព្រោះការទិទៀន និងស្វ័យទិទៀននេះ វាចេះតែបើកកកាយនូវកម្មសិទ្ធិបុគ្គលស្លូនត្លូរបស់គេដូច្នេះគេខំលាក់បំពួន និងឱបក្រសោបនូវកម្មសិទ្ធិបុគ្គលស្លូនត្លូនេះតទៅទៀត មិនចង់ឲ្យមហាជនខ្វេះកកាយ ឬជួយវាយឲ្យរបើកនូវកម្មសិទ្ធិបុគ្គលស្លូនត្លូពីក្នុងខ្លួនគេឡើយ ។ ដូច្នេះបានសេចក្តីថា មិនយើងមិនមែនធ្វើបដិវត្តន៍សង្គមនិយមទេ តែគឺរួមរស់ជាមួយខ្មាំងសត្រូវវណ្ណៈនៅក្នុងខ្លួន ។ បើរួមរស់ជាមួយខ្មាំងសត្រូវវណ្ណៈនៅក្នុងខ្លួនហើយ វាយខ្មាំងសត្រូវខាងក្រៅក៏មិនខ្លាំងដែរ ។ បើខ្មាំងសត្រូវខាងក្រៅ ក៏វាយមិនឈ្នះ ខ្មាំងសត្រូវខាងក្នុងខ្លួនក៏មិនព្រមវាយកម្ចាត់វានោះ ថ្ងៃណាមួយខ្មាំងសត្រូវទាំងពីរនេះ វានឹងព្រួតគ្នាវាកម្ទេចខ្លួនយើងមិនខានឡើយ ។ នេះហើយជាគ្រោះមហន្តរាយចំពោះបុគ្គលផ្ទាល់ខ្លួន ក៏ដូចចំពោះបក្ស បដិវត្តន៍ ប្រទេសជាតិ និងប្រជាជនកម្ពុជាយើងទាំងមូលដែរ ។ ដូច្នេះយើងប្រកាន់ជាការពារបក្សបដិវត្តន៍ ប្រទេសជាតិ និងប្រជាជនកម្ពុជាយើងពុំបានឡើយ ។

៤) មិត្តយើងខ្លះទៀត ទុកជីវទស្សន៍បដិវត្តន៍ ទុកដូចជាតុលាការសឹក ។ ម៉្លោះហើយគេខ្លាចជីវទស្សន៍បដិវត្តន៍ គេគេចជីវទស្សន៍បដិវត្តន៍ ឬក៏ធ្វើជីវទស្សន៍បដិវត្តន៍មិនស្មោះត្រង់ នៅមានលាក់លាមកែគេច ។ ដូច្នេះកសាងខ្លួនក៏មិនចម្រើន ហើយមានការស្មុគស្មាញជាបន្តបន្ទាប់ ។ បើស្មុគស្មាញជំពាក់ចាក់ស្រេះ ជាបន្តបន្ទាប់ជាប់ជាប្រចាំហើយ នោះមិត្តយើងមុខជានឹងធ្លាក់ទៅជាចំណីខ្មាំងពុំខានឡើយ ។ ដូច្នេះមិត្តយើងមិនត្រឹមតែមិនបានធ្វើបដិវត្តន៍សង្គមនិយម ជាមួយមហាជនប៉ុណ្ណោះទេ តែមិត្តបែរទៅជាទំនាស់ថ្នាំងថ្នាក់នឹងមាគ៌ាបដិវត្តន៍សង្គមនិយមរបស់បក្ស ហើយក្លាយខ្លួនទៅជាប្រឆាំងនឹងបដិវត្តន៍សង្គមនិយមទៀតផង ។

វិធានការមួយចំនួន ដើម្បីបន្តធ្វើបដិវត្តន៍សង្គមនិយមបានខ្លាំងក្លា និងជ្រាលជ្រៅថែមទៀតៈ

យើងបានឃើញហេតុផល និងសារសំខាន់ជាការចាំបាច់ដែលប្រជាជនកម្ពុជា យុវជន-យុវនារីកម្ពុជាយើង ត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យខ្លាំងក្លា ជ្រាលជ្រៅតទៅទៀត ហើយជាពិសេសក្នុងពេលបច្ចុប្បន្ននេះ ដែលខ្មាំងយួនលោភលន់វាតទីលេបទឹក វានៅតែបន្តធ្វើសកម្មភាពបុករុកនៅតាមព្រំដែនជាប់ជាប្រចាំ និងបន្តដើរខបាយកលពិសពុលខ្មៅងងឹតសព្វបែបយ៉ាង យ៉ាងមមាញឹកទាំងចំហ ទាំងសម្ងាត់ ទាំងខាងយោធា ទាំងខាងនយោបាយទាំងខាងចារកម្ម ទាំងខាងវិទ្ធង្សនា ទាំងវិទ្ធេចកម្ម ។ល ។ ប៉ុនប៉ងវាយលុកឈ្លានពានចូលទឹកដីកម្ពុជា ជាថ្មីទៀតដើម្បីសម្រេចយុទ្ធសាស្ត្រ សហព័ន្ធឥណ្ឌូចិនរបស់វា និងយកកម្ពុជាប្រជាធិបតេយ្យយើង និងប្រជាជនកម្ពុជាយើងទៅធ្វើជាខ្ញុំកញ្ជះវាជារៀងរហូត ។ ដូច្នេះកាលពីទើបរំដោះប្រទេសជាតិយើង បានទាំងស្រុងជាស្ថាពរនៅថ្ងៃទី១៧ មេសា ១៩៧៥ កន្លងទៅក៏យើងត្រូវបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យខ្លាំងក្លាជ្រាលជ្រៅហើយបច្ចុប្បន្ននេះ និងទៅអនាគតទៀត យើងរឹតតែបន្តត្រូវធ្វើបដិវត្តន៍សង្គមនិយម ឲ្យកាន់តែខ្លាំងក្លាជ្រាលជ្រៅទ្វេឡើងថែមទៀត បន្តវាយកម្ចាត់ និងបោសសម្អាតនូវសំណល់ និងឥទ្ធិពលពិសពុលនៃវណ្ណៈនាយទុន និងរបប

ឯកជនរបស់វា និងរបបវណ្ណៈជិះជាន់ផ្សេងៗ ឲ្យអស់រលីងពីក្នុងជួរបដិវត្តន៍យើង ជួរយុវជន-យុវនារីបដិវត្តន៍យើង ក៏ដូចពីក្នុងសង្គមជាតិយើងត្រូវបន្តវាយកម្ទាត់ឲ្យបានជ្រះស្រឡះដាច់ខាត នូវកម្មសិទ្ធិបុគ្គលសួនតួឲ្យអស់រលីងពីក្នុងខ្លួនម្នាក់ៗ ក៏ដូចពីក្នុងអង្គភាពយើង ពីក្នុងជួរបដិវត្តន៍យើង និងពីក្នុងសង្គមជាតិយើងទាំងមូលដែរ ទោះជាខាងទស្សនៈគោលជំហរក្តី ជាខាងសម្ភារក្តី ជាលោកទស្សនៈក្តី ជាមនោសញ្ចេតនាក្តី ជាទម្លាប់ចាស់ក្តី ជាអាកប្បកិរិយា និងរបៀបរបបរស់នៅធ្វើការងារក្តី ។ ព្រមជាមួយនេះ យុវជន-យុវនារីបដិវត្តន៍យើងក៏ត្រូវខិតខំកសាង បំពាក់បំប៉នឲ្យខ្លួនយើងនូវគោលជំហរសមូហភាពវណ្ណៈអធនរបស់បក្ស និងនិស្ស័យសង្គមនិយមឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លាឡើងជានិច្ច ដើម្បីធ្វើឲ្យខ្លួនយើងម្នាក់ៗទៅជាយុវជន-យុវនារីសង្គមនិយមរឹងប៉ឹង ឲ្យអង្គភាពយើងនីមួយៗ ក៏ដូចក្នុងសង្គមជាតិយើងទាំងមូល ទៅជាអង្គភាពសង្គមនិយមរឹងប៉ឹងខ្លាំងក្លា ទៅជាសង្គមជាតិសមូហភាពសង្គមនិយមរឹងប៉ឹងខ្លាំងក្លា និងក្រហមឆ្អិនឆ្អៅឡើងជានិច្ច និងជារៀងរហូតរាប់ជំនាន់តៗទៅទៀត ។ ធ្វើយ៉ាងនេះទើបធានាដល់កិច្ចការពារប្រទេសជាតិ ការពារឯករាជ្យជាតិ អធិបតេយ្យជាតិ កិត្តិយសជាតិ និងបូរណភាពដែនដីជាតិយើងបានគង់វង់ឋិតថេរជារៀងរហូត និងបានល្អប្រសើរជាប់ជានិច្ច ។ បើយុវជន-យុវនារីបដិវត្តន៍យើងជំនាន់នេះ បន្តធ្វើបដិវត្តន៍សង្គមនិយមបានខ្លាំងក្លា និងជ្រាលជ្រៅយ៉ាងនេះហើយ ជំនាន់តៗទៅមុខទៀតក៏នឹងចេះតែរឹងប៉ឹងខ្លាំងក្លាឡើងជានិច្ច សង្គមកម្ពុជាយើងក៏នឹងទៅជាសង្គមសមូហភាពសង្គមនិយមមួយ ដែលនឹងចេះតែរីកចម្រើន និងកាន់តែរឹងប៉ឹងខ្លាំងក្លាឡើងជាលំដាប់តរៀងទៅដែរ ។ ដូច្នេះខ្មាំងសត្រូវគ្រប់ប្រភេទ ពិសេសខ្មាំងយួនលោភលន់វាតទីលេបទឹកដី ទោះបីជាមានអាវុធទំនើបសម្បូរបែបច្រើនយ៉ាងក៏ដោយ ទោះបីជាវាប្រើគ្រប់កលល្បិច ត្រជាក់ ក្តៅ ចំហ សម្ងាត់ខ្មៅងងឹតយ៉ាងណាក្តី ក៏វាពុំអាចធ្វើអ្វីយើងបានដែរ ហើយក៏វារឹតតែពុំអាចលេបកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជាយើង ទៅបញ្ចូលក្នុងសហព័ន្ធឥណ្ឌូចិនដ៏អាស្រូវរបស់វា ឬក៏យកទៅធ្វើជាជនជាតិភាគតិចរបស់វាបានឡើយ ។ កម្ពុជាប្រជាធិបតេយ្យ ពិតជានឹងឋិតនៅជ្រងៅៗ ក្នុងឯករាជភាព អធិបតេយ្យភាព និងកិត្តិយសជាតិដ៏រុងរឿងថ្កើងថ្កាន នៅលើបូរណភាពដែនដីដ៏ពិសិដ្ឋរបស់ខ្លួនជារៀងរហូត ហើយបន្តលើកជ្រោងគ្រវីទង់ឯករាជ្យ-ម្ចាស់ការ ខ្លួនទីពឹងខ្លួនខ្លួនកាន់កាប់វាសនាប្រទេសជាតិខ្លួនដោយខ្លួនឯង កាន់តែខ្ពស់ត្រដែតត្រដឹម និងកាន់តែក្រហមឆ្អិនឆ្អៅឡើងជានិច្ច ដើម្បីជាគំរូដល់ប្រទេសតូចនានា និងប្រជាជនដែលត្រូវគេជិះជាន់ សង្កត់សង្កិនឈ្វានពានជាន់ឈ្លី និងមើលងាយមើលថោកនៅលើសកលលោកទាំងអស់ដែរ ។

ដូច្នេះភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យកាន់តែខ្លាំងក្លាជ្រាលជ្រៅឡើងថែមទៀត របស់យុវជន-យុវនារីបដិវត្តន៍យើងនាពេលបច្ចុប្បន្ន ក៏ដូចទៅអនាគតទៀតដែរ គឺជាភារកិច្ចរុងរឿងថ្លៃថ្លា ដែលទាក់ទងនឹងអាយុជីវិត និងវាសនាអនាគតរបស់ប្រទេសជាតិយើង ចលនាបដិវត្តន៍យើងបក្សកម្មុយនិស្តយើង ប្រជាជនកម្ពុជាយើង ក៏ទាក់ទងដល់អាយុជីវិត និងវាសនាអនាគតយូរអង្វែងរបស់យុវជន-យុវនារីកម្ពុជាយើងទាំងមូលដែរ ។ តើខ្ញុំយួនឬឯករាជ្យ-ម្ចាស់ការ ក្នុងឯករាជជាតិ អធិបតេយ្យជាតិ កិត្តិយសជាតិ នៅក្នុងបូរណភាពដែនដីជាតិរបស់ខ្លួនតទៅទៀត? តើឋិតនៅអាប់ឱនកិត្តិយសទាបថោក ត្រូវគេប្រមាថមើលងាយមើលថោកក្នុងឋានៈជាខ្ញុំកញ្ជះយួនជាជនជាតិភាគតិចរបស់យួន ឬក៏រស់នៅក្នុងកិត្តិយសថ្លៃថ្នូរ សំបូរសប្បាយរុងរឿងថ្កើងថ្កានត្រដែតត្រដឹម ក្នុងឋានៈជាប្រជាជាតិ និងប្រជាជនមួយឯករាជ្យ ម្ចាស់ប្រទេស ម្ចាស់ទឹកដីព្រៃព្រឹក្សា ម្ចាស់វាសនាអនាគតរបស់ខ្លួន ម្ចាស់បដិវត្តន៍របស់ខ្លួនជារៀងរហូតទៅ?

ដូច្នេះភារកិច្ចបន្តធ្វើបដិវត្តន៍សង្គមនិយមរបស់យុវជន-យុវនារីបដិវត្តន៍យើងបច្ចុប្បន្ន ក៏ដូចទៅអនាគតទៀតនេះ ជាកិត្តិយសខ្ពង់ខ្ពស់ថ្លៃថ្លា និងជាមោទកភាពខ្ពង់ខ្ពស់បំផុតរបស់យុវជនយុវនារីបដិវត្តន៍យើង ដែលត្រូវបន្តវេនបដិវត្តន៍តទៅអនាគតទៀតឲ្យបានរឹងប៉ឹងខ្លាំងក្លា និងក្រហមឆ្អិនឆ្អៅជារៀងរហូត ។ ដើម្បីបន្តធ្វើបដិវត្តន៍សង្គមនិយមឲ្យកាន់តែខ្លាំងក្លាជ្រាលជ្រៅថែមទៀតត្រូវៈ

១) យកចិត្តទុកដាក់ខិតខំរៀនសូត្រមាគ៌ានយោបាយ សតិអារម្មណ៍ចាត់តាំងគ្រប់ផ្នែករបស់បក្សបង្កើនសមត្ថភាពយល់ដឹងទាំងខាងទ្រឹស្តី ទាំងខាងទស្សនៈគោលជំហរ ឲ្យដល់ខ្លួនជាប់ជានិច្ច ដើម្បីជាពន្លឺក្នុងការកសាងខ្លួន ក៏ដូចក្នុងការរស់នៅធ្វើការងារ

បំពេញភារកិច្ចបដិវត្តន៍តូចធំប្រចាំដែរ ដើម្បីចៀសវាងកុំឲ្យចាញ់ឧបាយកលខ្មាំង ចាញ់ការឃោសនាបោកបញ្ឆោតរបស់ខ្មាំង និងកុំឲ្យធ្លាក់ទៅជាចំណីខ្មាំងដាច់ខាត ។

(២) ឧស្សាហ៍ប្រជុំដកពិសោធន៍ឲ្យបានញឹកញាប់ ជាប្រជុំសន្និបាតក្តី ជាប្រជុំជីវភាពប្រចាំខែក្តី ជាប្រជុំស៊ីជម្រៅប្រចាំអាទិត្យក្តី ជាប្រជុំដកពិសោធន៍លើការងារប្រចាំថ្ងៃក្តី ដើម្បីរៀនសូត្រទាំងពិសោធន៍ខុស ទាំងពិសោធន៍ត្រូវរបស់ចលនាបដិវត្តន៍យើង ចលនាមហាជនយើងនៅទូទាំងប្រទេសក្តី នៅតាមមន្ទីរ-ក្រសួងអង្គភាពយើងក្តី ទើបយើងកាន់តែមានពិសោធន៍ល្អៗថ្មីៗជានិច្ច ក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយម ឲ្យកាន់តែខ្លាំងក្លាជ្រាលជ្រៅថែមទៀត ។ ដូច្នោះយុវជន-យុវនារីបដិវត្តន៍យើង កុំធុញទ្រាន់នឹងការប្រជុំកុំខ្ជិលខាតពេលវេលា ខាតការងារដោយសារតែមកចូលរួមប្រជុំញឹកញាប់ ។ ការប្រជុំសព្វបែបយ៉ាងនេះហើយ ដែលធ្វើឲ្យយើងកាន់តែភ្លឺស្វាង កាន់តែយល់ដឹងអំពីបដិវត្តន៍សង្គមនិយម កាន់តែភ្ញាក់រឭកអំពីបដិវត្តន៍សង្គមនិយមជាបន្តបន្ទាប់ និងជាលំដាប់លំដោយជាប់ជានិច្ច ។

(៣) យកចិត្តទុកដាក់បំផុសប្រជាធិបតេយ្យ-ប្រមូលផ្តុំ ក្នុងការដឹកនាំធ្វើការងារ ក៏ដូចក្នុងការប្រជុំរៀនសូត្រផ្សេងៗដែរ ដោយបំផុសការទិតៀន និងស្វ័យទិតៀនឲ្យខ្លាំងក្លា និងស៊ីជម្រៅទៅលើទស្សនៈគោលជំហរ និងសតិអារម្មណ៍របស់មិត្តយើងម្នាក់ៗ ។ ចៀសវាងដាច់ខាត កុំធ្វើទិតៀន-ស្វ័យទិតៀនលំៗ សើរៗ លើបញ្ហាកំប៉ិកកំប៉ុកជាមែកធាង ជារូបភាព និងបាតុភាពខាងក្រៅប៉ុណ្ណោះ ព្រោះនាំឲ្យតែបែកបាក់សាមគ្គី ហើយកសាងទស្សនៈគោលជំហរ សតិអារម្មណ៍ខ្លួនយើង និងមិត្តយើងមិនបានរឹងប៉ឹងទេ ។ ចៀសវាងដាច់ខាតកុំធ្វើការទិតៀនស្វ័យទិតៀនលំៗ បគ្រប់តែកិច្ចតាមការចាត់តាំងប៉ុណ្ណោះ ។ ទិទៀនស្វ័យទិទៀនបែបនេះ មិនមែនជាការតស៊ូវណ្ណៈ មិនមែនជាការធ្វើបដិវត្តន៍សង្គមនិយមទេ ។ តែផ្ទុយទៅវិញវាគ្រាន់តែជាការរួមរស់វណ្ណៈ ដែលពាក់ផ្លាកសង្គមនិយមបំភាន់មតិមហាជន និងបំភាន់សតិសម្បជញ្ញៈរបស់ខ្លួនតែប៉ុណ្ណោះ ។ បើយុវជន-យុវនារីបដិវត្តន៍យើងធ្វើបដិវត្តន៍សង្គមនិយមបែបនេះមិនខ្លាំងទេ ការពារប្រទេសក៏មិនបានវាយខ្លាំងសត្រូវគ្រប់ទិសទី ដែលប៉ុនប៉ងយាយីកម្ពុជាប្រជាធិបតេយ្យយើង ពិសេសវាយខ្មាំងយួនលោភលន់វាតទីលេបទឹកដីយើងក៏មិនឈ្នះ ។ ដូច្នេះយុវជន-យុវនារីបដិវត្តន៍បែបនេះកសាងប្រទេសគ្រប់ផ្នែកក៏មិនខ្លាំង ហើយក៏មិនបានរីកចម្រើនលូតលាស់ថ្កុំថ្កើងរុងរឿងឆាប់រហ័សតាមសំណូមពរដ៏ពិសិដ្ឋរបស់បក្ស និងប្រជាជនកម្ពុជាយើង ។

សរុបទាំងអស់នេះហើយដែលជាធាតុពិត និងជាខ្លឹមសារពិតប្រាកដ នៃបដិវត្តន៍សង្គមនិយម និងជាការងារជាក់ស្តែងនៃបដិវត្តន៍សង្គមនិយម ដែលយុវជន-យុវនារីបដិវត្តន៍យើងត្រូវបន្តប្រយុទ្ធអនុវត្តធ្វើឲ្យបានត្រឹមត្រូវទៀងទាត់ និងខ្លាំងក្លាជាប់ជានិច្ច ទើបចលនាបដិវត្តន៍សង្គមនិយមនៅកម្ពុជាយើង បានរឹងប៉ឹងខ្លាំងក្លាជ្រាលជ្រៅ និងក្រហមឆ្អិនឆ្អៅជាប់ជានិច្ច ហើយធានាដល់កិច្ចការប្រទេសជាតិ និងកសាងសង្គមនិយមគ្រប់ផ្នែកនៅកម្ពុជាយើងបានល្អប្រសើរជារៀងរហូតទៅ ។

**ឆេង ខ៊ែង**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន នឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthbunthorn.s@dccam.org*

*Home page: www.d.dccam.org*

# ពិព័រណ៍រូបថតនៅសារមន្ទីរអន្លង់វែង (អតីតផ្ទះតាម៉ុក)

រូបថត១០០សន្លឹក បានចាប់ផ្តើមដាក់តាំងបង្ហាញដល់សាធារណជនជាលើកដំបូងបង្អស់នៅសារមន្ទីរអន្លង់វែង (អតីតផ្ទះតាម៉ុក) នៅថ្ងៃទី១០ ខែធ្នូឆ្នាំ២០១៧ នេះ ក្រោមការរៀបចំរបស់ក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ និងមន្ទីរទេសចរណ៍ស្រុកអន្លង់វែង សហការជាមួយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។ ការតាំងពិព័រណ៍នេះ បានក្លាយជាផ្នែកមួយដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណពីរឿងរ៉ាវ ទីតាំងប្រវត្តិសាស្ត្រ និងការតស៊ូរបស់ប្រជាជននៅក្នុងស្រុកអន្លង់វែង ។ ពិព័រណ៍នេះ ក៏ជាការអប់រំដល់សិស្សានុសិស្ស ប្រជាជន និងភ្ញៀវដែលមកទស្សនកិច្ចនៅតំបន់នេះដែរ ។

រូបថត១០០សន្លឹក បានបង្ហាញពីសម័យកាលផ្សេងៗ ចាប់តាំងពីសម័យសាធារណរដ្ឋខ្មែរ (លន់ នល់), សម័យកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម), សម័យក្រោយខ្មែរក្រហម រហូតមកដល់អន្លង់វែង និងក្រោយពេលសមាហរណកម្ម ។ អ្នកចូលរួមទស្សនាការតាំងពិព័រណ៍នេះ អាចស្វែងយល់ពីសម័យកាលនីមួយៗ តាមរយៈរូបថត និងព័ត៌មានសង្ខេបនៃរូបថតនីមួយៗ ។

លោកស្រី ធិនទី មុនីរស្មី ប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ មានប្រសាសន៍ថា ការដាក់តាំងពិព័រណ៍រូបថតនេះ ពិតជាមានសារសំខាន់ខ្លាំងណាស់ ព្រោះកន្លងមក សារមន្ទីរតាម៉ុក មិនសូវមានព័ត៌មាន ឬ រូបភាពច្រើននោះទេ អ្នកមកទស្សនាអាចត្រឹមតែដើរមើលសម្ភារមួយចំនួនដែលបន្សល់ពីជំនាន់តាម៉ុក គ្រប់គ្រង ប៉ុន្តែមានព័ត៌មានតិចតួចសម្រាប់អាន និងសិក្សាស្វែងយល់ ។ តាមរយៈការតាំងពិព័រណ៍រូបថតប្រវត្តិសាស្ត្រនេះ អ្នកមកទស្សនាអាចស្វែងយល់អំពីរឿងរ៉ាវពីអតីតកាលតាមរយៈរូបថត ហើយជាពិសេស សម្រាប់ក្មេងជំនាន់ក្រោយដែលធ្លាប់តែឮអំពីរបបខ្មែរក្រហម តែមិនដែលស្គាល់មុខមាត់របស់មេដឹកនាំខ្មែរក្រហមមួយចំនួននោះ អាចនឹងឃើញ ឬស្គាល់តាមរយៈរូបថតដែលដាក់តាំងនូវរូបមេដឹកនាំខ្មែរក្រហមទាំងនេះ ។



ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដាក់តាំងពិព័រណ៍រូបថត១០០ នៅសារមន្ទីរអន្លង់វែង (អតីតផ្ទះតាម៉ុក)

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានបង្ហាញពីគោលបំណងក្នុងការដាក់តាំងពិព័រណ៍រូបថតនេះ គឺត្រូវបានធ្វើឡើងដើម្បីបម្រើឲ្យការចងចាំ និងការអប់រំ ដែលអាចជួយលើកកម្ពស់ការយល់ដឹង និងបង្កើតបានជាការឆ្លុះបញ្ចាំងដ៏ស៊ីជម្រៅចំពោះសម័យកាលនោះ ។ ខណៈដែលការដាក់តាំងពិព័រណ៍បាន និងកំពុងក្លាយជារំឭកឡើងវិញអំពីអតីតកាល ពិព័រណ៍នេះក៏ជាភ័ស្តុតាងដាក់ស្តែង ចំពោះព្រឹត្តិការណ៍ ប្រកបដោយសោកនាដកម្ម ដែលប្រជាជនកម្ពុជាបានឆ្លងកាត់ ។ លោកបាន រំឭកថា បន្ទាប់ការធ្វើសមាហរណកម្មរបស់តំបន់អន្លង់វែង នៅក្នុងឆ្នាំ១៩៩៨ ផ្ទះតាម៉ុក ត្រូវបានប្រែក្លាយទៅជាសារមន្ទីរពីរឆ្នាំក្រោយមក ។ ចំណុចចាប់ផ្តើមនៃសារមន្ទីរនេះ គឺ មានត្រឹមតែជាសម្បកផ្ទះរបស់តាម៉ុក ប៉ុណ្ណោះ ប៉ុន្តែគ្មានព័ត៌មានផ្សេងៗនៅឡើយទេ ។ ទោះជាយ៉ាងណាក៏ដោយ សារមន្ទីរនេះបានក្លាយជាទីតាំងដែលមានមនុស្សចូលទស្សនាច្រើនបំផុត បើប្រៀបធៀបទៅនឹងទីតាំងទេសចរណ៍ប្រវត្តិសាស្ត្រចំនួន១៨កន្លែងផ្សេងទៀត នៅក្នុងស្រុកអន្លង់វែង ។ សារមន្ទីរនេះទទួលបានភ្ញៀវចូលទស្សនារាប់ម៉ឺននាក់ក្នុងមួយឆ្នាំៗ ដែលភាគច្រើនគឺជាប្រជាជនកម្ពុជា ។ ដោយសារតែមានភាពចាំបាច់ដើម្បីធ្វើឲ្យសារមន្ទីរនេះមានភាពរស់រវើកឡើងវិញ តាមរយៈការស្វែងយល់ឲ្យកាន់តែគ្រប់ជ្រុងជ្រោយថែមទៀតអំពីប្រវត្តិសាស្ត្រនៃសង្គ្រាម និងសន្តិភាពនៅក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កំពុងបោះមួយជំហានទៅមុខទៀត ក្នុងការដាក់តាំង ពិព័រណ៍រូបថត១០០សន្លឹកនេះ ។

ក្រៅពីការតាំងពិព័រណ៍រូបថតនេះ កន្លងមកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានសហការជាមួយក្រសួងទេសចរណ៍ រៀបចំវគ្គបណ្តុះបណ្តាលដល់មគ្គុទ្ទេសទេសចរណ៍នៅតំបន់អន្លង់វែង ។ វគ្គបណ្តុះបណ្តាលនេះ បានជួយពង្រឹងសមត្ថភាពដល់មគ្គុទ្ទេសទេសចរណ៍ឲ្យយល់ដឹងកាន់តែស៊ីជម្រៅពីតំបន់អន្លង់វែង ដោយធានាថាព័ត៌មានដែលបានផ្តល់ទៅដល់ភ្ញៀវដែលបានមកទស្សនាតំបន់នេះមានភាពច្បាស់លាស់ និងអាចជឿទុកចិត្តបាន ។

ពិព័រណ៍រូបថតនេះ ជាការតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ភ្ញៀវ និងមគ្គុទ្ទេសក៍ទេសចរណ៍ តាមរយៈការជូនភ្ញៀវមកទស្សនានៅសារមន្ទីរនេះ ។ ការតាំងពិព័រណ៍នេះ ក៏ជាការបង្កើតឲ្យមានការពិភាក្សាគ្នាក្នុងចំណោមអ្នកចូលរួម ឪពុកម្តាយ ចាស់ទុំ ឬ មិត្តភ័ក្តិដែលមកទស្សនារូបថតទាំងនេះ ឬក៏អាចសួរនាំមគ្គុទ្ទេសក៍ទេសចរណ៍ដែលអាចផ្តល់ព័ត៌មានបន្ថែមអំពីចម្ងល់ទាំងឡាយអំឡុងពេលមើលរូបថត ។ **ឆាយ សារៈមុនិន្ទ**



ប្រជជនកំពុងទស្សនាការតាំងពិព័រណ៍រូបថត១០០នៅសារមន្ទីរអន្លង់វែង (អតីតផ្ទះតាម៉ុក)

# រូបថតរំឭកពីអតីតកាល

រូបថត១០០សន្លឹក បានសម្ពោធ និងដាក់តាំងជាផ្លូវការ កាលពីថ្ងៃ១០ ខែធ្នូ ឆ្នាំ២០១៧នេះ នៅសារមន្ទីរស្រុកអន្លង់វែង ឬសារមន្ទីរតាម៉ុក (អតីតផ្ទះតាម៉ុក) ។ កម្មវិធីនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម តុប សុភ័ក អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ឯកឧត្តម ប៊ូ សាខន អភិបាលរងខេត្តឧត្តរមានជ័យ លោក ហោ ជិន វិរយុទ្ធ អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង និងអ្នកតំណាងរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធជាច្រើន រួមមាន



ការដាក់តាំងពិព័រណ៍រូបថត១០០សន្លឹក នៅសារមន្ទីរអន្លង់វែង (អតីតផ្ទះតាម៉ុក)

មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ថ្លែងទៅកាន់អ្នកចូលរួម ឯកឧត្តម ប៊ូ សាខនក៏ដូចជា ឯកឧត្តម តុម សុភ័ក បានបង្ហាញពីចំណាប់អារម្មណ៍របស់ខ្លួនចំពោះពិព័រណ៍ និងលើកឡើងដោយសង្ខេបអំពីតំបន់ទេសចរណ៍ដែលមានសក្តានុពលដទៃ ទៀតដែលមានក្នុងស្រុកអន្លង់វែង ។ ជាមួយគ្នានេះ បណ្ឌិត លី សុខឃាង បានបង្ហាញ ពីគោលបំណងក្នុងការដាក់តាំងពិព័រណ៍រូបថត ដែលធ្វើឡើងដើម្បីបម្រើឲ្យការចងចាំ និងការអប់រំ និងជួយលើកកម្ពស់ការយល់ដឹង និងបង្កើតបានជាការឆ្លុះបញ្ចាំងដ៏ស៊ីជម្រៅចំពោះសម័យកាលនោះ ។ ស្របពេលដែលការដាក់តាំងពិព័រណ៍បាន និងកំពុងក្លាយជាការរំឭកឡើងវិញអំពីអតីតកាល ពិព័រណ៍នេះ ក៏ជាភ័ស្តុតាងជាក់ស្តែងចំពោះព្រឹត្តិការណ៍ ប្រកបដោយសោកនាដកម្ម ដែលប្រជាជនកម្ពុជាបានឆ្លងកាត់ ។

តាមរយៈរូបថតដែលដាក់តាំង១០០សន្លឹក ដែលបង្ហាញពីសម័យកាលផ្សេងៗ ចាប់តាំងពីសម័យសាធារណរដ្ឋខ្មែរ (លន់ នល់) , សម័យកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) , សម័យក្រោយខ្មែរក្រហម និងអន្លង់វែង ក្រោយសមាហរណកម្ម ។ អ្នកចូលរួមទស្សនាអាចស្វែងយល់ពីសម័យកាលនីមួយៗតាមរយៈការមើលរូបថតម្តងមួយៗ ជាមួយនឹងព័ត៌មានសង្ខេបនៃរូបថតនីមួយៗ ។

រូបថតប្រវត្តិសាស្ត្រនេះ នឹងក្លាយជាចំណុចពិភាក្សាគ្នារវាង ក្មេងជំនាន់ក្រោយ និងអ្នកដែលធ្លាប់បានរស់នៅ និងសម័យកាលគាត់ទាំងអស់គ្នា ធ្លាប់បានឆ្លងកាត់ ។ អំឡុងពេលមើលរូបថត ក្មេងៗអាចសួរនាំឪពុកម្តាយ ឬចាស់ទុំ អំពីចម្ងល់ផ្សេងៗដែលខ្លួនបានឃើញនៅក្នុងរូបថត ។ ការចែករំលែកបទពិសោធដែលអ្នកជំនាន់មុន ទៅកាន់អ្នកជំនាន់ក្រោយ គឺពិតជាមានសារសំខាន់ខ្លាំងណាស់ ដើម្បីជាការចងចាំ និងអប់រំ ។ ហេតុដូចនេះ តាមរយៈរូបថតប្រវត្តិសាស្ត្រទាំងនេះ ជាមួយនឹងការរៀបរាប់រឿងរ៉ាវពីអ្នកជំនាន់មុនប្រាប់ នឹងកាន់តែធ្វើឲ្យអ្នកជំនាន់ក្រោយយល់កាន់តែច្បាស់នូវព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ជាពិសេស គឺរបបខ្មែរក្រហម ដែលយើងជាអ្នកជំនាន់ក្រោយត្រូវសិក្សាស្វែងយល់ឲ្យច្បាស់ ធ្វើយ៉ាងណាចៀសវាង និងទប់ស្កាត់កុំឲ្យរបបនេះកើតមានឡើងម្តងទៀត ។

បន្ទាប់ពីពិធីសម្ពោធបានបញ្ចប់ អ្នកចូលរួមបានដើរមើលពិព័រណ៍រូបថតដែលបាន ដាក់តាំងជាប់នឹងជញ្ជាំង និងបានផ្តល់ជាទស្សនៈផ្សេងៗគ្នាៈ

**ហាម សុវត្ថិៈ** ជាសមាជិកក្រុមប្រឹក្សាស្រុក បានយល់ឃើញថា ពិព័រណ៍រូបថតនេះ គឺជាការរំឭកឡើងវិញអំពីប្រវត្តិសាស្ត្រ

ដែលបានកន្លងផុតទៅ ។ រូបថតនីមួយៗ បានរំឭកគាត់ឡើងវិញអំពីអតីតកាលដែលបានកប់បាត់ជាច្រើនឆ្នាំមកហើយ ។ ការរំឭកឡើងវិញនេះ ពិតជាមានសារសំខាន់ណាស់ ទាំងជនរងគ្រោះ និងអតីតខ្មែរក្រហម ដើម្បីជាការចែករំលែកបទពិសោធ និងរឿងរ៉ាវផ្សេងៗ ទៅដល់ក្មេងជំនាន់ក្រោយ ។

***ទន់ ឡុតៈ*** ជាអ្នកភូមិគគីរក្រោម បានឲ្យដឹងថា គាត់មកចូលរួមទស្សនាពិព័រណ៍នេះ ព្រោះគាត់ចង់ដឹងថា តើប្រវត្តិសាស្ត្រអាចបង្ហាញឡើងវិញតាមរយៈរូបថតយ៉ាងដូចម្តេច? ជាការពិត បន្ទាប់ពីគាត់បានមើលរូបថតម្តងមួយៗ រូបថតបានរម្លឹកគាត់ឡើងវិញ អំពីការតស៊ូពុះពាររបស់គាត់ ដើម្បីរស់ក្នុងអំឡុងពេលប្រទេសមានសង្គ្រាម ។

***សាត សំអុនៈ*** ជាកសិករនៅភូមិទួលកណ្តាល យល់ថា រូបថតទាំង៤សម័យកាលនេះ បានធ្វើឲ្យគាត់នឹកឃើញអំពីជីវិតពីអតីតកាលរបស់ខ្លួន ដែលជាអតីតកម្មាភិបាលខ្មែរក្រហម ។ សំអុន ក៏បានស្នើសុំឲ្យមានការដាក់តាំងពិព័រណ៍ដូចនេះ នៅថ្ងៃខាងមុខទៀត ។

***សាក់ មានៈ*** ប្រធានភូមិទួលក្រឡា បានបង្ហាញពីអារម្មណ៍របស់គាត់ បន្ទាប់ពីមើលរូបថតនេះថា គាត់ពិតជាចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះពិព័រណ៍រូបថតនេះ ។ ពិព័រណ៍រូបថតនេះ ពិតជាមានសារសំខាន់ណាស់ សម្រាប់ក្មេងជំនាន់ក្រោយ ដើម្បីរៀនសូត្រ ឬស្វែងយល់អំពីអតីតកាលដ៏ឃោរឃៅរបស់របបខ្មែរក្រហម ។ លើសពីនេះទៅទៀត ការដាក់តាំងរូបថត១០០សន្លឹកនៅផ្ទះតាម៉ុក គឺអាចទាក់ទាញការចាប់អារម្មណ៍ច្រើនពីសំណាក់អ្នកទស្សនាជាតិ និងអន្តរជាតិ ។

***ឆាំង ឡុងៈ*** ប្រជាជនរស់នៅភូមិអូរជុំ យល់ថា ពិតជាល្អខ្លាំងណាស់ ដែលមានការដាក់តាំងពិព័រណ៍រូបថតប្រវត្តិសាស្ត្រ ១០០សន្លឹកនេះ ព្រោះវាជាការផ្សព្វផ្សាយ ឬអប់រំទៅកាន់ក្មេងជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយយើងជាអ្នកដែលធ្លាប់ឆ្លងកាត់របបនោះក៏អាចរម្លឹក និងពិភាក្សាគ្នាអំពីបទពិសោធន៍ដែលខ្លួនធ្លាប់បានឆ្លងកាត់ដែរ ។ លើសពីនេះទៀត ការដាក់តាំងពិព័រណ៍រូបថតនេះ នឹងទាក់ទាញភ្ញៀវទេសចរណ៍ច្រើន បង្កើនការងារ និងកាត់បន្ថយភាពក្រីក្រនៅក្នុងសហគមន៍ផង ។

***ផាត រឿៈ*** ប្រជាពលរដ្ឋនៅភូមិអូរចាប់ត្រី បានបង្ហាញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ថា គាត់ពិតជាមានសេចក្តីរីករាយណាស់ ដែលបានមកចូលរួមទស្សនាការតាំងពិព័រណ៍រូបថតប្រវត្តិសាស្ត្រ ទាំង១០០សន្លឹក ព្រោះវាបានរម្លឹកពីអតីតកាលរបស់គាត់ដែលជាអតីតខ្មែរក្រហម និងការរងទុក្ខរបស់ប្រជាជនក្នុងអំឡុងរបបខ្មែរក្រហម ។ រឿ បានឲ្យដឹងថា គាត់បានធ្វើជាទាហានខ្មែរក្រហមចាប់តាំងពីឆ្នាំ១៩៧០ ដល់១៩៩១ម៉្លេះ ហើយសង្គ្រាម ពិតជាធ្វើឲ្យគាត់ហត់នឿយខ្លាំងណាស់ ។

***សាត់ សុផុនៈ*** ប្រធានភូមិអូរក្រញូង ផ្តល់ជាទស្សនៈថា គាត់ពិតជាចាប់អារម្មណ៍ ចំពោះពិព័រណ៍រូបថត ដែលមិនធ្លាប់មានការតាំងបែបនេះពីមុនមកទេ ។ រូបថតទាំង១០០សន្លឹកនេះ បានរម្លឹកការចងចាំរបស់គាត់តាំងពីរបប លន់ នល់ រហូតដល់សមាហរណកម្ម ឆ្នាំ១៩៩៨ ហើយជាពិសេស រូបថតដទៃទៀត បានដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ជាការពន្យល់ទៅកាន់អ្នកទស្សនាដែលជាក្មេងជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។

***សេង សីៈ*** អនុប្រធានភូមិអូរអង្រែ បានចូលរួមពិធីសម្ពោធពិព័រណ៍នេះ ព្រោះគាត់យល់ថា វាមានសារសំខាន់ណាស់ សម្រាប់គាត់ ក៏ដូចជាក្មេងជំនាន់ក្រោយ ដើម្បីជាការរម្លឹកឡើងវិញ អំពីការចងចាំ ។ សម្រាប់ សី ការតាំងពិព័រណ៍រូបថតនេះ មិនត្រឹមតែរម្លឹកគាត់ អំពីការចងចាំអតីតកាលនោះទេ ថែមទាំងជាការប្រមូលផ្តុំនូវរឿងរ៉ាវប្រវត្តិសាស្ត្រនៅសម័យកាលនីមួយៗទៀតផង ។

***ឆាំ សឿនៈ*** កសិកររស់នៅភូមិអូរចាប់ បានចូលរួមពិធីសម្ពោធពិព័រណ៍រូបថត ក្នុងគោលបំណងចង់ដឹងថាការតាំងពិព័រណ៍នេះយ៉ាងដូចម្តេច និងចង់ស្វែងយល់អំពីរឿងរ៉ាវដែលបានកើតឡើងក្នុងអតីតកាល ។ បន្ទាប់ពីបានមើលពិព័រណ៍ សឿន ពិតជាចូលចិត្តការតាំងពិព័រណ៍នេះណាស់ ព្រោះវាត្រូវបានរៀបចំឡើងយ៉ាងរៀបរយ ហើយតាមរយៈរូបថតដែលដាក់តាំងនេះ ក៏ជាសារមួយពីចំណេះដឹងនៃប្រវត្តិសាស្ត្រ ផ្ញើទៅកាន់អ្នកចូលរួមទស្សនា ដែលជាក្មេងជំនាន់ក្រោយ ក៏ដូចជា អ្នកដែលធ្លាប់ឆ្លងកាត់សម័យកាលទាំងនោះ ។

រូបថតទាំងនេះ ក៏បាននាំ សឿន ទៅកាន់អតីតកាលដែលគាត់ធ្លាប់ឆ្លងកាត់ដែរ ។

**ធាច សារៈមុនិន**

# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ កម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យ ជា ស៊ីម ចំរើនរដ្ឋ

នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានបើកវេទិកាថ្នាក់រៀនមួយស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យ ជា ស៊ីម ចំរើនរដ្ឋ ដែលមានសិស្សានុសិស្សចូលរួមសរុប៦៩នាក់ (ប្រុស៣០នាក់) ។ ដំបូងឡើយ វិទ្យាល័យនេះជាឧបសម្ព័ន្ធវិទ្យាល័យឬស្សីកែវ ស្ថិតនៅភូមិស្វាយប៉ាក សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

វេទិកាថ្នាក់រៀននេះ គឺបង្កើតឡើងដើម្បីឲ្យសិស្សានុសិស្សពិភាក្សាគ្នា អំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នូវអ្វីដែលសិស្សទាំងនេះបានដឹង និងធ្លាប់បានរៀនកន្លងមក ។ មិនត្រឹមតែប៉ុណ្ណោះ ក៏មានការដាក់តាំងពិព័រណ៍អំពីសកម្មភាពដែលខ្មែរក្រហមបានជម្លៀសប្រជាជនទាំងបង្ខំទៅតាមទីជនបទដើម្បីធ្វើស្រែចម្ការ ។ ពិព័រណ៍នេះ មានចំនួនសរុប៥ផ្ទាំង និងបានរៀបចំដាក់តាំងមុនរយៈពេលបីថ្ងៃដើម្បីឲ្យសិស្សានុសិស្សមើលទុកជាមុន ដើម្បីផ្តល់នូវចំណេះដឹងខ្លះៗមុនការចូលរួមវេទិកាថ្នាក់រៀននេះ ។ មុននឹងចាប់ផ្តើមកម្មវិធី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំស្លាយដើម្បីចាក់បញ្ចាំងវីដេអូខ្លីមួយ ដែលនិយាយអំពីរបបខ្មែរក្រហម និងចែកសៀវភៅស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សានុសិស្សដែលចូលរួមវគ្គបណ្តុះបណ្តាលនេះ ។

ម៉ោងប្រាំបីកន្លះព្រឹក លោកនាយកសាលាវិទ្យាល័យ ជា ស៊ីម ចំរើនរដ្ឋ បានប្រកាសបើកវគ្គវេទិកាថ្នាក់រៀនេះ និងបាន



សិស្សវិទ្យាល័យ ជា ស៊ីម ចំរើនរដ្ឋ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

និយាយអំពីសារសំខាន់នៃការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងបានរម្លឹកអំពីអតីតកាលរបស់គាត់អំឡុងឆ្នាំ ១៩៧៥-១៩៧៩ ។ លោកនាយកសាលា មានឈ្មោះ ឌី ទេព កោសល្យ អាយុ៤៩ឆ្នាំ គាត់បានរៀបរាប់អំពីរឿងរ៉ាវខ្លះៗ ក្នុងរបបខ្មែរក្រហមដែលគាត់ធ្លាប់បានឆ្លងកាត់កន្លងមក ។ នៅឆ្នាំ ១៩៧៧ ទេព្យកោសល្យ មានអាយុប្រហែល១២ឆ្នាំ អង្គការបានចាត់តាំងគាត់ឲ្យមើលក្របី ។ នាយប់មួយ ក្របីរបស់គាត់បានដាច់ចំណង ហើយបានរត់ចេញពីក្រោល ពេលនោះគាត់បានដើររកក្របីទាំងយប់ មួយសន្ទុះក្រោយមកគាត់ក៏បានឃើញក្របីរបស់គាត់ ហើយបានដឹកវាត្រឡប់មកវិញ ។ ពេលនោះ មានសមមិត្តដែលរស់នៅក្បែរគ្នា បាននិយាយប្រាប់គាត់ថា ឪពុករបស់គាត់ត្រូវបានខ្មែរក្រហមយកទៅរៀនសូត្រហើយ (សម្លាប់) ស្របពេលដែល ទេព្យកោសល្យ ឯងទៅរកក្របី ។ ប៉ុន្តែ ទេព្យកោសល្យ បែរជាគិតថា វាជាសំណាងល្អរបស់គាត់ដែលក្របីបានដាច់ចំណង ទើបគាត់បានរួចផុតជីវិត ពីព្រោះពេលនោះ ប្រសិនបើ ទេព កោសល្យ នៅជាមួយឪពុករបស់គាត់ ច្បាស់ជាអង្គការយកទៅសម្លាប់ចោលទាំងពីរនាក់ជាពុំខាន ។ បង្វែរមកវិញ ទេព្យកោសល្យ បាននិយាយទៅកាន់សិស្សរបស់គាត់ថា ការរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពិតជាមានសារសំខាន់ខ្លាំងណាស់ ព្រោះវាជាអតីតកាលដ៏ជូរចត់មួយ ដែលសិស្សទាំងអស់ត្រូវយល់ដឹងអំពីរបបនេះឲ្យបានច្បាស់ ដើម្បីកុំឲ្យកើតមានឡើងសាជាថ្មី ។

ទាវ លីលី ជាសិស្សថ្នាក់ទី១២A1 រៀននៅវិទ្យាល័យ ជា ស៊ីម ចំរើនរដ្ឋ បានរៀបរាប់ថា ពីដំបូងឡើយ គាត់ធ្លាប់បានឮពីសម័យខ្មែរក្រហម តាមរយៈឪពុកម្តាយរបស់គាត់ ដែលបានប្រាប់អំពីរឿងរ៉ាវដែលកើតឡើងក្នុងសម័យកាលនោះ ។ ពេលនោះ លីលី មានអារម្មណ៍ថា ស្អប់របបនោះយ៉ាងខ្លាំង ប៉ុន្តែក្រោយ លីលី បានសិក្សាអំពីរបបខ្មែរក្រហម នៅក្នុងថ្នាក់រៀនរបស់ខ្លួនផ្ទាល់ ជាពិសេសថ្ងៃនេះ ដែលបានមានឱកាសចូលរួមវេទិកាថ្នាក់រៀនអំពីរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឲ្យ លីលី យល់ដឹងកាន់តែច្បាស់ ហើយមិនមានគំនិតស្អប់ ឬមិនចង់សិក្សាអំពីប្រវត្តិសាស្ត្រនេះទេ ផ្ទុយទៅវិញ លីលី យល់ដឹងបានច្រើនពីរបបខ្មែរក្រហមតាមរយៈការចូលរួមវេទិកាថ្នាក់រៀននេះ ។ អ្វីដែលពិសេសទៀតនោះ នៅពេលដែល លីលី បានមើលការតាំងពិព័រណ៍អំពីរូបភាពដែលខ្មែរក្រហមជម្លៀសប្រជាជន ហាក់បីដូចធ្វើឲ្យ លីលី ស្ថិតនៅក្នុងសកម្មភាពជាក់ស្តែងមួយនៃរបបខ្មែរក្រហម និងធ្វើឲ្យគាត់មានអារម្មណ៍សង្វេគយ៉ាងពន់ពេក ។

ប្រាក់ សោភា រៀនថ្នាក់ទី១២B2 នៅវិទ្យាល័យ ជា ស៊ីម ចំរើនរដ្ឋ បាននិយាយអំពីសារសំខាន់នៃការរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យថា ប្រវត្តិសាស្ត្ររបស់ជាតិខ្លួនផ្ទាល់ គឺមិនត្រូវបំភ្លេចនោះទេ ទោះបីជាប្រវត្តិសាស្ត្រល្អ ឬមិនល្អក្តី គឺយើងត្រូវសិក្សាអំពីវាឲ្យបានច្បាស់ ជាពិសេសរបប ប៉ុល ពត ដែលជាប្រវត្តិសាស្ត្រដ៏សាហាវយង់ឃ្នង និងព្រៃផ្សៃដែលប្រជាជនខ្មែរទូទៅមានអារម្មណ៍ដក់ជាប់នៅក្នុងចិត្តជានិច្ច ។ សោភា បានបន្ថែមថា នៅពេលដែលបានរៀនប្រវត្តិសាស្ត្រនៅថ្ងៃនេះ គឺធ្វើឲ្យគាត់បានដឹងកាន់តែច្បាស់អំពីឈ្មោះថ្នាក់ដឹកនាំក្នុងសម័យកាលនោះ និងគោលនយោបាយដែលខ្មែរក្រហមបានប្រព្រឹត្ត ។ សោភា បានបន្តថា ប្រសិនបើគាត់ទទួលបានចំណេះដឹងពីប្រវត្តិសាស្ត្រនេះកាន់តែច្រើន គាត់នឹងចែករំលែកទៅកាន់សិស្សប្អូនរបស់គាត់ ដែលរៀននៅក្នុងវិទ្យាល័យជាមួយគ្នា ដើម្បីជាគន្លឹះសម្រាប់ប្រឡងទុតិយភូមិ ដែលជាវិញ្ញាសារធ្លាប់បានចេញកន្លងមក ។

សោភា បានបញ្ជាក់ថា ការរៀនប្រវត្តិសាស្ត្រនេះ គឺបានផ្តល់អត្ថប្រយោជន៍សម្រាប់ខ្លួនគាត់ផ្ទាល់ នៅពេលដែលគាត់ប្រឡងតែងសេចក្តី គាត់បានលើកយកផលអវិជ្ជមានដែលកើតឡើងពីរបបនោះ មកធ្វើការប្រៀបធៀបនឹងសម័យកាលបច្ចុប្បន្នថា តើវាមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេច ។ អ្វីដែល សោភា ចាប់អារម្មណ៍ទៀត គឺរូបភាពតាំងពិព័រណ៍ ដែលបានឆ្លុះបញ្ចាំងអំពីសម័យអតីតកាល និងមានអក្សរដែលសរសេរបញ្ជាក់អំពីព្រឹត្តិការណ៍នោះម្យ៉ាងទៀតមានក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជួយចង្អុលបង្ហាញនូវចម្ងល់ទាំងឡាយដែល សោភា មានការងឿងឆ្ងល់ធ្វើឲ្យ សោភា កាន់តែយល់ច្បាស់ឡើង ។

ជាចុងបញ្ចប់ សោភា សំណូមពរ ថា ចង់ឲ្យមានវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្របែបនេះតទៅទៀត ដើម្បីកុំឲ្យសិស្សានុសិស្ស ឬក្មេងជំនាន់ក្រោយបំភ្លេចនូវប្រវត្តិសាស្ត្រមួយនេះ ។

**ហ៊ូ ថុនា**

# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវ
# នៅវិទ្យាល័យ ជា ស៊ីម ចំរើនរដ្ឋ ក្នុង









# វត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)
# ក្រុងភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧










*ប្រវត្តិរឿងរ៉ាវចេញពីភូមិ*

# ពិធីសំពះផ្ទឹមក្នុងព្រះវិហារនៅឃុំវិហារសួគ៌

## សេចក្តីផ្តើម

ទំនៀមទម្លាប់ប្រពៃណីរបស់ប្រទេសនីមួយៗ នៅក្នុងពិភពលោកតែងតែមានភាពខុសគ្នាទៅតាមបរិបទនៃជំនឿ ការឲ្យតម្លៃ និងការវិវត្តន៍របស់សង្គមជាតិនោះ ។ តួយ៉ាង ទំនៀមទម្លាប់នៃកិច្ចរៀបអាពាហ៍ពិពាហ៍ក្នុងប្រទេសខ្លះមិនដូចគ្នានោះទេ ។ ឧទាហរណ៍ ប្រទេសកម្ពុជាមានការប្រារព្ធពីធីកាត់សក់ក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍ រីឯប្រទេសខ្លះដូចជាចិនជាដើម មិនមានពីធីនេះឡើយ ។

ពិធីអាពាហ៍ពិពាហ៍ គឺជាទំនៀមទម្លាប់ប្រពៃណីមួយដ៏សំខាន់សម្រាប់ប្រជាជនខ្មែរ ។ ខ្មែរឲ្យតម្លៃទៅលើការរៀបអាពាហ៍ពិពាហ៍របស់កូនប្រុសកូនស្រី ស្មើនឹងការបានបំពេញមុខបំពេញមាត់ដល់គ្រួសារ ។ បើមានកូនប្រុសកូនស្រីណា មិនបានបំពេញការតព្វកិច្ចនៃកិច្ចរៀបអាពាហ៍ពិពាហ៍ទេ អ្នកជិតខាងដែលដឹងរឿងនោះ ពិតជាមានការរើសអើង ពេបជ្រាយទៅដល់គ្រួសារនោះថាបុត្រាបុត្រីនៃគូស្វាមីភរិយា "ជាកូនឥតខាន់ស្លា" ជាដើម ។ ដូច្នេះ តើពាក្យអាពាហ៍ពិពាហ៍មានន័យយ៉ាងដូចម្តេចនៅក្នុងសង្គមខ្មែរ?

យោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត បានពន្យល់ថា ពាក្យអាពាហ៍ពិពាហ៍ គឺជាភាសាសំស្ក្រឹត បាលីថា អាវាហ វិវាហ ។ អាវាហ មានន័យថា នាំមក ចំណែក វិវាហ មានន័យថា នាំត្រឡប់ទៅ ។ តាមអធិប្បាយក្នុងគម្ពីរកែសព្ទថា ការនាំកូនស្រីមកខាងលំនៅកូនប្រុស ហៅថា អាវាហ (អាពាហ៍) រីឯការនាំកូនប្រុសត្រឡប់ទៅខាងលំនៅកូនស្រីវិញ ហៅថា វិវាហ (ពិពាហ៍) ។ ដូច្នេះយើងឃើញថា អាពាហ៍ពិពាហ៍ គឺជាការនាំកូនស្រីទៅរៀប



ពិធីរៀបអាពាហ៍ពិពាហ៍ នៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

មង្គលការនៅផ្ទះខាងកូនប្រុស ហើយនាំកូនប្រុសទៅរៀបមង្គលការនៅផ្ទះខាងកូនស្រីវិញ ។ ទោះជាយ៉ាងដូច្នេះក៏ដោយ យើងសង្កេតឃើញថា ការរៀបមង្គលការនៅស្រុកខ្មែរ គឺភាគច្រើនកូនប្រុសត្រូវនាំទៅរៀបការនៅផ្ទះខាងកូនស្រី ។ នេះក៏ដោយសារទំនៀមទម្លាប់ប្រពៃណីខ្មែរបានឲ្យតម្លៃខ្ពស់ទៅលើកូនស្រី ពោលគឺសង្គមខ្មែរ មានរបៀបគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ (តាំងពីជំនាន់ព្រះនាង លីវ យី) គឺរបបលើកស្ត្រីធ្វើជាធំ ជាអ្នកដឹកនាំសង្គម ជាអ្នកគ្រប់គ្រងកិច្ចការ ដូច្នេះបានជាយើងមានច្បាប់ជាច្រើន អប់រំស្ត្រីឲ្យមានសីលធម៌ខ្ពង់ខ្ពស់ មានភាពឧត្តុង្គឧត្តម និងមានភាពល្អបរិសុទ្ធ ។ ការឲ្យតម្លៃទៅលើស្ត្រីបែបនេះ តម្រូវឲ្យបុរសចូលស្តីដណ្តឹង សុំសេចក្តីយល់ព្រមពីឪពុកម្តាយខាងស្រីជាមុនសិន ។ ដូច្នេះ តើអាពាហ៍ពិពាហ៍ខ្មែរដើមកំណើតមកពីណា?

ទស្សនៈជាច្រើនបានលើកឡើងខុសៗគ្នាអំពីដើមកំណើតនៃការរៀបអាពាហ៍ពិពាហ៍របស់ខ្មែរ ។ សៀវភៅរបស់អ្នកស្រី ត្រឹង ងា (១៩៧៥) បានសរសេររៀបរាប់ពីការយល់ឃើញរបស់ប្រជាជនខ្មែរថា ៖ ពិធីមង្គលការរបស់ខ្មែរអាចយកលំនាំតាមពិធីមង្គលការរវាងព្រះរាម និងនាងសីតារបស់មហាឫសីមិថិលា ឬធ្វើតាមពិធីរៀបអភិសេករបស់ព្រះថោង និងនាងនាគ ឬយកគំរូតាមព្រះវេស្សន្តរ កាលទ្រង់រៀបអភិសេកចៅក្រីស្នា និងនាងជាលី ។ ចំណែកលោក ម៉ម ប៊ុណ្ណា បានលើកឡើងថា មនុស្សចេះរៀបចំធ្វើអាពាហ៍ពិពាហ៍ តាំងពីមនុស្សចេះអៀនខ្មាស់ ចេះស្រឡាញ់កិត្តិយស ដោយសម្អាងលើរឿងព្រេងក្នុងព្រហ្មញ្ញសាសនា ។

ទស្សនៈខាងលើហាក់ធ្វើឲ្យមានភាពស្រពិចស្រពិលនៃដើមកំណើតអាពាហ៍ពិពាហ៍ខ្មែរដដែល ។ ប៉ុន្តែ ប្រសិនបើក្រឡេកមើលប្រវត្តិសាស្ត្រនៃការមកដល់របស់ព្រាហ្មណ៍កោណ្ឌិន្យ និងព្រះនាងសោមា (នាងនាគ ឬលីវយី) ជាស្ត្រីខ្មែរ ដែលបានប្រារព្ធពិធីមង្គលការមុនដំបូងបង្អស់នៅលើទឹកដីខ្មែរ ហើយដើម្បីរំឭកនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ ប្រជាជនខ្មែរបានប្រារព្ធពិធីព្រះថោងនាងនាគ ។ ដូច្នេះយើងអាចសន្និដ្ឋានថា ដើមកំណើតអាពាហ៍ពិពាហ៍ខ្មែរ អាចយកលំនាំតាមរឿងព្រេងព្រះថោង និងនាងនាគ ច្រើនជាងអំណះអំណាងដទៃ ។

អាពាហ៍ពិពាហ៍ខ្មែរមានការវិវត្តទៅតាមសម័យកាលនីមួយៗ គឺការវិវត្តនេះត្រង់ចំនួនថ្ងៃនៃការប្រារព្ធពិធីមង្គលការរួមមាន ការប្រារព្ធអាពាហ៍ពិពាហ៍រយៈពេល៧ថ្ងៃ៧យប់ ៣ថ្ងៃ៣យប់ ២ថ្ងៃ១យប់ និង១ថ្ងៃ១ព្រឹក ជាដើម ។ ការវិវត្តនេះ គឺអាស្រ័យទៅលើការនិយមរបស់ប្រជាជនខ្មែរ ដោយគិតអំពីធនធាន និងពេលវេលាដែលគ្រួសារនីមួយៗមានការវិវត្តន៍នៃជំនឿក្នុងការប្រារព្ធពីធីនីមួយៗ និងព្រឹត្តិការណ៍នានាដែលកើតមានឡើងក្នុងសង្គមជាតិ ដែលតម្រូវឲ្យសហគមន៍គ្រួសារនីមួយៗកាត់បន្ថយចំនួនថ្ងៃជាដើម ។ ជាក់ស្តែង នៅចុងសម័យសាធារណរដ្ឋខ្មែរ ដែលកម្លាំងទ័ពព្រៃបានហ៊ុមព័ទ្ធទីជនបទ និងខេត្តមួយចំនួន ការប្រារព្ធពិធីរៀបអាពាហ៍ពិពាហ៍ បានកាត់បន្ថយនៅសល់ត្រឹមតែ ១ព្រឹក ប៉ុណ្ណោះ ។ ការរៀបអាពាហ៍ពិពាហ៍ខ្លះ មានលក្ខណៈជារបៀបសែនព្រេន ដែលកម្មវិធីប្រព្រឹត្តទៅនៅវេលាព្រឹក ដោយគ្រាន់តែហែកូនកំលោះចូលរោងអាពាហ៍ពិពាហ៍ ហើយកូនក្រមុំចេញមករៀបចំសំពះផ្ទឹមចងដៃ បាចផ្កាស្លា រួចគោងស្បៃចូលបន្ទប់តែម្តង ។ បន្ទាប់មក ភ្ញៀវកិត្តិយសអញ្ជើញចូលរួមពិធីលៀងភោជនីហារ និងបញ្ចប់កម្មវិធីនៅម៉ោងប្រហែល១២ថ្ងៃត្រង់ ។

បើយោងតាមសៀវភៅលំអានទំនៀមខ្មែរបុរាណដែលរៀបរៀងដោយលោក ញាណ ភឿន និងលោក ម៉ម ឆៃ (២០០៥) ការប្រារព្ធពិធីនីមួយៗក្នុងអាពាហ៍ពិពាហ៍ខ្មែរ ចែកចេញជាពីរដំណាក់កាល គឺ មុនថ្ងៃរៀបការ និងក្នុងថ្ងៃរៀបការ ដែលដំណាក់កាលទាំង២ នេះមានដូចជា ៖

១) ពិធីមុនការរៀបមង្គលការ មានរៀបចំដូចជាៈ

- ◆ ពិធីចែចូវ
- ◆ ពិធីស្តីដណ្តឹង

២) ពិធីក្នុងថ្ងៃរៀបមង្គលការមានដូចជាៈ

- ◆ ពិធីសែនក្រុងពាលី
- ◆ ពិធីសូត្រមន្ត
- ◆ ពិធីស្តីដណ្តឹង (សង្ខេប)
- ◆ ពិធីហែកំណត់
- ◆ ពិធីកាត់ផ្កាស្លា
- ◆ ពិធីកាត់សក់
- ◆ ពិធីសែនគួចដៃ (សែនចងដៃ)

◆ ពិធីធ្វើធ្មេញ
◆ ពិធីយកវេលា
◆ ពិធីផ្ទឹម និង
◆ ពិធីផ្សំដំណេក ។

មង្គលការខ្មែរមានការរៀបចំពិធីជាច្រើន ដែលពិធីទាំងនោះសុទ្ធសឹងតែមានតម្លៃក្នុងប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនខ្មែរ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពិធីមង្គលការនៅក្នុងប្រទេសកម្ពុជាបានធ្វើឡើងក្នុងទម្រង់ផ្សេងគ្នា អាស្រ័យលើវប្បធម៌ និងជំនឿ ដើម្បីយល់ដឹងឲ្យកាន់តែស៊ីជម្រៅថែមទៀតពីអ្វីដែលបានរៀបរាប់ខាងលើអ្នកនិពន្ធសូមលើកយកពិធីមួយ ដែលជាពិធីហែកូនប្រុស កូនស្រី ទៅសំពះផ្ទឹមនៅក្នុងព្រះវិហារ ដែលកើតចេញពីវប្បធម៌ និងជំនឿរបស់អ្នកភូមិក្នុងឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលមកធ្វើការសិក្សា ។ ប្រជាជនមួយចំនួនក្នុងឃុំវិហារសួគ៌បានហៅពិធីនេះថា "ពិធីបន្ត្រប់លក្ខណ៍" ឬ "ពិធីបន់ស្រន់" ។ ការហៅខុសគ្នានេះ គឺសម្អាងទៅលើរឿងរ៉ាវជាប់ពាក់ព័ន្ធក្នុងពិធីមង្គលការនេះ ដែលចាស់ព្រឹទ្ធាចារ្យក្នុងភូមិនិយាយតៗគ្នា ។

អត្ថបទស្រាវជ្រាវនេះនឹងឆ្លើយនៅនឹងសំណួរមួយចំនួនរួមមាន ៖ តើពិធីសំពះផ្ទឹមជាអ្វី មានរណ្ដាប់ និងរបៀបរៀបចំយ៉ាងដូចម្ដេច? តើមូលហេតុអ្វីបានជាចាំបាច់មានការដង្ហែកូនកំលោះកូនក្រមុំទៅវត្តនៅថ្ងៃមង្គលការក្នុងឃុំវិហារសួគ៌? តើពិធីដង្ហែកូនកំលោះកូនក្រមុំទៅវត្តនេះ មានរឿងរ៉ាវយ៉ាងដូចម្ដេច ព្រមទាំងមានការផ្លាស់ប្ដូរយ៉ាងណាខ្លះពីសម័យសង្គមរាស្ត្រនិយម រហូតមកដល់បច្ចុប្បន្ន?

តាមរយៈការសិក្សាស្រាវជ្រាវលើប្រវត្តិដែលសំពះផ្ទឹមក្នុងព្រះវិហារក្នុងឃុំវិហារសួគ៌ អ្នកនិពន្ធសង្ឃឹមថា អត្ថបទស្រាវជ្រាវនេះនឹងរួមចំណែកក្នុងការបំពេញបន្ថែមនូវភាពចន្លោះប្រហោងនៃពិធីមង្គលការក្នុងប្រទេសកម្ពុជា ដើម្បីផ្ដល់ជាចំណេះដឹងបន្ថែមដល់ក្មេងជំនាន់ក្រោយឲ្យបានដឹងពីសារសំខាន់នៃពិធីរឿងរ៉ាវ រណ្ដាប់ ក៏ដូចជារបៀបរៀបចំពិធីសំពះផ្ទឹម (បន្ត្រប់លក្ខណ៍ ឬបន់ស្រន់) ដែលអ្នកឃុំវិហារសួគ៌ប្រណិប័តនៅក្នុងពិធីរៀបមង្គលការខ្មែរ និងជួយថែរក្សាកុំឲ្យបាត់បង់ ព្រមទាំងដើម្បីស្វែងយល់អំពីការវិវត្តរបស់ពិធីនេះពីសម័យសង្គមរាស្ត្រនិយម រហូតមកដល់បច្ចុប្បន្ន ។

ជាសរុប អត្ថបទស្រាវជ្រាវនេះនឹងពិភាក្សាទៅលើពិធី


វត្តព្រះវិហារសួគ៌ នៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល

សំពះផ្ទឹម (បន្ត្រប់លក្ខណ៍ ឬបន់ស្រន់) ក្នុងព្រះវិហារ រឿងរ៉ាវទាក់ទងនឹងពិធីសំពះផ្ទឹម រណ្ដាប់ក្នុងពិធី របៀបនៃការដង្ហែកូនកំលោះកូនក្រមុំទៅសំពះផ្ទឹមក្នុងព្រះវិហារ របៀបរៀបចំរណ្ដាប់ និងរបៀបសំពះផ្ទឹមក្នុងព្រះវិហារ ជំនឿផ្សេងៗក្នុងពិធីសំពះផ្ទឹម និងការប្រែប្រួលនៃពិធីសំពះផ្ទឹមក្នុងសម័យកាលនីមួយៗ ដែលឆ្លើយតបទៅនឹងគោលបំណង និងសំណួរស្រាវជ្រាវរបស់អ្នកនិពន្ធ ។

## ពិធីសំពះផ្ទឹមក្នុងព្រះវិហារ

ជាទូទៅនៅក្នុងសង្គមខ្មែរ ការប្រារព្ធពិធីទំនៀមទម្លាប់អ្វីមួយហាក់ដូចជាមានភាពខុសប្លែកគ្នាពីតំបន់មួយទៅតំបន់មួយ ។ ពិធីសំពះផ្ទឹមក្នុងព្រះវិហារនៅក្នុងថ្ងៃរៀបមង្គលការ ដែលអ្នកឃុំវិហារសួគ៌ប្រណិប័តន៍ គឺមិនមានការសរសេរចងក្រងនៅក្នុងក្រុមប្រពៃណីទំនៀមទម្លាប់អាពាហ៍ពិពាហ៍ខ្មែរឡើយ ។ ជាងនេះទៅទៀត ពិធីនេះមានតែអ្នកឃុំវិហារសួគ៌ទេដែលប្រារព្ធធ្វើ ។ បើតាមសម្ដីអ្នកស្រី យុន សុខណាង អាយុ៥៥ឆ្នាំ រស់នៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ការប្រារព្ធធ្វើពិធីសំពះផ្ទឹមមានតាំងពីយូរយារណាស់មកហើយ ។ អ្នកភូមិគ្រប់គ្នាតែងតែនាំកូនកំលោះកូនក្រមុំទៅវត្តនៅថ្ងៃរៀបអាពាហ៍ពិពាហ៍ ។ លោកតា ភោគ យឿន អាយុ៦៦ឆ្នាំ នៅភូមិតាកែវ២ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល បានអះអាងស្រដៀងគ្នាដែរថា ពិធីនេះមានយូរយារណាស់មកហើយ ហើយក៏មិនដឹងថាមានកំណើតតាំងពីពេលណាមកដែល ព្រោះថាប្រជាជនក្នុងភូមិតែងតែប្រារព្ធពធីនេះជារៀងរហូតមក ពោលគឺអ្នកភូមិនាំគ្នាហែកូនកំលោះកូនក្រមុំទៅវត្ត ដើម្បីសុំសេចក្ដីសុខ និងសេចក្ដីចម្រើនពីបារមីរបស់ព្រះអង្គវត្តព្រះវិហារសួគ៌ ។ ជាងនេះទៅទៀត លោកតាអាចារ្យខាងពេលា យិន សុខ អាយុ៧០ឆ្នាំ នៅភូមិវិហារសួគ៌ត្បូង ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល មានប្រសាសន៍ថា កិច្ចដង្ហែកូនកំលោះកូនក្រមុំទៅវត្តក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍ត្រូវបានប្រជាជនឃុំវិហារសួគ៌ប្រារព្ធអស់កាលរាប់ទសវត្សរ៍កន្លងមកហើយ សូម្បីតែឪពុកម្ដាយរបស់គាត់ក៏មិនបានដឹងថា ពិធីនេះកើតឡើងតាំងពីពេលណានោះមកដែរ ។

ចាស់ព្រឹទ្ធាចារ្យនៅក្នុងភូមិឯទៀត ក៏ដូចជាអាចារ្យ និងព្រះសង្ឃបានឲ្យដឹងថា ការដង្ហែកូនកំលោះកូនក្រមុំមកវត្តគឺមិនមែនមានតែអ្នកឃុំវិហារសួគ៌ប្រណិប័តន៍ប៉ុណ្ណោះទេ តាំងពីដើមរៀងមក (សម័យសង្គមរាស្ត្រនិយម) ពោលគឺប្រជាជនដែលរស់នៅឃុំសន្លុងក៏ធ្លាប់ ដង្ហែកូនកំលោះកូនក្រមុំមកវត្តវិហារសួគ៌ដែរ (ឃុំសន្លុងមានព្រំប្រទល់ជាប់នឹងឃុំវិហារសួគ៌) ។ កាលនោះ ប្រជាជននៅឃុំសន្លុងដង្ហែដោយថ្មើរជើង និងមានមនុស្សជាច្រើនហែមកជាមួយដែរ ។ ប៉ុន្តែ សព្វថ្ងៃនេះ ប្រជាជនដែលរស់នៅក្នុងឃុំសន្លុងហាក់មិនសូវប្រណិប័តន៍ពិធីនេះដូចពីដើមឡើយ ។ ផ្ទុយទៅវិញ ប្រជាជននៅឃុំវិហារសួគ៌ដែលរៀបចំពិធីមង្គលការកូន គឺកម្រនឹងកាត់ពិធីដង្ហែកូនកំលោះកូនក្រមុំមកវត្តក្នុងថ្ងៃរៀបមង្គលការចោលណាស់ ។

ជាទំនៀមទម្លាប់ បើយោងតាមការលើកឡើងរបស់លោកតាអាចារ្យ សុខ ការដង្ហែកូនកំលោះកូនក្រមុំមកវត្ត អាចមានចំនួនរហូតបីដងទៅតាមម្ចាស់ដើមការ ចាស់ព្រឹទ្ធាចារ្យ និងឪពុកម្ដាយកូនកំលោះកូនក្រមុំជាអ្នកចាត់ចែង ពោលគឺថ្ងៃសូត្រមន្តពេលល្ងាចម្ដង ថ្ងៃមង្គលការម្ដង និងថ្ងៃបញ្ចប់ពិធីរៀបអាពាហ៍ពិពាហ៍ម្ដងទៀត ។ មានកូនកំលោះកូនក្រមុំមួយចំនួនមិនបានអនុវត្តក្នុងការដង្ហែទៅវត្តនៅក្នុង ថ្ងៃទីមួយ និងថ្ងៃទីបីនោះឡើយ ដោយសារពេលវេលា និងជីវភាពគ្រួសារ ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ថ្ងៃទីពីរវិញ ចាំបាច់ត្រូវដង្ហែកូនកំលោះកូនក្រមុំទៅវត្ត ។ ដូច្នេះ យើងឃើញថា ពិធីសំពះផ្ទឹមកូនកំលោះកូនក្រមុំនៅក្នុងព្រះវិហារពិតជាមានសារសំខាន់ណាស់សម្រាប់ប្រជាជនដែលរស់នៅក្នុងឃុំវិហារសួគ៌ ពីព្រោះប្រជាជនជឿថា ការប្រារព្ធពិធីបែបនេះនឹងទទួលបានសេចក្ដីសុខ សេចក្ដីចម្រើន និងសុភមង្គលដល់កូនកំលោះកូនក្រមុំ ។ ការប្រារព្ធពិធីនេះហាក់បង្ហាញពីការប្រណិប័តន៍ទំនៀមទម្លាប់តៗគ្នា ដែលជាផ្នែកមួយឆ្លុះបញ្ចាំងឲ្យឃើញអំពីការថែរក្សាប្រពៃណីខ្មែរ ។

## រឿងរ៉ាវទាក់ទងពិធីសំពះផ្ទឹមក្នុងព្រះវិហារ (បន្ត្រប់លក្ខណ៍ ឬពិធីបន់ស្រន់)

នៅក្នុងអាពាហ៍ពិពាហ៍ខ្មែរ ការប្រារព្ធពិធីអ្វីមួយគឺតែងមានរឿងរ៉ាវទាក់ទងនឹងប្រវត្តិនៃពិធីនោះ ។ តួយ៉ាង រឿងរ៉ាវទាក់ទងនឹងពិធីកាត់សក់កូនប្រុសស្រីក្នុងថ្ងៃមង្គលការដែលមានដំណាលថា៖

កាលពីព្រេងនាយ មានមហាសេដ្ឋីម្នាក់ បានប្រារព្ធពិធីរៀបមង្គលការកូនស្រីរបស់ខ្លួន ។ គ្រានោះ ចាតុម្មហារាជ (សម្ដេច

ទេវតាទាំង៤អង្គ ដែលរក្សាទិសទាំងបួន) នៅឯឋានសួគ៌ បានបើកទិព្វចក្ខុមើលមកឋានមនុស្សលោកនៅឯដែនដី ហើយទតឃើញមហាសេដ្ឋីកំពុងប្រារព្ធពិធីរៀបមង្គលការ ។ ចាតុម្មហារាជក៏បានបញ្ជូនវិស្សុកម្មទេវបុត្រពីរអង្គ មួយអង្គជាខ្វាន់ព្រះកេសា (ជាងកាត់សក់) និងមួយអង្គទៀតជាអ្នកសម្អាងកាយ ឲ្យចុះមកកាន់ដែនដីដើម្បីលក់កន្ត្រៃទិព្វ និងក្រាសទិព្វទៅឲ្យមហាសេដ្ឋីនោះ ។ កន្ត្រៃ និងក្រាសទិព្វ អាចនាំលាភសក្ការ ភ័ព្វសំណាង និងដំណឹងល្អដល់មនុស្សលោកឲ្យរស់នៅដោយសន្តិភាព សុភមង្គល និងវិបុលសុខ ។ យើងអាចមើលឃើញវិស្សុកម្មទេវបុត្រទាំងពីរប្រកបដោយសម្លៀកបំពាក់ស្រស់ឆើតឆាយ និងទ្រពានកន្ត្រៃ និងក្រាស់ទិព្វជាប់នឹងដៃ ។ មហាសេដ្ឋីចង់បានកន្ត្រៃ និងក្រាសទិព្វនេះខ្លាំងណាស់ លោកក៏ស្នើសុំឲ្យវិស្សុកម្មទេវបុត្រទាំងពីរកាត់សាកមើល មុននឹងជាវវត្ថុទិព្វទាំងពីរនោះ ។ វិស្សុកម្មទេវបុត្រទាំងពីរ ក៏យល់ព្រមតាមសំណូមពរលោកសេដ្ឋី ហើយក៏បង្ហាញថ្វីដៃឲ្យឃើញដូចចិត្ត ។ ទេវបុត្រទាំងពីរមាននាទីជាអ្នកចម្រៀងផង ជាអ្នកកាត់សក់ផង និងជាអ្នកតុបតែងមុខផង ។ អ្នកទាំងពីរច្រៀងចម្រៀងសារិកាកែវបណ្តើរ ហើយកាត់សក់កូនប្រុសស្រីបណ្តើរ ។ កាត់សក់រួច អ្នកទាំងពីរក៏នាំកូនប្រុសស្រីទៅងូតទឹកជំរះកាយក្នុងត្រពាំង (ពាយ) ដ៏ថ្លាឆ្វង់ និងត្រជាក់ល្ហឹម អមជាមួយការច្រៀងចម្រៀងបទត្រពាំងពាយដោយងូតទឹកជម្រះកាយបណ្តើរ និងបាចទឹកដាក់សាមីខ្លួនទាំងពីរបណ្តើរ ។ អត្ថន័យនៃចម្រៀងនីមួយៗ គឺដើម្បីអង្វរក និងបណ្តេញឧបទ្រពចង្រៃ ព្រមទាំងព្រាយបិសាចឲ្យចេញឆ្ងាយពីសាមីខ្លួនទាំងពីរ ដូចជាការងូតទឹកដុសក្អែលឲ្យជ្រះស្រឡះចេញអំពីកាយ ដូច្នេះឯង ។ វិស្សុកម្មទេវបុត្រទាំងពីរកំប្លែងលេងសើចជាមួយនឹងសាមីខ្លួនដូចជាមិត្តសម្លាញ់យ៉ាងស្និទ្ធស្នាលបំផុត ។ មហាសេដ្ឋីភ្ញាក់ស្រឡាំងកាំងពេលបានឃើញបុត្រី និងកូនប្រសារប្រែទៅល្អដូចជាព្រះរាជា ។ មហាសេដ្ឋីក៏ចេញឈ្នួលថ្លៃកាត់សក់ និងជាវកន្ត្រៃ និងក្រាសទិព្វនោះទុកជាកម្មសិទ្ធិសម្រាប់ប្រើប្រាស់តទៅមុខ ។ បន្ទាប់មកមហាសេដ្ឋីក៏បានស្នើសុំឲ្យទេវតាទាំងពីរជូនពរជ័យដល់កូនប្រុសស្រីដោយទេវតាក៏បានច្រៀងប្រសិទ្ធិពរជ័យជូនកូនប្រុសស្រី ព្រមទាំងលោកសេដ្ឋី និងភ្ញៀវកិត្តិយសទាំងអស់របស់លោកក្នុងឱកាសនោះដែរ ។ អត្ថន័យនៃចម្រៀង គឺដើម្បីជូនពរជ័យឲ្យគូស្វាមីភរិយាថ្មីប្រកបនូវជោគវាសនាល្អ សុភមង្គល និងវិបុលសុខក្នុងជីវិត ។ ហេតុដូច្នេះ ប្រជាជនខ្មែរក៏បានរៀបចំប្រារព្ធពិធី



រូបខាងស្តាំ ៖ យាង សេងហឿន សម្ភាសជាមួយអាចារ្យឈ្មោះ គឹម គៀន អំពីពិធីសំពះផ្ទឹមក្នុងព្រះវិហារ នៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

កាត់សក់ក្នុងអាពាហ៍ពិពាហ៍ដរាបរៀងមក ដោយយកតាមលំនាំនៃរឿងរ៉ាវនេះ ។ ដូចគ្នានេះដែរ ការដង្ហែកូនកំលោះកូនក្រមុំទៅវត្តរបស់អ្នកឃុំវិហារសួគ៌ ក៏មានរឿងរ៉ាវទាក់ទងរបស់ខ្លួនដែរ ។

លោក ថុល ថុន អាយុ៦២ឆ្នាំ រស់នៅភូមិព្រៃធំ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល បានមានប្រសាសន៍ថា ការដង្ហែកូនកំលោះកូនក្រមុំទៅវត្តដើម្បីសំពះផ្ទឹមគឺមានតាំងពីយូរលង់ណាស់មកហើយ ។ ដូចមានដំណាលរឿងថា ៖

កាលពីដើមឡើយ នៅពេលរៀបមង្គលការកូនប្រុសស្រី ចាស់ព្រឹទ្ធាចារ្យ និងឪពុកម្ដាយតែងនាំកូនកំលោះកូនក្រមុំដង្ហែទៅកាន់វត្ត ។ ដើម្បីធ្វើកិច្ចពិធីបង្គ្រប់លក្ខណ៍ ដែលពិធីនេះមានអត្ថន័យបញ្ជាក់ពីភាពបរិសុទ្ធរបស់កូនប្រុសស្រីក្នុងពេលរៀបមង្គលការ ។ តាមការឲ្យដឹងពីចាស់ៗក្នុងភូមិថា នៅពេលកូនស្រីមិនមានភាពបរិសុទ្ធិ កូនស្រីនោះនឹងចុកពោះរហូតបាត់បង់ជីវិត ដ្បិតបារមីរបស់ព្រះអង្គក្នុងព្រះវិហារពូកែស័ក្តិសិទ្ធិ ។ ជាលទ្ធផល ប្រសិនបើកូនស្រីណាមិនមានភាពបរិសុទ្ធិនឹងត្រូវបារមីព្រះអង្គនឹងកាច់យកតែម្ដង ដោយគ្រាន់តែដើរចូលក្នុងព្រះវិហារតាមទ្វារខាងមុខ ។ ប៉ុន្តែ ក្រោយមក ការដង្ហែកូនប្រុសកូនស្រីទៅវត្តដើម្បីធ្វើពិធីបង្គ្រប់លក្ខណ៍នេះបានប្ដូរ ។ កូនក្រមុំហែចូលក្នុងព្រះវិហារនៅតាមផ្លូវ ឬទ្វារចំហៀង ឬក្រោយវិញ ដើម្បីបញ្ចៀសបារមីរបស់ព្រះអង្គកាច់ស្លាប់ ។ ហេតុដូច្នេះ យើងសង្កេតឃើញថា នៅសម័យបច្ចុប្បន្ន ការដង្ហែកូនកំលោះកូនក្រមុំចូលក្នុងព្រះវិហារគឺតម្រូវឲ្យចូលតាមទ្វារចំហៀង ឬក្រោយវិញ ។

ក្នុងចំណោមអ្នកផ្ដល់បទសម្ភាសន៍ទាំង៨នាក់ បានមានប្រសាសន៍ដូចៗគ្នាថា ការដង្ហែកូនកំលោះកូនក្រមុំតម្រូវឲ្យចូលតាមខ្លោងទ្វារជ័យតែមួយគត់ ដែលស្ថិតនៅខាងក្រោយព្រះវិហារបំណន់ ដែលជាព្រះវិហារកូនកំលោះកូនក្រមុំត្រូវធ្វើពិធីសំពះផ្ទឹម ។

គួរបញ្ជាក់ដែរថា នៅក្នុងវត្តព្រះវិហារសួគ៌មានព្រះវិហារប្រាំ វិហារធំបី គឺព្រះវិហារកើង (ព្រះវិហារធំ) ព្រះវិហារបំណន់ និងព្រះវិហារកោះអណ្ដែត និងព្រះវិហារតូចពីរ គឺព្រះវិហារព្រះពិស្ណុការ និងព្រះវិហារមហាជ័យជម្នះ ។ ព្រះវិហារកើង គឺជាវិហារសម្រាប់ធ្វើឧបោសថ ធ្វើកិច្ចក្រាលគ្រងកឋិន បំបួសកុលបុត្រ ឬពិធីខាងផ្នែកព្រះពុទ្ធសាសនាផ្សេងៗ ។ រីឯព្រះវិហារព្រះពិស្ណុការ ព្រះវិហារមហាជ័យជំនះ ព្រះវិហារបំណន់ និងព្រះវិហារកោះអណ្ដែត គឺសម្រាប់ប្រារព្ធពិធីបែបព្រហ្មញ្ញសាសនា រួមមានពិធីបន់ស្រន់សុំសេចក្ដីសុខសេចក្ដីចម្រើន និងសុំសម្រេចសេចក្ដីប្រាថ្នាផ្សេងៗ ។ ជាក់ស្ដែង នៅពេលគ្រួសារណាមួយ ក្រោយរៀបមង្គលការយូរហើយមិនមានកូនទៀត គ្រួសារនោះតែងនាំគ្នាទៅបន់ស្រន់សុំកូនពីព្រះម៉ែពរផ្ទៃ នៅក្នុងព្រះវិហារកោះអណ្ដែត ដែលមានដំណាលរឿងទាក់ទងនឹងរឿងព្រះបាទបក្សីចាំក្រុងបម្រុងរាជ្យ ។ បើយោងតាមចាស់ទុំនិយាយតៗគ្នាមកគឺថា ការបន់ស្រន់នោះច្រើនបានសម្រេចដូចសេចក្ដីប្រាថ្នា ។ ចំពោះព្រះវិហារបំណន់គឺជាព្រះវិហារសម្រាប់ប្រារព្ធពិធីដង្ហែកូនកំលោះកូនក្រមុំ និងកិច្ចបន់ស្រន់ផ្សេងៗ ។

ព្រះភិក្ខុ ខុន ប៊ុនថន ព្រះជន្ម៣៣ព្រះវស្សា ដែលជាព្រះវិន័យធរវត្តព្រះវិហារសួគ៌ និងលោកតា គឹម គៀន អាយុ៦៨ឆ្នាំ នៅភូមិវិហារសួគ៌ជើង ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ដែលជាគណៈកម្មការវត្តព្រះវិហារសួគ៌ មានសង្ឃដីកា និងប្រសាសន៍ប្រហាក់ប្រហែលគ្នាថា ៖

កាលដើមឡើយ ប្ដីប្រពន្ធពីរនាក់ មានកូនពីរនាក់ ប្រុសម្នាក់ និងស្រីម្នាក់ ។ វេលាថ្ងៃមួយ កូនប្រុសស្រីរបស់ប្ដីប្រពន្ធមានជំងឺ ហេតុដូច្នេះអ្នកទាំងពីរក៏បានទៅបួងសួងនៅវត្តព្រះវិហារសួគ៌ ដែលកាលណោះមិនទាន់មានព្រះវិហារនៅឡើយទេ ពោលគឺមានតែដំបូកមួយ និងដើមឈើធំមួយដើមប៉ុណ្ណោះ ។ ពេលប្ដីប្រពន្ធទាំងពីរទៅបែរបន់នៅទីកន្លែងដីបូកនោះ អ្នកទាំងពីរបានសន្យាថា បើកូនប្រុសស្រីអ្នកទាំងពីរជាសះស្បើយពីជំងឺ អ្នកទាំងពីរនឹងយកកូនទាំងពីរនាក់យកមកសំពះផ្ទឹម ដើម្បីសុំពរសុំជ័យឬទ្ធិបារមីពីទីកដីដែលស្ថិតក្នុងវត្តព្រះវិហារសួគ៌នោះ (ក្រោយក៏ក្លាយជាព្រះវិហាររហូតដល់សព្វថ្ងៃ) ។ បន្ទាប់ពីការបន់ស្រន់ហើយ កូនប្រុសស្រីក៏បានជាពីជំងឺ ដូច្នេះឪពុកម្ដាយទាំងពីរក៏បានយកអ្នកទាំងពីរមកសំពះផ្ទឹមដូចបានសន្យា ។ តំណាតមក ការប្រារព្ធពិធីសំពះផ្ទឹមតាមគ្នានៅថ្ងៃរៀបមង្គលការក៏មានរហូតមកដល់បច្ចុប្បន្ននេះ ។

## ***វណ្ដាប់នៃពិធីសំពះផ្ទឹម***

វណ្ដាប់ដែលប្រជាជននៅក្នុងឃុំវិហារសួគ៌យកមករៀបចំ

ពិធីសំពះផ្ទឹមក្នុងព្រះវិហារ (បន្តុប់លក្ខណ៍ ឬពិធីបន់ស្រន់) មាន ដូចខាងក្រោម ៖

១) ថង់វង់១គូ
២) ផ្កាស្លា
៣) ដាវជ័យ
៤) ផ្តិលទឹក១
៥) អំបោះចងដៃ (អំបោះស ឬក្រហម)
៦) វង់ភ្លេង ១វង់ (វង់ភ្លេងការប្រពៃណី)
៧) ស្លាព័ន្ធ ម្លូព័ន្ធ ១គូ
៨) ស្លាព្រះពរ (មានទាន២ ធូក ពាសសៃ អង្ករ)
៩) ផ្កាពីរកន្ត្រក
១០) ស្លឹកម្លូ ៣សន្លឹក
១១) ខ្នើយសំពះ ១
១២) កន្ទេល ១ខ្សែ
១៣) មេបាខាងប្រុស-ស្រី ឬចាស់ទុំអ្នកដឹងនៃពិធីសំពះផ្ទឹម
១៤) អ្នកកំដរកូនស្រី-ប្រុស
១៥) សាច់ញាតិចាស់ទុំ

**របៀបនៃការដង្ហែកូនកម្លោះកូនក្រមុំទៅសំពះផ្ទឹមក្នុងព្រះវិហារ**

ពិធីសំពះផ្ទឹមក្នុងព្រះវិហារ ជាពិធីសំខាន់មួយក្នុងចំណោមពិធីផ្សេងៗទៀតនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់ប្រជាជនឃុំ



ព្រះភិក្ខុព្រះនាម ខុន ប៊ុនថន គង់នៅវត្តព្រះវិហារសួគ៌ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

វិហារសួគ៌ ។ ការប្រារព្ធធ្វើពិធីនេះតម្រូវឲ្យមានការហែកូនប្រុសស្រីពីផ្ទះម្ចាស់សាមីដើមការទៅកាន់វត្តព្រះវិហារសួគ៌ ។

បើតាមលោក គឹម គៀន និយាយថា នៅសម័យសង្គមរាស្ត្រនិយម ការដង្ហែកូនកំលោះកូនក្រមុំមកប្រារព្ធពិធីសំពះផ្ទឹមក្នុងវត្ត គឺធ្វើឡើងនៅពេលរសៀល ។ ប៉ុន្តែ សម័យកាលក្រោយមក ជាពិសេសបន្ទាប់ពីរបបក្រហម ការប្រារព្ធពិធីដង្ហែកូនកំលោះកូនក្រមុំតម្រូវឲ្យធ្វើឡើងមុនពិធីកាត់សក់ ពោលគឺបន្ទាប់ពីប្រារព្ធពិធីសំពះផ្ទឹមក្នុងព្រះវិហាររួចហើយ ទើបកូនកំលោះកូនក្រមុំត្រឡប់ទៅផ្ទះវិញដើម្បីប្រារព្ធពិធីកាត់សក់ ។ ដូច្នេះ ពិធីហែកូនកំលោះកូនក្រមុំទៅវត្តត្រូវប្រារព្ធធ្វើនៅពេលព្រឹក ។

ការដង្ហែត្រូវរៀបចំនៅជិតខ្លោងទ្វារឲ្យមានរបៀបរៀបរយ ដោយក្រុមភ្លេងត្រូវនៅជួរមុខ កូនកំលោះកាន់ផ្កាស្លា និងកូនក្រមុំកាន់ស្លាព្រះពរនៅជួរបន្ទាប់ និងនៅចំកណ្តាល ។ មេបា ឬចាស់ព្រឹទ្ធាចារ្យកាន់ថង់វង់អមសងខាងកូនកំលោះកូនក្រមុំ ។ បន្ទាប់ពីមេបា ឬចាស់ព្រឹទ្ធាចារ្យ គឺអ្នកកាន់ស្លាព័ន្ធម្លូព័ន្ធដែលជាប្តីប្រពន្ធ ហើយបន្ទាប់មកទៀតគឺអ្នកកាន់កន្ត្រកផ្កា ។ ចំណែកឯ អ្នកកំដរត្រូវឈរនៅខាងក្រោយកូនកំលោះកូនក្រមុំចាំបាំងឆ័ត្រឲ្យកូនប្រុសស្រី ។ អ្នកដែលឈរបន្ទាប់អ្នកកំដរ គឺជាសាច់ញាតិដែលមកជាមួយប្រសិនបើមាន ។ ក្រោយរៀបចំរួច ក្បួនត្រូវចាប់ផ្តើមដង្ហែទៅកាន់ព្រះវិហារបំណន់ ។ ក្រុមភ្លេងលេងអមនៅពីមុខរហូតដល់ព្រះវិហារបំណន់ រួចកូនកំលោះតម្រូវឲ្យដើរចូលក្នុងព្រះវិហារតាមទ្វារខាងមុខ ដែលស្ថិតនៅទិសខាងកើត រីឯកូនក្រមុំតម្រូវឲ្យចូលតាមទ្វារចំហៀងដែលស្ថិតនៅទិសខាងជើង ។

លោក គឹម គៀន បានមានប្រសាសន៍ថា កូនស្រីត្រូវចូលតាមទ្វារចំហៀងនៅទិសខាងជើង ដើម្បីបង្ហាញថាស្ត្រីនោះមានលក្ខណ៍ ។ ប្រសិនបើ ស្ត្រីនោះដើរចូលតាមទ្វារខាងមុខនៅពេលធ្វើកិច្ចពិធីសំពះផ្ទឹម ចាស់បុរាណលោកចាត់ទុកថាស្ត្រីនោះមិនមានលក្ខណ៍នោះទេ ។ ដូច្នេះទើប កូនក្រមុំត្រូវបានតម្រូវឲ្យដើរចូលនៅទ្វារចំហៀងរហូតមក ។

គួរបញ្ជាក់ដែរថា ខ្លោងទ្វារនៅក្នុងវត្តព្រះវិហារសួគ៌មានបួន គឺខាងខ្លោងទ្វារប៉ែកខាងត្បូង១ ខាងលិច២ និងខាងជើង១ ។ ការដង្ហែកូនកំលោះកូនក្រមុំតម្រូវឲ្យចូលនៅខ្លោងទ្វារខាងលិចដែល

ស្ថិតនៅខាងក្រោយព្រះវិហារបំណន់ ។ មួយវិញទៀត ការបង្ហែកូនកំលោះកូនក្រមុំចេញពីផ្ទះមកដល់ខ្លោងទ្វារជ័យ ត្រូវហែពីទិសខាងជើងមកខ្លោងទ្វារជ័យ មិនអាចហែចេញពីទិសខាងត្បូង ឬខាងកើតឡើយ ។

## របៀបរៀបចំរណ្តាប់ និងរបៀបសំពះផ្ទឹមក្នុងព្រះវិហារ

នៅពេលចូលដល់ក្នុងព្រះវិហារបំណន់ កន្ទេលត្រូវក្រាលនៅចំហៀងខាងជើងព្រះវិហារ ពោលគឺមិនមែនក្រាលនៅទល់មុខព្រះភ័ក្ត្រព្រះពុទ្ធរូបនោះទេ ។ មេបា ឬចាស់ព្រឹទ្ធាចារ្យត្រូវអុជធូបសុំសេចក្តីសុខជាមុន ។ បន្ទាប់មកទើបរៀបចំរណ្តាប់រួមមាន ផ្កាស្លាស្លាព្រះពរ និងផ្តិលទឹកត្រូវដាក់នៅមុខគេ ដែលមានថង់រង ស្លាព័ន្ធម្លូព័ន្ធ និងកន្ត្រកផ្កាអមសងខាង ។ រីឯ ខ្នើយសំពះដែលមានរៀបស្លឹកម្លូបីសន្លឹកនៅពីលើត្រូវដាក់បន្ទាប់ពីផ្តិលទឹក ។ នៅលើថង់រង១ចំហៀងត្រូវមានទៀន២ដើម ។ នៅក្នុងផ្តិលទឹកមានអំបោះក្រហម ឬស និងទៀនពីរដើម ឬមួយដើម ។

បន្ទាប់ពីរៀបចំអុជទៀនលើថង់រង និងលើផ្តិលទឹករួច កូនកំលោះត្រូវកាន់ស្លឹកម្លូនៅលើខ្នើយសំពះពីស្តាំទៅឆ្វេងជាគម្រប់មួយដង ចំណែកកូនក្រមុំក៏អនុវត្តដូចគ្នាដែរ ។ បន្ទាប់មក កូនកំលោះកូនក្រមុំក្រាបសំពះទន្ទឹមគ្នា ដោយកូនកំលោះនៅខាងស្តាំកូនក្រមុំនៅខាងឆ្វេងដោយមាន មេបា ឬចាស់ព្រឹទ្ធាចារ្យកាន់ដៃកូនប្រុសស្រីអមសងខាងផង ។ រីឯ អ្នកកំដរអន្ទុយនៅខាងក្រោយកូនកំលោះកូនក្រមុំ ។ បន្ទាប់មកទៀត ភ្លេងចាប់ផ្តើមប្រគំបទសែនចងដៃជាហូរហែ ដោយមេបា ឬចាស់ទុំចងអំបោះឲ្យកូនប្រុសកូនស្រីនិងនិយាយឲ្យពរជ័យដល់កូនកំលោះកូនក្រមុំ ដូចជាជូនពរកូនកំលោះកូនក្រមុំជួបប្រទះតែសេចក្តីសុខ និងសិរីសួរស្តី និងចេះស្រលាញ់គ្នាលុះចាស់កោងខ្នងជាដើម ។នៅពេលភ្លេងប្រគុំចប់ មេបា ចាស់ទុំតម្រូវឲ្យកូនប្រុសស្រីងើបដំណាលគ្នា ។ ជាកិច្ចបញ្ចប់ពិធី កូនប្រុសស្រីដើរចេញតាមទ្វារដែលដើរចូលមករៀងៗខ្លួននិងថតរូបទុកជាអនុស្សាវរីយ៍ ។

## ជំនឿផ្សេងៗក្នុងពិធីសំពះផ្ទឹម

បើផ្អែកទៅលើការលើកឡើងរបស់លោកអាចារ្យខាងពេលា គឺលោក យិន សុខ បានឲ្យដឹងថា នៅក្នុងពិធីសំពះផ្ទឹមក្នុងព្រះវិហារ ការចងខ្សែអំបោះពណ៌សដល់កូនប្រុសស្រី គឺបញ្ជាក់អំពីភាពស្អាតស្អំ និងស្មោះត្រង់គ្នាទៅវិញទៅមក ។ ប៉ុន្តែ បច្ចុប្បន្នយើងសង្កេតឃើញមានប្រជាជនមួយចំនួនចងអំបោះក្រហមដែលខុសពីការប្រណិប័តន៍ពីបុរាណកាលមក ។ លោកអាចារ្យ សុខ បានបន្ថែមថា ការប្រណិប័តន៍ខុសពីបុរាណនេះ គឺមកពីអាចារ្យមួយចំនួនមិនបានសិក្សាស្វែងយល់អំពីប្រពៃណី និងអត្ថន័យនៃការចងអំបោះក្នុងពិធីអាពាហ៍ពិពាហ៍ខ្មែរឲ្យបានស៊ីជម្រៅ ។

អ្នកផ្តល់បទសម្ភាសន៍ចំនួន៧នាក់នៅក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ទាំងអស់ បានមានប្រសាសន៍ដូចៗគ្នាថា មេបា ចាស់ទុំតម្រូវឲ្យកូនកំលោះកូនក្រមុំងើបដំណាលគ្នា ដោយសារតែចាស់ព្រឹទ្ធាចារ្យមានជំនឿថា ប្រសិនបើកូនប្រុសស្រីណាងើបក្រោយនោះនឹងមានរាសីដាក់ជាងអ្នកដែលងើបមុន ដូចជាមានជំងឺច្រើនជាងជាដើម ។ ដូច្នេះ កូនកំលោះកូនក្រមុំត្រូវងើបឲ្យបានព្រមៗគ្នា ។

បើយោងតាមអ្នកស្រី ភាស់ ទូច នៅភូមិតាកែវ២ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល អ្នកកាន់ស្លាព័ន្ធម្លូព័ន្ធត្រូវតែជាប្តីប្រពន្ធ ឬអ្នកដែលមិនបាក់មែកបាក់ធាង មានន័យថា គ្រួសារមានរស់នៅជុំគ្នា ។ ចាស់ទុំជឿថា ការធ្វើដូច្នេះ គូស្វាមីភរិយាថ្មីនឹងរួមរស់ជាមួយគ្នារហូតដល់ចាស់ ។ ជាងនេះទៅទៀត លោកតាឡូញ ខុន អាយុ៦៧ឆ្នាំ ដែលជាអាចារ្យចាត់ចែងក្នុងពិធីមង្គលការរស់នៅ នៅភូមិស្វាយមាស ឃុំវិហារសួគ៌ បានមានប្រសាសន៍ថា ប្រជាជនរស់នៅឃុំវិហារសួគ៌ប្រកាន់ណាស់ចំពោះអ្នកកាន់ស្លាព័ន្ធម្លូព័ន្ធ ។ ប្រសិនបើអាចារ្យរូបណាបែកបាក់ប្រពន្ធកូន សាម៉ីដើមការនឹងមិនរើសយកធ្វើជាអាចារ្យរៀបចំពិធីមង្គលការកូនប្រុសកូនស្រីរបស់ខ្លួនឡើយ ។

អ្នកស្រី ភាស់ ទូច បានមានប្រសាសន៍បន្តទៀតថា នៅពេលត្រឡប់ទៅផ្ទះបន្ទាប់ពីការប្រារព្ធពិធីសំពះផ្ទឹមក្នុងព្រះវិហាររួច លោកអាចារ្យ (ជំនាន់នោះគឺអាចារ្យ ប្រាក់ ថាន់ ជាអាចារ្យមង្គលការរបស់អ្នកស្រី) បានបង្គាប់អ្នកស្រីឲ្យរក្សាទុកវត្ថុមួយចំនួនដែលបានប្រើដើម្បីរៀបចំពិធីសំពះផ្ទឹម ដូចជា ទៀនដែលអុជនៅលើថង់រង និងរំនឹងស្លាព្រះពរ ព្រមទាំងអង្ករក្នុងស្លាព្រះពរ ដើម្បីទុកគ្រាន់ព្យាបាលជំងឺកូនចៅ ។ លោកអាចារ្យមានជំនឿថា នៅពេលដែលអ្នកស្រីមានបុត្រាបុត្រី ហើយកូនរបស់គាត់មានជំងឺ គាត់អាច

យកអង្ករនោះបន្តិចទៅដាំលាយជាមួយអង្ករផ្សេងឲ្យកូនញ៉ាំ ដើម្បីឲ្យជំងឺនឹងជាស្បើយ ។ ម៉្យាងទៀត ប្រសិនបើអ្នកស្រីសុបិន្ត ឃើញកូនមិនស្រួល ឬឃុំខ្លាំង អ្នកស្រីអាចយកអង្ករដែលរក្សាទុកនោះមកបាចបណ្តោះគ្រោះអន្តរាយ ជាដើម ។ ចំណែកឯទៀនវិញ គឺទុកសម្រាប់ប្រើក្នុងពេលរៀបចំពិធីបង្កក់កូន ដែលអាចារ្យនឹងយកទៀននោះមកបង្វិលពពិល ។ ប៉ុន្តែ ការថែរក្សារបស់ទាំងអស់នោះគឺពិបាក ។ ដូច្នេះ កូនកំលោះកូនក្រមុំមួយចំនួនមិនបានរក្សាទុករបស់ទាំងអស់នោះទេ ។ ជាងនេះទៅទៀត អាចារ្យរៀបចំមង្គលការមួយចំនួនមិនបានផ្តាំផ្ញើប្រាប់កូនកំលោះកូនក្រមុំឲ្យយកវត្ថុទាំងអស់នោះទៅរក្សាទុកឡើយ ។ លោកតា គីម គៀន បាននិយាយបន្ថែមទៀតថា វិជ្ជាពេទ្យមិនសូវជឿនលឿនប៉ុន្មានទេកាលសម័យដើម ។ ដូច្នេះ ចាស់ទុំមានជំនឿថា អង្ករនោះជាឱសថអាចព្យាបាលក្មេងពីជំងឺ បាន ។

## សំយោគ

ពិធីដង្ហែកូនកំលោះកូនក្រមុំទៅកាន់ទីវត្តគឺមានលក្ខណៈផ្សេងគ្នាទៅតាមការនិយម ស្ថានភាពស្រុកទេស ប្រពៃណីទំនៀមទម្លាប់ និងជំនឿ ។ ទោះជាយ៉ាងណាក៏ដោយ ការប្រារព្ធពិធីសំពះផ្ទឹមនៅក្នុងព្រះរបស់ប្រជាជនក្នុងឃុំវិហារសួគ៌ គឺមានភាពស្រដៀងគ្នានឹងពិធីសំពះផ្ទឹម នៅនឹងគេហដ្ឋាននៃពិធីមង្គលការរបស់អ្នកភូមិឯទៀតដែរ ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ក៏ជំនឿនៃការសំពះផ្ទឹមនេះហាក់មានលក្ខណៈពិសេសរៀងៗខ្លួន ឧទាហរណ៍ដូចជាការបន់ស្រន់សុំសេចក្តីសុខសិរីសួរស្តីប្រសិទ្ធពរជ័យពីព្រះអង្គវត្តព្រះវិហារសួគ៌ និងការដែលតម្រូវឲ្យកូនក្រមុំចូលក្នុងព្រះវិហារតាមទ្វារចំហៀងខាងជើង បានបង្ហាញពីភាពមានលក្ខណ៍របស់កូនក្រមុំនៅក្នុងជំនឿរបស់ប្រជាជនដែលរស់នៅឃុំវិហារសួគ៌ ។

មិនតែប៉ុណ្ណោះ អ្នកដែលផ្តល់បទសម្ភាសន៍ក៏បានបង្ហាញប្រាប់អំពីភាពខុសគ្នាបន្តិចបន្តួចនៅក្នុងការប្រារព្ធពិធីពីសម័យកាលមួយទៅសម័យកាលមួយ ។ លោកតា យិន សុខ បានមានប្រសាសន៍ថា កាលពីសម័យសង្គមរាស្ត្រនិយម ការដង្ហែកូនកំលោះកូនក្រមុំមកសំពះផ្ទឹមក្នុងព្រះវិហារ គឺមិនមែនមានតែអ្នកឃុំវិហារសួគ៌នោះទេ ពោលគឺប្រជាជនរស់នៅឃុំសន្ទុងក៏ធ្លាប់ដង្ហែមកដែរ បើទោះបីជាបច្ចុប្បន្ននេះ ប្រជាជននៅក្នុងឃុំសន្ទុងមិនសូវដង្ហែមកក៏ដោយ ។ ចំណែកឯ លោកតា គីម គៀន ដែលជាគណៈកម្មការវត្តព្រះវិហារសួគ៌ ក៏សង្កេតឃើញប្រជាជនរស់នៅឃុំសន្ទុងនៅតែបន្តមកបន់ស្រន់នៅល្ងាចថ្ងៃសូត្រមង្គលការ ។ លោកតាសន្និដ្ឋាន កត្តាមួយចំនួនដែលប្រជាជននៅឃុំសន្ទុងមិនបានដង្ហែកូនកំលោះកូនក្រមុំមកព្រះវិហារនៅក្នុងថ្ងៃមង្គលការ គឺមកពីផ្លូវធ្វើដំណើរវែងឆ្ងាយ និងមានការរៀបចំកម្មវិធីច្រើនក្នុងថ្ងៃមង្គលការ ។

ម៉្យាងវិញទៀត អ្នកផ្តល់បទសម្ភាសន៍ទាំង៨នាក់ បានសង្កេតឃើញដូចៗគ្នាថា ពិធីដង្ហែកូនកំលោះកូនក្រមុំទៅព្រះវិហារ គឺមិនមានការប្រែប្រួលខ្លាំងនោះទេ ។ ពោលគឺនៅមុនសម័យសង្គមរាស្ត្រនិយម ការដង្ហែកូនកំលោះកូនក្រមុំទៅវត្តប្រព្រឹត្តទៅដោយថ្មើរជើង និងមានមនុស្សចូលរួមច្រើន ។ ចំណែកឯនៅក្រោយសម័យខ្មែរក្រហម និងសម័យបច្ចុប្បន្នវិញ ការដង្ហែកូនកំលោះកូនក្រមុំទៅវត្តគឺប្រើប្រាស់រថយន្តនិងចំនួនមនុស្សចូលរួមដង្ហែហាក់តិចជាងមុន ។ ប៉ុន្តែ រណ្តាប់ និងក្បួនដង្ហែត្រូវបានរក្សានិងអនុវត្តដដែល ។ ជាអកុសល ពិធីដង្ហែកូនកំលោះកូនក្រមុំទៅសំពះផ្ទឹមក្នុងព្រះវិហារនេះ មិនត្រូវបានអនុញ្ញាតឲ្យប្រណិប័តនៅក្នុងសម័យខ្មែរក្រហមឡើយ ដោយពេលនោះខ្មែរក្រហមបានបំផ្លិចបំផ្លាញព្រះវិហារក្នុងឃុំវិហារសួគ៌ និងយកព្រះវិហារធ្វើជាឃ្លាំងសម្រាប់ដាក់ស្រូវ ហើយការប្រារព្ធពិធីផ្សេងៗដែលជាជំនឿ និងជាទំនៀមទម្លាប់របស់ប្រជាជនឃុំវិហារសួគ៌ក៏ត្រូវបានលុបបំបាត់ចោលដែរ ។

ត្បិតការដង្ហែកូនកំលោះកូនក្រមុំទៅវត្តមានការហៅឈ្មោះខុសគ្នា តែពិធីនេះត្រូវបានប្រារព្ធឡើងជាយូរលង់ណាស់មកហើយ ។ ការប្រារព្ធធ្វើពិធីនេះនៅក្នុងពិធីមង្គលការខ្មែរ គឺជាចំណុចពិសេសមួយរបស់ប្រជាជនរស់នៅក្នុងឃុំវិហារសួគ៌ ដែលខុសប្លែកពីឃុំដទៃនៅក្នុងប្រទេសកម្ពុជា ។ បុព្វបុរសដែលធ្លាប់រស់នៅឃុំវិហារសួគ៌បានបង្កើតប្រពៃណីទំនៀមទម្លាប់ដ៏សម្បូរបែបសម្រាប់កូនចៅជំនាន់ក្រោយដែលកើត និងរស់នៅឃុំវិហារសួគ៌ ។ ដូច្នេះ ប្រជាជនដែលរស់នៅឃុំវិហារសួគ៌ គប្បីចេះថែរក្សា និងបន្តប្រណិប័តទំនៀមទម្លាប់ដែលដូនតារបស់ខ្លួនបានបន្សល់ទុកមកដល់សព្វថ្ងៃ ព្រមទាំងបន្តចែករំលែក និងអភិរក្សប្រពៃណីទំនៀមទម្លាប់របស់ខ្លួនកុំឲ្យបាត់បង់ ។ **ឃាង សេងហៀន**

# អំពីប្រល័យពូជសាសន៍៖ ការធ្វើទុកបុកម្នេញ លើជនជាតិវៀតណាម និងចាម

លោក គាំចាន់ មានប្រសាសន៍ទៀតថា ការសំដៅលើមនុស្សទាំងឡាយណាដែលបដិសេធការបោះបង់ទំនៀមទម្លាប់ និងភាសារបស់ពួកគេ គឺស័ក្តិសមត្រូវតាមបទដ្ឋាននៃការប្រល័យពូជសាសន៍ ។ ក្រុមព្រះរាជអាជ្ញាបានដាក់សំណើអះអាងថា ការកម្ចាត់ជនជាតិចាមចេញពីស្រុកចំនួនបីដែលធ្លាប់ជាទឹកដីកំណើតយូរលង់មកហើយរបស់ពួកគេក៏អាចត្រូវនឹងបទដ្ឋានដែរ ។

សមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍បាននិយាយនៅក្នុងលិខិតមួយថា កិច្ចប្រឹងប្រែងដើម្បីបំបែកបំបាក់ជនជាតិចាមគឺជាផ្នែកមួយនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ។

បន្ទាប់មកលោក គាំចាន់ បានពិភាក្សាអំពីសក្ខីកម្មរបស់សាក្សីសំខាន់ម្នាក់ ដែលធ្លាប់ជាលេខាស្រុកកំពង់សៀម ។ ជាដំបូង គាត់បានពិនិត្យមើលជំហររបស់ក្រុមការពារ ដែលក្នុងនេះ នួន ជា បានទទួលស្គាល់ពីបែបបទដែលការផ្តល់សក្ខីកម្មរបស់សាក្សីខាងលើ អាចមានឥទ្ធិពល និងអានុភាពខ្លាំងក្នុងការបញ្ជាក់ថា គោលនយោបាយប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាមពិតជាមានពិតមែន និងដាក់បញ្ចេញនូវ «ទ្រឹស្តីសមគំនិតដែលមិនសមហេតុផល» ស្តីពីបែបបទដែលក្រុមព្រះរាជអាជ្ញាមើលទៅអាចទាយទុកមុនបានទៅហើយចំពោះការដាក់សាក្សីម្នាក់នេះឲ្យផ្តល់សក្ខីកម្មនៅក្នុងដំណាក់កាលនៃជំនុំជម្រះនេះ ។ ការឆ្លើយតបរបស់លោក



ជនជាតិនៅព្រះវិហារ

គាំចាន់ ទៅនឹងមេធាវីការពារក្តីគឺថា នរណាម្នាក់ដែលដឹងពីឯកសារសំណុំរឿង និងចង់ទទួលបានការពិតនឹងចង់ដឹងពីការថ្លែងរបស់លេខាស្រុកកំពង់សៀមដែរ ។

លោក គាំចាន់ កត់សម្គាល់ថាមាន (ករណីច្រើន) នៅក្នុងឯកសារសំណុំរឿងដែលរៀបរាប់យ៉ាងលម្អិតអំពីសកម្មភាពនៅខេត្តកំពង់ចាម ។ ឧទាហរណ៍ សាក្សីជំនាញម្នាក់បានសរសេរក្នុងសៀវភៅរបស់គាត់ថា ចំនួនការស្លាប់របស់ជនជាតិចាមមានភាពសាហាវយង់ឃ្នងខ្លាំងណាស់នៅខេត្តកំពង់ចាម ហើយឯកសារទាក់ទងនឹងកម្ពុជាប្រជាធិបតេយ្យបានបង្ហាញថាស្ទើរតែចំនួនទាំងអស់នៃជនជាតិចាមត្រូវបានសម្លាប់ចោលប្រមាណពី ២.០០០ ដល់ ១០.០០០ គ្រួសារ ។ ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ភូមិជនជាតិចាមចំនួនដប់ត្រូវបានបំផ្លាញទាំងស្រុង ដែលក្នុងចំណោមនោះមានភូមិចំនួន៥ ស្ថិតនៅខេត្តកំពង់ចាម ។

លោក គាំចាន់ បានបង្វែរទៅលេខាស្រុកកំពង់សៀមវិញ ដែលលោកស្រីបានផ្តល់សក្ខីកម្មថា មានបញ្ជាពីថ្នាក់តំបន់ទៅថ្នាក់ស្រុកឲ្យបោសសម្អាត (ប្រល័យពូជសាសន៍) ជនជាតិចាម ។ លោកស្រីបានឆ្ងល់ពីមូលហេតុដែលមេដឹកនាំចង់បោសសម្អាតជនជាតិចាម ។ លោកស្រីត្រូវបានសួរពីចំនួនជនជាតិចាមសរុបនៅស្រុកកំពង់សៀម ប៉ុន្តែគាត់មិនបានដឹងទេ ។ លោកស្រីនៅតែបន្តឆ្ងល់ពីមូលហេតុដែលជនជាតិចាមត្រូវបានគេតម្រូវឲ្យបោសសម្អាត ប៉ុន្តែនៅពេលបញ្ជាចេញមកពីថ្នាក់លើមក លោកស្រីគ្រាន់តែជាអ្នកអនុវត្តវាប៉ុណ្ណោះ ។ លោក គាំចាន់ បានពិពណ៌នាសាក្សីម្នាក់នេះមានលក្ខណៈការពារតួនាទីរបស់ខ្លួនជ្រុលពីព្រោះថាលោកស្រីបានផ្តល់សក្ខីកម្មថាក្នុងអំឡុងពេលនៃការបោសសម្អាត លោកស្រីគ្រាន់តែជាអ្នកដឹងឮថាជនជាតិចាមត្រូវបាននាំយកទៅសម្លាប់ប៉ុណ្ណោះ ។ កាលនោះ លោកស្រីត្រូវបានផ្តល់ដំណឹងដោយលេខាតំបន់ ។ លោកស្រីបានប្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា បញ្ជាទាំងឡាយដែលលោកស្រីបានទទួលគឺហ្មត់ចត់ណាស់ ហើយលោកស្រីគ្មានជម្រើសអ្វីក្រៅពីធ្វើតាមបញ្ជាទាំងនោះទេ ។ អ្នកក្រោមបង្គាប់របស់លោកស្រីដែលជាលេខាឃុំ បានផ្តល់សក្ខីកម្មថាលោកស្រីត្រូវបានគេតម្រូវឲ្យចងក្រងឈ្មោះទាហាននៃរបបលន់ នល់ នៃជនជាតិចាម និងជនជាតិវៀតណាមដាក់ក្នុងបញ្ជី ។ លោកស្រីលេខាស្រុកបានផ្តល់សក្ខីកម្មបន្តទៀតថា លោកស្រីបានកត់សម្គាល់ឃើញការថយចុះជាលំដាប់នៃជនជាតិចាម ហើយមេបញ្ជាការយោធាស្រុកបានប្រាប់លោកស្រីថា ជនជាតិចាមត្រូវបានគេបោសសម្អាតអស់ហើយ ។ លេខាឃុំក៏បានផ្តល់សក្ខីកម្មដែរថា លេខាស្រុកបានធ្វើដំណើរទៅរាជធានីភ្នំពេញម្តងឬពីរដងក្នុងមួយខែ ។ សាក្សីផ្សេងៗទៀតបានពិភាក្សានិយាយគ្នាលេខាស្រុកអំពីគោលនយោបាយរបស់ថ្នាក់លើ ដែលថាជនជាតិចាមគឺជាសត្រូវដែលចាំបាច់ត្រូវលុបបំបាត់ចោល ។

បន្ទាប់មក លោក គាំចាន់ បានរៀបរាប់ពីសក្ខីកម្មផ្សេងៗពីសាក្សីជាច្រើននៅតាមស្រុកផ្សេងដែលមានគោលនយោបាយស្តីពីការប្រព្រឹត្តលើជនជាតិចាមត្រូវបានអនុវត្ត ។ សាក្សីដែលត្រូវបានសម្ភាសដោយការិយាល័យសហចៅក្រមស៊ើបអង្កេត បាននិយាយថាមានជនជាតិចាមប្រហែល២៩២គ្រួសារ នៅក្នុងភូមិចំនួន ១២ ក្នុងឃុំមួយ ប៉ុន្តែមានតែជនជាតិចាម៣នាក់ប៉ុណ្ណោះដែលបានរួចជីវិត ។ សាកសពជាច្រើនរបស់ពួកគេត្រូវបានគេបោះចោលនៅក្នុងអណ្តូងទឹកឬរណ្តៅគ្រាប់បែក ។ លោក គាំចាន់ បានប៉ាន់ធ្វើការប្រមាណថា គ្រាន់តែក្នុងឃុំមួយនោះ មានជនជាតិចាមចំនួនដល់ទៅ១.៨៦៥ ឯណោះ ។ លេខាស្រុកកំពង់សៀមបានផ្តល់សក្ខីកម្មថា លោកស្រីបានធ្វើការរាយការណ៍ជនជាតិចាមចំនួន១.៦០០គ្រួសារ ដែលសរុបជាមនុស្សប្រហែលជា ៨.០០០ នាក់ ។

លោក គាំចាន់ បានគូសបញ្ជាក់ពីរឿងពិតមួយអំពីលេខាស្រុកកំពង់សៀមដែលថាលោកស្រីបានយកជនជាតិចាមម្នាក់ជាកូនស្រីចិញ្ចឹម ហើយនេះគឺជាជនជាតិចាមតែមួយគត់ដែលនាងត្រូវបានសង្គ្រោះ ។

តមកទៀត លោក គាំចាន់ បានពិភាក្សាពីការប្រព្រឹត្តលើជនជាតិចាមនៅស្រុកកងមាស ។ បន្ទាប់ពីការមកដល់របស់ពួកកម្មាភិបាលនិរតី មានក្រុមសន្តិសុខដាវវែងមួយក្រុមមួយដែលតែងទទួលបញ្ជាពីលេខានៅស្រុកកងមាសឲ្យចាប់ខ្លួនជនជាតិចាម ។ ក្រៅពីជនជាតិចាម ពួកគេចាប់ខ្លួនប្រជាជន "ថ្មី" និងអតីតទាហានលន់ នល់ ទៅដាក់វត្តអូរត្រកួន ដែលជាមន្ទីរសន្តិសុខរបស់ស្រុកកងមាស ។ ប៉ុន្តែមានភាពខុសគ្នាចំពោះការប្រព្រឹត្តលើមនុស្សទាំង

នេះ ដោយគ្រួសារចាមទាំងអស់ត្រូវបានចាប់ខ្លួនរួមគ្នា និងមិនត្រូវបានគេសួរចម្លើយទេ ព្រោះតែមិនចាំបាច់ស្វែងរកខ្សែស្រឡាយរបស់ពួកគេ (សាច់ញាតិ និងទំនាក់ទំនងរបស់ពួកគេ) ហើយពួកគេទាំងអស់គង់តែត្រូវយកទៅសម្លាប់ ជួនកាលម្តង ១០០នាក់ ក្នុងពេលតែមួយ ។ សមាជិកម្នាក់នៃក្រុមសន្តិសុខដាវវែងបាននិយាយថា នៅក្នុងឃុំជាក់លាក់មួយ ជនជាតិចាមទាំងអស់ត្រូវបានឃាត់ខ្លួននៅពេលដែលពួកកម្មាភិបាលនិរតីបានមកដល់ ។

បន្ទាប់មកលោក គាំចាន់ បានពិនិត្យមើលចំនួននៃសក្ខីកម្មយ៉ាងច្រើនក្រៅពីបុគ្គលដែលបានកត់សម្គាល់ការបាត់ខ្លួនរបស់ជនជាតិចាមក្នុងភូមិ ឃុំ តំបន់របស់ពួកគេ ឬក៏បានជួបប្រទះសាកសពជនជាតិចាមដែលបានបោះចោលក្នុងទន្លេមេគង្គ ។

លោក គាំចាន់ ក៏បានបង្ហាញវីដេអូចងក្រងពីរស្តីពីសក្ខីកម្មពីសាក្សីជនជាតិចាមទាក់ទងនឹងបែបបទនៃការបង្ខំឲ្យពួកគេបរិភោគសាច់ជ្រូក ការដែលសមាជិកគ្រួសាររបស់ពួកគេបដិសេធនឹងបោះបង់សាសនា ការប្រទះឃើញការសម្លាប់ជនជាតិចាមដោយបោះចូលរណ្តៅធំមួយ ការបោះសាកសពមនុស្សរួមមានកុមារ និងទារកចូលក្នុងទន្លេ ការដែលមនុស្សទាំងនោះត្រូវបានចងជាប់គ្នានឹងខ្សែរួចអូសទៅកណ្តាលទន្លេដោយទុកឲ្យលង់ទឹក ហើយបន្ទាប់មកដំណើរការនេះត្រូវធ្វើម្តងហើយម្តងទៀត ។



ជនជាតិចាមថ្វាយបង្គំនៅព្រះវិហារ

លោក គាំចាន់ បានបន្តទៀតថា ជំហររបស់ព្រះរាជអាជ្ញា គឺមិនដែលថាខ្មែរក្រហមបានសម្លាប់ប្រជាជនចាមទាំងស្រុងទេ ប៉ុន្តែពួកគេបានបំផ្លាញក្រុមពួកគេជាអាទិ៍ ។ លោកបានបញ្ជាក់សាជាថ្មីថា និយមន័យនៃការប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងដើម្បីការពារអត្តសញ្ញាណក្រុមមិនមែនបុគ្គលទេ ។ លោកបានពន្យល់ថា (ការបំផ្លិចបំផ្លាញ) មិនត្រឹមតែមានន័យថាសម្លាប់មនុស្សទេពីព្រោះអំពើប្រល័យពូជសាសន៍ទាំងប្រាំរួមមានការផ្ទេរកុមារពីក្រុមមួយទៅក្រុមមួយទៀត ។ នៅពេលការសម្លាប់ជនជាតិចាមកើតឡើង កុមារទាំងឡាយនៅមានជីវិត ប៉ុន្តែពួកគេនឹងរៀនភាសាទំនៀមទម្លាប់ និងសាសនាខុសគ្នា ហើយដោយហេតុនេះ បន្ទាប់មកក្រុមនេះនឹងមិនមានទៀតទេ ។

ក្នុងសំណុំរឿងនេះ ការសម្លាប់ត្រូវបានធ្វើឡើងជាពិសេសសំដៅទៅលើកន្លែងទាំងឡាយណាដែលជនជាតិចាមបានកំពុងរស់នៅ ហើយខ្មែរក្រហមបានសំដៅលើមេដឹកនាំនៃសហគមន៍ជនជាតិចាម និងការអនុវត្តសាសនា ។ ដោយសារមូលហេតុទាំងនេះ ការប្រល័យពូជសាសន៍ជនជាតិចាមបានពិតជាបានកើតឡើងប្រាកដដោយគ្មានការសង្ស័យឡើយ ។

សាក្សីម្នាក់ដែលធ្លាប់នៅភូមិភាគកណ្តាលបានផ្តល់សក្ខីកម្មដល់តុលាការថា បន្ទាប់ពីខ្មែរក្រហមបានកាន់កាប់តំបន់នោះ ប្រជាជនចាមត្រូវបានបញ្ចូលជាមួយប្រជាជនខ្មែរ ។ នៅឆ្នាំ១៩៧៧ ប្រជាជនចាមត្រូវបានគេនាំទៅវត្តអូរត្រកួនដើម្បីសម្លាប់ ហើយគាត់បានពន្យល់ពីមូលហេតុនៃគោលនយោបាយប្រល័យពូជសាសន៍ថា បក្សកុម្មុយនីស្តកម្ពុជាចង់បានពូជសាសន៍បរិសុទ្ធតែមួយ ។

នៅក្នុងប្រធានបទចុងក្រោយ លោក គាំចាន់ បានផ្លាស់ទៅពិភាក្សាអំពីតួនាទីរបស់ជនជាប់ចោទដែលលោកបានហៅថា បងធំទាំងបី ។ គាត់បានបញ្ជាក់ថា បក្សកុម្មុយនីស្តកម្ពុជា គឺជារបបផ្តាច់ការ ដែលបងធំទាំង៣បានឡើងកាន់អំណាចតាមរយៈកងកម្លាំង និងការបោកបំភាន់ហើយគ្មានការបោះឆ្នោតទេលើកលែងតែការបោះឆ្នោតក្លែងក្លាយសម្រាប់សភាដែលដឹកនាំដោយ នួន ជា ។ ដូច្នេះ

*លោក គាំចាន់ បានសួរថា តើការសម្រេចចិត្តបានធ្វើឡើងយ៉ាងដូចម្តេចនៅក្នុងបរិយាកាសបែបនេះ?*

នៅក្នុងសៀវភៅ "ពិនិត្យពិច័យលើប្រវត្តិសាស្ត្រកម្ពុជា" របស់ ខៀវ សំផន គាត់បានសរសេរថានៅក្នុងរដ្ឋកុម្មុយនីស្ត គ្រប់ការសម្រេចទាំងអស់ត្រូវបានធ្វើឡើងនៅក្នុងក្របខណ្ឌថ្នាក់ដឹកនាំមជ្ឈិមហើយការសម្រេចចិត្តទាំងនេះត្រូវតែអនុវត្តដូចគ្នាដោយបុគ្គលម្នាក់ៗ ។ លោក គាំចាន់ បានកត់សម្គាល់ថាប្រាកដជាមានករណីដែលអ្នកដឹកនាំថ្នាក់ក្រោមធ្វើការសម្រេចចិត្តដោយសម្ងាត់ពីព្រោះថាថ្នាក់ដឹកនាំមិនអាចធ្វើការសម្រេចចិត្តទាំងអស់សម្រាប់កូនចៅគ្រប់រូបនោះទេ ប៉ុន្តែនោះមិនមែនបានន័យថា ខៀវ សំផន ឬ នួន ជា អាចជៀសផុតពីទំនួលខុសត្រូវមុខច្បាប់ ចំពោះគោលនយោបាយដែលពួកគេបានកំណត់ ឬឧក្រិដ្ឋកម្មដែលពួកគេបានអនុញ្ញាតឡើយ ។

បន្ទាប់មកលោក គាំចាន់ បានពិនិត្យក្របខណ្ឌនៃទំនួលខុសត្រូវនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ លក្ខន្តិកៈនៃបក្សកុម្មុយនីស្តកម្ពុជាបានចែងថា កងទ័ពទាំង៣ថ្នាក់របស់កម្ពុជាប្រជាធិបតេយ្យត្រូវតែស្ថិតក្រោមការគ្រប់គ្រងផ្តាច់មុខរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយតាមការសម្រេចចិត្តរបស់គណៈកម្មាធិការមជ្ឈិមចាប់ពីថ្ងៃទី៣០ ខែមីនាឆ្នាំ ១៩៧៦ បញ្ហាទីមួយដែលកងទ័ពនោះត្រូវធ្វើប្រតិបត្តិការដោះស្រាយនោះ គឺជាសិទ្ធិក្នុងការកម្ទេចសត្រូវខាងក្នុង និងខាងក្រៅជួរបក្ស ។ នេះក៏បង្ហាញដែរថា គោលដៅនេះគឺជាក្របខណ្ឌ ឬការអនុវត្តដាច់ខាតមួយរបស់បដិវត្តន៍របស់យើងដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យសង្គមនិយមរបស់យើង និងដើម្បីពង្រឹងសិទ្ធិអំណាចរដ្ឋរបស់យើង ។ លោក គាំចាន់ បានថ្លែងថា ខណៈពេលដែលសិទ្ធិក្នុងការសម្លាប់ត្រូវបានផ្ទេរទៅឲ្យគណៈកម្មាធិការភូមិភាគ ឬគណៈកម្មាធិការតំបន់ស្វយ័តដកមេយោធាដែលមានសិទ្ធិអំណាចស្មើនឹងភូមិភាគដែរ ។ នួន ជា និង ខៀវ សំផន មិនអាចគេចផុតពីទំនួលខុសត្រូវចំពោះបែបបទនៃការសម្លាប់ដែលត្រូវអនុវត្តដោយថ្នាក់ក្រោម នៅពេលដែលពួកគេត្រូវបានអនុញ្ញាតដោយជាក់លាក់ឲ្យធ្វើការសម្លាប់ទាំងនោះ ហើយការសម្លាប់ទាំងនោះធ្វើតាមគោលការណ៍ដែលកំណត់ដោយថ្នាក់មជ្ឈិម ។ ក្នុងនាមជាមេដឹកនាំថ្នាក់មជ្ឈិម ពួកគេបានអនុវត្តគោលនយោបាយឧក្រិដ្ឋកម្មតាមវិធីបី ៖

១) បញ្ហា និងការសម្រេចចិត្តដែលពួកគេបានដាក់ចេញ

២) សុន្ទរកថា និងការបើកវគ្គរៀនសូត្រ

៣) ជាឧទាហរណ៍ គ្មានកន្លែងណាអាចជាគំរូល្អជាងមន្ទីរស-២១ទេ ដោយសារវាជាកន្លែងដែលសូម្បីតែមនុស្សដែលស្និទ្ធនឹងនួន ជា និង ខៀវ សំផន ក៏ត្រូវបានចាប់យកទៅទីនោះដែរ ។

លោក គាំចាន់ បានបញ្ជាក់ថា មេដឹកនាំថ្នាក់មជ្ឈិមទាំងនេះបានកំណត់គំរូដ៏ច្បាស់លាស់អំពីគោលនយោបាយគ្មានមេត្តា និងឃោរឃៅ ដែលត្រូវបានអនុវត្ត ។ ចុងក្រោយ ពួកគេបានសម្លាប់គូប្រជែងណាដែលប្រឆាំងនឹងការគ្រប់គ្រងរបស់ពួកគេ ។

លោក គាំចាន់ បានបញ្ជាក់ទៀតថា ភូមិភាគទាំងឡាយតែងតែរាយការណ៍ និងទទួលបញ្ជាពីថ្នាក់មជ្ឈិម ហើយលេខាធិការទាំងឡាយក៏បានធ្វើដំណើរទៅរាជធានីភ្នំពេញដើម្បីចូលរួមវគ្គរៀនសូត្រ ។ ក្នុងបទសម្ភាសន៍មួយ ខៀវ សំផន បាននិយាយថា ប៉ុល ពត បានធ្វើការតាមប្រមាញ់ និងចាប់ខ្លួន ដោយមានការចូលរួមពីគណៈកម្មាធិការអចិន្ត្រៃយ៍ ពោលគឺគាត់មិនដែលធ្វើអ្វីតែឯងទេ ។ ខៀវ សំផន គួរតែដឹងរឿងនេះ ព្រោះគាត់ជាអ្នកជាប់ពាក់ព័ន្ធ ។ ខៀវ សំផន និង នួន ជា គឺជាសហការីជិតស្និទ្ធបំផុតរបស់ ប៉ុល ពត ។ លោក គាំចាន់ បានបញ្ជាក់ថាលោកមិនបាននិយាយថាអ្នកទាំងអស់គ្នាស្ថិតក្នុងចំណោមសហការីដែលជិតស្និទ្ធជាមួយ ប៉ុល ពត ទេ ប៉ុន្តែសហការីពីរនាក់ដែលស្និទ្ធជាងគេរបស់ ប៉ុល ពត គឺមានកំណត់ត្រឹមតែ ខៀវ សំផន និង នួន ជា ប៉ុណ្ណោះ ។ បងធំទាំង ៣ នាក់នេះគឺទទួលខុសត្រូវចំពោះគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា និងការអនុវត្តរបស់វា ។ ពួកគេបាននៅជាមួយ ប៉ុល ពត រហូតដល់ការចាប់ខ្លួន និងមរណភាពរបស់គាត់ ហើយពួកគេមិនដែលជំទាស់នឹង ប៉ុល ពត ឬនិយាយអាក្រក់ពី ប៉ុល ពត ទោះបីក្រោយទីបញ្ចប់របបក៏ដោយ ។ នួន ជា និង ខៀវ សំផន បានការពារគ្នាទៅវិញទៅមក ជាឧទាហរណ៍មានបញ្ជារបស់ នួន ជា ឲ្យ ឌុចដកសេចក្តីជាប់ពាក់ព័ន្ធនឹង ខៀវ សំផន នៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ ចេញ ។

អង្គរក្សរបស់ ប៉ុល ពត បានផ្តល់សក្ខីកម្មថា នួន ជា ខៀវ សំផន និង ប៉ុល ពត បានញ៉ាំអាហារបីពេលជាមួយគ្នាជារៀងរាល់ថ្ងៃ ។ ពួកគេបានធ្វើការជាមួយគ្នាជារៀងរាល់ថ្ងៃ ។ ពួកគេរស់នៅ

ជិតគ្នា ។ ខៀវ សំផន និយាយដូចគ្នាដែរថា សម្រាប់ជីវិតប្រចាំថ្ងៃ ពួកគេបីនាក់មិនដែលធ្វើអ្វីដោយឡែកពីគ្នាទេ ។ នួន ជា ក៏បាន និយាយដូចគ្នាដែរថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពួកគេទាំង បីនាក់បានហូបអាហាររបស់ពួកគេជាមួយគ្នាយ៉ាងទៀងទាត់ ។

កម្មាភិបាលជាន់ខ្ពស់ម្នាក់ ដែលជាអ្នកបកប្រែផ្ទាល់របស់ ប៉ុល ពត បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/១ ថា នួន ជា គឺជាបងធំទី២ ហើយ នួន ជា គឺជាបុរសដែលមានឥទ្ធិពលខ្លាំងជាង គេបន្ទាប់ពី ប៉ុល ពត ។ គាត់បានពណ៌នាថា នួន ជា ជាស្រមោល របស់ ប៉ុល ពត ។ ខៀវ សំផន បានពោលពីការគិតរបស់គាត់ថា ប៉ុល ពត គឺជាមេដឹកនាំដ៏អស្ចារ្យម្នាក់ ហើយនៅក្នុងបទសម្ភាស មួយ គាត់បានបង្ហាញទីកន្លែងដែល ប៉ុល ពត បានរស់នៅ ព្រមទាំង បានប្រាប់ថា គាត់បានដើរតាម ប៉ុល ពត គ្រប់ពេលដូចជា ស្រមោល ។ ដូច្នេះ ស្រមោលទាំងទ្វេបានតាមគាំទ្រ ប៉ុល ពត គ្រប់ពេលវេលាសូម្បីតែនៅមុនរបបកម្ពុជាប្រជាធិបតេយ្យក៏ ដោយ ។ ខៀវ សំផន ស្មោះត្រង់នឹង ប៉ុល ពត ហើយគាត់ថែមទាំង បញ្ចេញមនោសញ្ចេតនាពីរឿងនេះផង ដោយបាននិយាយថា គាត់នៅតែអាចមើលឃើញ ប៉ុល ពត នៅជួរភ្នំក្រវាញ ហើយ គាត់នឹក ប៉ុល ពត ណាស់ ព្រោះគាត់ជាមនុស្សមានចិត្តដ៏កម្រមួយ ។

នៅក្នុងខ្សែភាពយន្ត «នៅពីក្រោយវាលពិឃាត» នួន ជា និយាយអំពីដំណើរដែល ប៉ុល ពត បានឡើងកាន់អំណាច ។ នួន ជា បានស្នើសុំឲ្យ ប៉ុល ពត ដឹកនាំ ហើយ ប៉ុល ពត យល់ព្រម ប៉ុន្តែក្នុងលក្ខខណ្ឌដែលពួកគេនឹងធ្វើអ្វីៗទាំងអស់ជាក្រុម ។ នៅ ពេលគាត់ត្រូវបានសួរថា តើកាលនោះធ្លាប់មានជម្លោះរវាងគាត់ និង ប៉ុល ពត ឬទេ គាត់បានតបថាមិនដែលមានជម្លោះទេក្នុង ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។

បន្តទៀត លោក គាំចាន់ បានមានប្រសាសន៍ថា ចំពោះការ ជម្លៀសដោយបង្ខំ ការរស់នៅតាមសហករណ៍ មន្ទីរសន្តិសុខទាំង ១៩០កន្លែង ដែលមនុស្សត្រូវបានសម្លាប់ដោយគ្មានដំណើរការ កាត់ក្តី ដល់ការប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និង វៀតណាម លោក នួន ជា បញ្ជាក់ថា លោកគ្មានការខ្វែងគំនិតជា មួយ ប៉ុល ពត ទេ ។

នៅពេលដែល ខៀវ សំផន ត្រូវបានសួរពី «ការប្រឈម មុខនឹងការប្រល័យពូជសាសន៍» អំពី ប៉ុល ពត គាត់បាននិយាយថា ពួកគេ (សាធារណៈជន) និយាយថា ៖ ប៉ុល ពត គឺជាជនផ្តាច់ការ និងនិយាយអំពីការប្រល័យពូជសាសន៍របស់ ប៉ុល ពត ប៉ុន្តែគាត់ ជាមេដឹកនាំដ៏អស្ចារ្យ ហើយប្រសិនបើ ប៉ុល ពត បានប្រព្រឹត្តបែប នេះមែន នោះគាត់មិនអាចបង្កើតចលនាមួយបែបនេះបានឡើយ ។ ខៀវ សំផន ក៏បានថ្លែងដែរថា គាត់ចង់លើករឿងនេះមកបក ស្រាយក្នុងអង្គជំនុំជម្រះ ។

នួន ជា និង ប៉ុល ពត ក៏មានវេលាសម្រាប់ធ្វើស្វ័យទិតៀន ដែល ប៉ុល ពត តែងរិះគន់ នួន ជា ពីភាពរឹងរូសរបស់គាត់ ឯ នួន ជា តែងរិះគន់ ប៉ុល ពត ថាគាត់ងាយនឹងទុកចិត្តគេពេក ។ នួន ជា និង ខៀវ សំផន បានធ្វើសមាហរណកម្មចូលរដ្ឋាភិបាលក្នុងថ្ងៃតែមួយ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៨ ។ នួន ជា ក៏បានប្រាប់លោក ថេត សម្បត្តិ ថា មានចម្លើយសារភាពមួយពាក់ព័ន្ធនឹង ខៀវ សំផន ហើយ នួន ជា បានប្រាប់ឌុច មិនឲ្យរាយការណ៍ពីរឿងនេះម្តងទៀត ឡើយ ព្រមទាំងហាមមិនឲ្យរាយការណ៍ចម្លើយណាដែលមានការ ពាក់ព័ន្ធនឹង ខៀវ សំផន ទៀត ។

លោក គាំចាន់ បានបញ្ជាក់ថា ពួកគេទាំងបីនាក់នេះបាន បង្កើតជារង្វង់អំណាចមួយដែលទទួលខុសត្រូវចំពោះគោលនយោ បាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ក្នុងការឆ្លើយការពារខ្លួន លោក ខៀវ សំផន បានពឹងផ្អែក លើការអះអាងថា លោកមិនបានដឹងអំពីទាសភាព ឬការបន្សុទ្ធកម្ម ឬឧក្រិដ្ឋកម្មដទៃទៀតដែលកើតកំពុងកើតឡើងអំឡុងកម្ពុជាប្រជា ធិបតេយ្យទេ ។ ក្នុងខ្សែភាពយន្ត ពេលដែលគាត់ត្រូវបានសួរពី ចំនួនមនុស្សស្លាប់នៅក្នុងរបបខ្មែរក្រហម ខៀវ សំផន បានឆ្លើយថា មានចំនួនច្រើន ប៉ុន្តែមិនច្រើនដល់ថ្នាក់ពីរលាននាក់ទេ ចំនួននេះគឺ ជាការបំផ្លើសតែប៉ុណ្ណោះ ។ ទាក់ទងនឹងទំនួលខុសត្រូវផ្ទាល់ខ្លួន របស់គាត់ ខៀវ សំផន បានអះអាងថា គាត់គ្មានអំណាចអ្វីទាំងអស់ ហើយក៏មិនបានដឹងអ្វីទាំងអស់ ។ គាត់សួរខ្លួនឯងពីមូលហេតុដែល គាត់មិនដឹង ហើយនិយាយថាប្រហែលជាគាត់អាចត្រូវគេរិះគន់ ចំពោះការដែលគាត់រកមូលហេតុដែលមិនបានដឹង ប៉ុន្តែគាត់មិន បានព្យាយាមរកមូលហេតុទេ ដោយសារគាត់គោរពវិន័យបក្ស ។ ប៉ុន្តែ គាត់មិនមានអារម្មណ៍ថាគាត់ត្រូវបានបោកបញ្ឆោត ឬ

បោកប្រាស់ទេ ព្រោះថា ប៉ុល ពត មិនបានប្រាប់គាត់ពីអ្វីដែលកំពុងកើតឡើង ដោយសារតែ ប៉ុល ពត តែងតែត្រូវទាំងអស់ ហើយគាត់មានមូលហេតុសម្រាប់អ្វីគ្រប់យ៉ាង ។

លោក គាំចាន់ បាននិយាយថា ខៀវ សំផន បាននិយាយផ្ទុយនឹងសំដីខ្លួន ចំពោះការដែលគាត់និយាយថា ប៉ុល ពត មានមូលហេតុចំពោះអ្វីគ្រប់យ៉ាងដែលគាត់ធ្វើ ព្រោះថាម៉េចបានគាត់អាចដឹងរឿងហ្នឹងបាន បើគាត់មិនដឹងថាមានអ្វីកើតឡើង? លោក គាំចាន់ បានសួរបែបវោហាសាស្ត្រថាតើពួកគេទាំងបីនាក់និយាយគ្នាពីអ្វីនៅពេលពួកគេបានហូបអាហារពេលល្ងាចជាមួយគ្នា ដោយពិនិត្យឃើញថា វាមិនគួរឲ្យជឿសោះថា ពួកគេអាចនឹងនិយាយអំពីប្រធានបទដូចជាវប្បធម៌ពេញនិយម ឬកីឡា ហើយ "ពិតប្រាកដណាស់ ខៀវ សំផន បានដឹងពីអ្វីដែលកើតឡើង" ។

បន្ទាប់មក លោក គាំចាន់ បានពិនិត្យមើលអំពីប្រវត្តិរបស់ ខៀវ សំផន ខ្លះៗ ចំពោះបក្សកុម្មុយនីស្ត ហើយបានបញ្ជាក់សាជាថ្មីថា នៅពេលដែលលោក ខៀវ សំផន បានបញ្ជាក់ថាគាត់មិនមែនជាសមាជិករបស់បក្សទេ ហើយក៏មិនមែនជាមេដឹកនាំខ្មែរក្រហមដែរ ត្រង់កន្លែងនេះលោកកំពុងធ្វើការកុហកដើម្បីគេចពីទំនួលខុសត្រូវរបស់គាត់ចំពោះអ្វីដែលបានកើតឡើង ។

នៅក្នុងសៀវភៅរបស់គាត់ ខៀវ សំផន បាននិយាយថានៅឆ្នាំ១៩៧៨ គាត់បានដឹងពួអំពីអំពើឃោឃៅដោយសារតែសាច់ញាតិរបស់ប្រពន្ធគាត់ក៏បានទទួលរងគ្រោះដែរ ដូច្នេះគាត់បានបញ្ជាឲ្យដោះលែងសាច់ញាតិរបស់ប្រពន្ធគាត់ តែមិនបានធ្វើដូចនេះសម្រាប់អ្នកផ្សេងទៀតឡើយ ។ បុគ្គលប្រាំបួននាក់ដែល ខៀវ សំផន ជាអ្នកទទួលខុសត្រូវត្រូវបានសម្លាប់នៅចុងបញ្ចប់នៃរបបនេះ ហើយបុគ្គលមួយចំនួនពីគណៈកម្មាធិការអចិន្ត្រៃយ៍ដែលគាត់ធ្វើការជាមួយក៏ត្រូវបានសម្លាប់ដែរ ដូច្នេះបានន័យថាគាត់ពិតជាបានដឹងពីរឿងនៃការសម្លាប់ ។

ខៀវ សំផន បានប្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា គាត់ត្រូវបានគេអញ្ជើញម្តងឬពីរដងក្នុងមួយខែដើម្បីចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ដែលត្រូវបានបង្កើតឡើងដោយ ប៉ុល ពត ។ ខៀវ សំផន បាននិយាយថា កិច្ចប្រជុំទាំងឡាយមានភាពរាក់ទាក់ណាស់ ហើយគ្រប់គ្នាបានចុះសម្រុងគ្នាយ៉ាងល្អនៅក្នុងកិច្ចប្រជុំទាំងនោះ ។

លោកបានបង្ហាញក្រាហ្វិចដែលពណ៌នាពីអ្នកដែលបានចូលរួមច្រើនជាងគេក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ។ នួន ជា ជាអ្នកបានចូលរួមច្រើនបំផុត (១៨ដង) តទៅដោយ ប៉ុល ពត (១៧ដង) ខៀវ សំផន (១៦ដង) ជឿន (ត្រូវបានកម្ទេច) (១២ដង) អៀង សារី (១០ដង) សុន សេន (១០ដង) វន វេត (ត្រូវបានសម្លាប់) (៩ដង) កុយ ធួន (ត្រូវបានសម្លាប់) (៦ដង) សោ ភឹម (០) និងតាម៉ុក (០ដង) ។ លោក គាំចាន់ បានពន្យល់ថាក្នុងចំណោមសមាជិកទាំង៥នាក់ដែលមិនត្រូវបានកម្ទេច អៀង សារី និង សុន សេន ច្រើនតែនៅឆ្ងាយ ដែល អៀង សារី ធ្វើដំណើរទៅបរទេស ហើយ សុន សេន ទៅតំបន់បូព៌ា ។ នៅពេលដែលការធ្វើបន្សុទ្ធកម្មចាប់ផ្តើមឡើងសល់តែ នួន ជា ខៀវ សំផន និង ប៉ុល ពត ប៉ុណ្ណោះជាអ្នកទទួលខុសត្រូវ នេះបង្ហាញថាឥទ្ធិពល និងការចូលរួមពាក់ព័ន្ធរបស់ ខៀវ សំផន បានកើនឡើងជាលំដាប់ ។

អ្នកជំនាញម្នាក់បានកត់សម្គាល់ពីការជាប់ពាក់ព័ន្ធរបស់ ខៀវ សំផន នៅក្នុងការបោសសំអាតដែលមានលក្ខណៈការិយាធិបតេយ្យ ជាទូទៅមុខងាររបស់គាត់ក្នុងជួរបក្សទទួលខុសត្រូវចំពោះការរក្សានិរន្តរភាពនៃការអនុវត្តគោលនយោបាយស្របគ្នានឹងការផ្លាស់ប្តូរមុខងារជាអាទិភាពរបស់ ប៉ុល ពត ពីការកសាងសេដ្ឋកិច្ចឡើងវិញមកការប្រមាញ់សត្រូវ ។ ការផ្លាស់ប្តូរដោយផ្តល់អាទិភាពខ្ពស់បំផុតចំពោះការងារបោសសម្អាតសត្រូវដែលត្រូវបានផ្សព្វផ្សាយនៅក្នុងបក្សដោយ នួន ជា ។

លោក គាំចាន់ បានផ្ទេរសិទ្ធិនិយាយដល់សហព្រះរាជអាជ្ញាជាតិ គឺលោកស្រី ជា លាង ដែលនឹងថ្លែងទៅកាន់អង្គជំនុំជម្រះអំពីការផ្តន្ទាទោស ។

លោកស្រី លាង បានស្នើសុំបញ្ចប់ការដាក់សំណើរបស់ក្រុមព្រះរាជអាជ្ញាដោយការស្នើសុំផ្តន្ទាទោស នួន ជា និង ខៀវ សំផន ពីបទចូលដៃក្នុងឧក្រិដ្ឋកម្មនៃការប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដូចដែលបានបង្ហាញហេតុផលក្នុងការសង្ខេបរបស់ក្រុមព្រះរាជអាជ្ញា ។ ក្រុមព្រះរាជអាជ្ញាបានបង្ហាញថា សម្អាងលើមូលដ្ឋាននៃគុណភាព និងចំនួននៃភស្តុតាង នេះគឺជាសេចក្តីសន្និ

ដ្ឋានតែមួយគត់ដែលសម្រេចចេញមកប្រកបដោយភាពពិតប្រាកដផ្អែកលើភ័ស្តុតាង ។

លោកស្រី ជា លាង បានបញ្ជាក់ថា ភ័ស្តុតាងបានបង្ហាញថា ជនជាប់ចោទទាំងពីរនាក់នេះគឺជាអ្នកនាំមុខក្នុងតួនាទីជាអ្នកប្រតិបត្តិមនោគមវិជ្ជា ស្ថាបត្យករ អ្នកគ្រោងការ និងជាអ្នកអនុវត្តគោលនយោបាយបក្សកុម្មុយនីសកម្ពុជានូវប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធដ៏ខ្លាំង និងឃោរឃៅបំផុតនៃការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និងឃោរឃៅបំផុតនៅក្នុងចំណោមប្រទេសនានានៅសតវត្សរ៍ទី២០ ។ នៅពេលឡើងកាន់អំណាចភ្លាម ជនជាប់ចោទបានធ្វើការវាយប្រហារទៅលើប្រជាជនកម្ពុជា ដែលការពិតពួកគេមានទំនួលខុសត្រូវក្នុងការការពារប្រជាជនទាំងនោះសោះ ។ នៅក្នុងសតិរបស់ពួកគេ ការរក្សាអំណាចដោយដាច់ខាត និងការសម្រេចឲ្យបាននូវចក្ខុវិស័យនៃពិភពសង្គមនិយមដ៏ស្រមើស្រមៃមួយ គឺមានសារសំខាន់ជាងការការពារសិទ្ធិមនុស្សមូលដ្ឋានដ៏សំខាន់ដែលពួកគេបានជំពាក់ដល់ប្រជាជនកម្ពុជាទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងរយៈពេលបីឆ្នាំ ប្រាំបីខែ ២០ថ្ងៃនៃរដ្ឋាភិបាលរបស់ពួកគេ ពួកគេបានប្រានចោលកាតព្វកិច្ចរបស់ប្រទេសកម្ពុជា និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ហើយបែរជាធ្វើការវាយប្រហារដោយចេតនាលើសិទ្ធិមនុស្សមូលដ្ឋានរបស់កម្ពុជាទៅវិញ ។

លោកស្រី ជា លាង បានបញ្ជាក់ទៀតថា ជនជាប់ចោទបានដកហូតពីប្រជាជនកម្ពុជានូវសិទ្ធិនៃការរស់រានមានជីវិត ការទទួលបានការគាំពារផ្លូវកាយ ការជំនុំជម្រះក្តីដោយយុត្តិធម៌ សេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការធ្វើដំណើរ សិទ្ធិក្នុងការអនុវត្តសាសនាតាមជំនឿរបស់ខ្លួន សិទ្ធិមានគ្រួសារ សិទ្ធិរៀបអាពាហ៍ពិពាហ៍ សិទ្ធិធ្វើការងារ សិទ្ធិសម្រាក សិទ្ធិទទួលបានដោយគ្រប់គ្រាន់នៃអាហារ និងទឹក ការថែទាំសុខភាព អនាម័យ និងផ្ទះសម្បែងក្នុងចំណោមសិទ្ធិផ្សេងៗទៀត ។

លោកស្រី ជា លាង បានអះអាងថា ខៀវ សំផន និង នួន ជា មានអំណាចដាច់ខាតក្នុងការធ្វើអ្វីដែលពួកគេចង់ធ្វើចំពោះប្រជាជនកម្ពុជា ហើយពួកគេបានធ្វើដូច្នេះឯង ។ ពួកគេបានបង្ខំឲ្យប្រជាជនចាកចេញពីលំនៅដ្ឋានរបស់ពួកគេ ហើយបង្ខំឲ្យធ្វើការនៅក្នុងជំរំការងារនៅទូទាំងប្រទេស ក្នុងស្ថានភាពអមនុស្សធម៌ដ៏អាក្រក់ ពួកគេបានបំបែកគ្រួសារដើម្បីឥទ្ធិពល និងកម្លាំងគ្រួសារចុះខ្សោយ ពួកគេបានបង្ខំឲ្យប្រជាជនរៀបការ និងរួមភេទផ្ទុយនឹងឆន្ទៈ ។ ពួកគេបានធ្វើទុកបុកម្នេញទៅលើសត្រូវនយោបាយជាច្រើនរួមមាន អតីតមន្ត្រីរាជការ និងមន្ត្រីស៊ីវិលនៃរបប លន់ នល់ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា បុគ្គលិកក្រសួងនានានៃរបបកម្ពុជាប្រជាធិបតេយ្យ ជនជាតិចាម ពុទ្ធសាសនិក និងជនជាតិវៀតណាម ។ ការធ្វើទុកបុកម្នេញត្រូវបានធ្វើឡើងតាមរយៈការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងសកម្មភាពអមនុស្សធម៌ដទៃទៀតទាំងក្នុង និងក្រៅមន្ទីរសន្តិសុខដែលត្រូវបានបក្សកុម្មុយនីសកម្ពុជាចំណាយយ៉ាងច្រើន ។

លោកស្រី ជា លាង បានបញ្ជាក់ទៀតថា ប្រព័ន្ធរំលោភបំពានដោយចេតនានេះត្រូវបានអនុវត្តនៅគ្រប់ភូមិភាគ និងការិយាល័យទាំងអស់ក្នុងអំឡុងពេលដែលជនជាប់ចោទបានកាន់អំណាច ។ ទោះបីបើមានអ្នកដែលមានសំណាងបានរស់នៅឆ្លងកាត់របបនេះក៏ដោយ ក៏ជនជាប់ចោទនៅតែធានាថាពួកគេមិនអាចបន្ធូរលក្ខខណ្ឌដែលដាក់លើអ្នកទាំងនោះបានឡើយ ។

លោកស្រី ជា លាង បានធ្វើការបញ្ជាក់តទៀតថា ជនជាប់ចោទបានទម្លាក់ប្រជាជនកម្ពុជាចូលក្នុងភាពឈឺចាប់ ។ កម្រិតយ៉ាងខ្ពស់នៃប្រព័ន្ធនៃការរំលោភបំពាន និងការអនុវត្តដោយឥតកោតក្រែងដោយជនជាប់ចោទ បានបង្កើតឡើងនៅក្នុងបរិយាកាសមួយពោរពេញដោយភាពភិតភ័យ និងភាពទន្ទឹងតក់ស្លុតក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដោយពួកគេគិតថាពួកគេនឹងត្រូវបានសម្លាប់ឬធ្វើទុកបុកម្នេញនៅពេលណាមួយ ។ នេះបានធ្វើឲ្យប្រជាជនកម្ពុជាមានផលប៉ះពាល់យូរអង្វែងខាងផ្លូវកាយ និងផ្លូវចិត្តដែលនឹងនៅបន្តសេសសល់ពេញមួយជីវិតរបស់ពួកគេ ។

លោកស្រី ជា លាង បានបញ្ជាក់ទៀតថា ជនជាប់ចោទទាំងពីរនាក់ស្ថិតនៅជនកំពូលនៃរដ្ឋអំណាចបក្សកុម្មុយនីស្តកម្ពុជា ហើយពួកគេទាំងពីរនាក់បានធ្វើការរួមចំណែកយ៉ាងសំខាន់ យ៉ាងធំធេង និងយ៉ាងជិតដល់ ។ នួន ជា គឺជាអ្នកទទួលខុសត្រូវខ្ពស់ទី២ ហើយលោក ខៀវ សំផន ជាប្រមុខរដ្ឋ លើសពីការកាន់តួនាទីផ្សេងទៀតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីសកម្ពុជា ។ ថ្នាក់ដឹកនាំកំពូល គឺសំខាន់ក្នុងការគ្រោងបង្កើត និងការអនុវត្តគោល

នយោបាយឧក្រិដ្ឋកម្មទាំងនេះ ។ ជនជាប់ចោទទាំងពីរនាក់បានរំលោភបំពានអំណាចរបស់ពួកគេយ៉ាងធ្ងន់ធ្ងរ ។ សម្រាប់បុគ្គលទាំងពីរនេះ ឲ្យតែទទួលបានលទ្ធផលដែលពួកគេចង់បាន ត្រូវប្រើប្រាស់វិធីណាក៏ត្រឹមត្រូវដែរ ទោះជាវិធីនោះឃោរឃៅយង់ឃ្នងយ៉ាងណាក៏ដោយ ។

លោកស្រី ជា លាង បានស្នើសុំឲ្យគ្មានការអត់ឱនចំពោះការផ្តន្ទាទោសចំពោះបុគ្គលទាំងនេះទេ ទោះបីដោយសារអាយុ ការអប់រំ និងសមត្ថភាពផ្លូវចិត្តក៏ដោយ ។ នួន ជា មានអាយុ៤៨ឆ្នាំ ហើយ ខៀវ សំផន មានអាយុ៤៣ឆ្នាំ នៅពេលដែលពួកគេកាន់អំណាច ពួកគេទាំងពីរបានសិក្សាច្បាប់នៅបរទេស ។ បុគ្គលទាំងនេះគឺជាមនុស្សដែលមានចំណេះដឹង ដែលដឹងពីផលវិបាកនៃសកម្មភាពរបស់ពួកគេ ។ ពួកគេមានវិជ្ជាជីវៈការសិក្សា និងបំនិនជីវិតដើម្បីគ្រប់គ្រងឥរិយាបថរបស់មនុស្ស ហើយពួកគេក៏មិនគួរទទួលបានការអត់ឱនដោយសម្អាងលើមូលដ្ឋាននៃការអះអាងរបស់ពួកគេថា ពួកគេស្ថិតនៅក្រោមការគាបសង្កត់ ។ ផ្ទុយពីករណីមន្ទីរស-២១ ដែលកម្មាភិបាលទីនោះស្ថិតក្រោមសម្ពាធដែលបើពួកគេមិនសម្លាប់អ្នកផ្សេងទេ ពួកគេនឹងត្រូវបានសម្លាប់ ជនជាប់ចោទទាំងនេះមិនស្ថិតក្រោមសម្ពាធបែបនេះទេ ហើយពួកគេបានបង្កើតបរិយាកាសភិតភ័យ និងរន្ធត់តក់ស្លុត ។ ពួកគេក៏មិនគួរត្រូវបានផ្តល់ភាពអត់ឱនឲ្យដោយសវនាការ ធ្វើការសហការជាមួយអង្គជំនុំជម្រះវិសាមញ្ញដែរ ។ ពួកគេមិនបានផ្តល់ជាជំនួយសំខាន់មួយណា ក្រៅពីការចូលរួមរបស់ពួកគេនៅក្នុងការស៊ើបអង្កេត និងជំនុំជម្រះឡើយ ។ ពួកគេមិនដែលបង្ហាញពីវិប្បដិសារីទេ ផ្ទុយទៅវិញពួកគេបានទាំងនិពន្ធសៀវភៅដែលបង្ហាញពីឥរិយាបថរបស់ពួកគេជាជាងការសុំទោសចំពោះទង្វើរបស់ពួកគេ ។

លោកស្រី ជា លាង បានពន្យល់ថា ខៀវ សំផន មានទស្សនៈថាគាត់មិនបានធ្វើអ្វីបន្តិចណាសោះដែលធ្វើឲ្យគាត់មានការអាម៉ាស់មុខចំពោះនរណាម្នាក់ ។ ថ្វីបើ នួន ជា ទទួលខុសត្រូវផ្លូវសីលធម៌ចំពោះអ្វីដែលបានកើតឡើងក៏ដោយ ក៏គាត់បដិសេធមិនទទួលខុសត្រូវផ្ទាល់ចំពោះសកម្មភាពរបស់គាត់ដែរ ។ គួរឲ្យសោកស្តាយ ដែលគាត់បាននិយាយថា ប្រសិនបើគាត់ចាប់ជាតិវិញ គាត់នឹងធ្វើបដិវត្តន៍ម្តងទៀត ។ ចំពោះការពិតដែលជនជាប់ចោទមិនព្រមបោះបង់ជំនឿរបស់ខ្លួនដែលថា ពួកគេមានសិទ្ធិជ្រើសរើសលើការស្លាប់ឬរស់ និងបែបបទការរស់នៅរបស់មនុស្ស បានបង្ហាញពីកង្វះសុទ្ធសាធនូវវិប្បដិសារី និងការយល់ដឹងខុសពីការដែលសង្គមសុខដុមរមនាមួយគួរមានលក្ខណៈយ៉ាងម៉េច ដែលការពិតសង្គមសុខដុមរមនាគឺជាសង្គមមួយដែលគេស្រឡាញ់អបអរ មិនមែនជាសង្គមដែលគេនិយាយសម្អប់ឡើយ ។ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអំណាច និងមនុស្សជាតិនេះ ត្រូវតែទទួលការថ្កោលទោសយ៉ាងធ្ងន់ធ្ងរដោយតុលាការនេះ ។

ក្រុមព្រះរាជអាជ្ញាបានដាក់សំណើអះអាងថា ការផ្តន្ទាទោសដែលស័ក្តិសមតែមួយគត់គឺការជាប់ពន្ធនាគារអស់មួយជីវិត ។ តាមរយៈការកាត់ទោសនេះ វានឹងឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយជនជាប់ចោទ និងតួនាទីសំខាន់របស់ពួកគេ ។

លោកស្រី ជា លាង ទទួលស្គាល់ថា ការសម្រេចសេចក្តី និងការផ្តន្ទាទោសនេះនឹងមិននាំយកអ្នកដែលបានត្រូវគេសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រឡប់មកវិញទេ ហើយក៏មិនដកស្នាមរបួសរបស់អ្នកដែលបានរងគ្រោះក្នុងអំឡុងពេលនេះដែរ ។ ទោះយ៉ាងណាក៏ដោយ ព្រះរាជអាជ្ញាសង្ឃឹមថា ការកាត់ក្តីនេះនឹងផ្តល់នូវយុត្តិធម៌មួយកម្រិតដល់ជនរងគ្រោះ និងជួយទប់ស្កាត់ការកកើតឡើងនៃឧក្រិដ្ឋកម្មទាំងនេះឡើងវិញនាពេលអនាគត ដោយបង្ហាញថាគ្មាននរណាម្នាក់អាចនៅពីលើច្បាប់ដោយសំអាងលើឋានៈ ឬតំណែងបានឡើយ ។

លោកស្រី ជា លាង បានស្នើសុំថា នៅពេលអង្គជំនុំជម្រះចេញសាលក្រម ការសម្រេចសេចក្តីនឹងមានសេចក្តីលម្អិតទាំងអស់អំពីការចោទប្រកាន់ និងការពិត និងមូលដ្ឋាននៃសេចក្តីរកឃើញ ។ តាមរយៈការធ្វើដូច្នេះ ការសម្រេចសេចក្តីនេះអាចផ្តល់ជាមេរៀនដ៏សំខាន់ដល់មនុស្សជំនាន់ក្រោយ និងរដ្ឋាភិបាលកម្ពុជាស្តីពីការពិតនៃសម័យកាលខ្មែរក្រហម និងការយល់ដឹងច្បាស់លាស់ពីកាលៈទេសៈដែលនាំឲ្យកើតមានឧក្រិដ្ឋកម្មដ៏សាហាវឃោរឃៅ ដើម្បីកុំឲ្យឧក្រិដ្ឋកម្មទាំងនេះអាចកើតឡើងម្តងទៀត ។

**រ៉ូនិត អារី**

# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ : ០០ ព្រឹក*

*ទីតាំង : អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង : ស៊ាង ចិន្តា ទូរសព្ទលេខ : ០២៣ ២១១ ៨៧៥ អ៊ីម៉ែល : truthchenda.s@dccam.org*

# រូបសំណាករម្លឹកអំពីការចងចាំ

ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ រូបសំណាករម្លឹកអំពីការចងចាំរបបខ្មែរក្រហម ដែលសិល្បករ និងអ្នករចនារូបសំណាក លោក អ៊ឹង គូសេរ៉ា ជាកូនខ្មែរកាត់បារាំងបាន ហៅឈ្មោះថា "អ្នកអង្គុរលន់តួ" ឬជាបូជនីយដ្ឋាន "សម្រាប់អ្នកដែលលែងនៅទីនេះទៀតហើយ" ត្រូវបានសម្ពោធ និងដាក់តាំងជាផ្លូវការ នៅសួនច្បារទល់មុខស្ថានទូតបារាំង ក្នុងរាជធានីភ្នំពេញ ។ រូបសំណាករម្លឹកពីការចងចាំនេះ ក៏ជាផ្នែកមួយនៃសំណងដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២,០១ ផ្តោតលើការកសាងបូជនីយដ្ឋានរំលឹកការចងចាំនៅក្នុងទីក្រុងភ្នំពេញ ផ្តល់ការគោរពដល់ជនរងគ្រោះនៃការជម្លៀសដោយបង្ខំ ដែលត្រូវទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានចេញនៅក្នុងសេចក្តីសម្រេចរបស់តុលាការនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ។



"រូបសំណាក់អ្នកអង្គុរលន់តួ" ឬជាបូជនីយដ្ឋាន "សម្រាប់អ្នកដែលលែងនៅទីនេះទៀតហើយ" នៅមុខស្ថានទូតបារាំង ក្រុងភ្នំពេញ ។

ជាមួយគ្នានេះដែរ សាលារាជធានីភ្នំពេញ បានអនុញ្ញាតឲ្យកសាង និងដាក់តាំងរូបសំណាកនេះ ដែលគម្រោងនេះ ក្រោមការឧបត្ថម្ភពីដៃគូសប្បុរសជន ដូចជា ស្ថានទូតបារាំងប្រចាំនៅព្រះរាជាណាចក្រកម្ពុជា, វិទ្យាស្ថានស៊ីកវិត, សមាគមអាន់វ៉ៃយ៉ា និងអនុស្សាវរីយ៍ធំ និងដៃគូសប្បុរសជនជាច្រើនទៀត ។

ជាជនរងគ្រោះម្នាក់ក្នុងអំឡុងពេលខ្មែរក្រហមបានធ្វើការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ នៅថ្ងៃ១៧ មេសា ១៩៧៥ សិល្បករ សេរ៉ា ដែលពេលនោះ មានវ័យ១៣ឆ្នាំ បានបែកពីឪពុកនៅមុខស្ថានទូតបារាំង (កន្លែងដាក់តាំងរូបសំណាកបច្ចុប្បន្ន) ជាទីដែលត្រូវគាត់បានឃើញឪពុកជាលើកចុងក្រោយ ។ នៅពេលដែលខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញ ក្រុមគ្រួសាររបស់ សេរ៉ា បានសុំសិទ្ធិជ្រកកោនក្នុងស្ថានទូតបារាំងប្រចាំក្រុងភ្នំពេញ ។ ឪពុករបស់គាត់ជាពាណិជ្ជករខ្មែរដែលចេះនិយាយបានច្រើនភាសា និងធ្លាប់បានទៅសិក្សានៅប្រទេសបារាំងផង ។ សេរ៉ា និងម្តាយ រួមទាំងបងប្អូន ត្រូវបានអនុញ្ញាតឲ្យចាកចេញពីប្រទេសកម្ពុជា លើកលែងតែឪពុកដែលមានដើមកំណើតខ្មែររបស់ សេរ៉ា តែប៉ុណ្ណោះដែលមិនត្រូវបានអនុញ្ញាតឲ្យចាកចេញ ហើយត្រូវបានខ្មែរក្រហមចាប់ខ្លួនយកទៅ ។ ក្រោយមក សេរ៉ា ក៏ទទួលដំណឹងថាឪពុករបស់គាត់ ត្រូវបានខ្មែរក្រហមសម្លាប់នៅឆ្នាំ១៩៧៨ ។

រូបសំណាករម្លឹកដល់ការចងចាំនេះ សិល្បករ សេរ៉ា បង្កើតឡើងក្នុងគោលបំណង សម្តែងការគោរពដល់ជនរងគ្រោះនៃរបបខ្មែរក្រហម និងជាផ្នែកមួយនៃគម្រោងសំណង ដែលសម្រេចដាក់បញ្ចូលដោយតុលាការ ដែលទទួលខុសត្រូវលើការនាំយកអតីតមេដឹក នាំរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមមកកាត់ទោស ។ ការដាក់តាំងរូបសំណាកនេះ នៅរាជធានីភ្នំពេញ គឺជាបង្ហាញពីជំហានបន្ទាប់នៃការទទួលស្គាល់ជាសាធារណៈអំពីឧក្រិដ្ឋកម្មដែលបានបង្កឡើង ព្រមទាំងផលប៉ះពាល់ដែលកើតមានចំពោះជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ រូបសំណាកនេះ បានរម្លឹកពីភាព

ភ័យរន្ធត់ ជាក់ស្តែងរបស់ប្រជាជនកម្ពុជាក្នុងរបបខ្មែរក្រហម ដែលនៅតែបន្តលងបន្លាចប្រជាជនកម្ពុជាទាំងក្នុង និងក្រៅប្រទេស រហូតដល់បច្ចុប្បន្ន និងកំពុងជ្រាបរាលដាលដល់កូនចៅជំនាន់ក្រោយ របស់ជនរងគ្រោះកម្ពុជា ។ ការតម្កល់នៅទីតាំងសាធារណៈនេះ បាន ផ្តល់ជាសារមួយនៃសន្តិភាព និងការផ្សះផ្សាថ្នាក់ជាតិដល់ជនរួម ជាតិ ។ លើសពីនេះ ការដាក់បង្ហាញស្នាដៃសិល្បៈ នៅទីសាធារណៈ ក៏ជាការលើកទឹកចិត្តដល់សាធារណជនឲ្យជួបជុំគ្នា ដើម្បីរម្លឹកពីការ ចងចាំ និងខ្ទិសដល់មនុស្សជាទីស្រឡាញ់ដែលបានចែកឋានទៅ ហើយ ។ យុវជន យុវនារី កម្ពុជាជំនាន់ក្រោយ ក៏គួរតែស្វែងយល់ពី បទពិសោធរបស់ឪពុកម្តាយ និងជីដូនជីតារបស់ខ្លួន ដើម្បីឲ្យអ្នកទាំង នោះជាប់ទំនាក់ទំនងគ្នាតាមរយៈការយល់ដឹងពីអំពើប្រល័យពូជ សាសន៍ និងរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ។ រឿងរ៉ាវទាំងនេះត្រូវបាននិយាយតៗគ្នាពីមួយជំនាន់ទៅមួយជំនាន់ ។

រូបសំណាកនេះ បានខ្ទិសដល់អ្នកដែលលែងនៅទីនេះទៀត ហើយ ប្រហែលជាទាក់ទងនឹងរបបប្រល័យពូជសាសន៍មានលក្ខណៈ គួរឲ្យខ្លាច និងគួរឲ្យតក់ស្លុត ។ ប៉ុន្តែ រូបចម្លាក់ "អ្នកអង្វរក" បែរជា បណ្តាលឲ្យអ្នកទស្សនាមានអារម្មណ៍ទន់ភ្លន់ និងស្រស់ស្រាយទៅវិញ ។ ដោយគ្រាន់តែក្រលេកមួយភ្លែត យើងនឹងព្យាយាមវិភាគថា តើ វាជារូបស្រី ឬរូបប្រុស តែរូបចម្លាក់នេះបង្ហាញពីមនុស្សជាតិ ជាង បង្ហាញពីលក្ខណៈភេទ ។ រំពេចនោះយើងមានអារម្មណ៍ថា រូបចម្លាក់ មានភាពប្រហាក់ប្រហែលនឹងយើងយ៉ាងខ្លាំង ដោយរូបរាងដែល ហាក់បីដូចជាមនុស្សកំពុងតែធ្លាក់ពីលើទីខ្ពស់របស់រូបចម្លាក់នោះ ។ រូបចម្លាក់ ធ្វើឲ្យធ្វើឲ្យអ្នកទស្សនាមានអារម្មណ៍អាណិតអាសូរពីភាព ឆាយរងគ្រោះរបស់វា ហើយរូបចម្លាក់នេះធ្វើឲ្យយើងរឹតតែចង់ដឹង ចង់ស្គាល់ថែមទៀត ។

ការដាក់រូបនោះលើជើងទម្រទាបមានន័យថា សូម្បីតែ ក្មេងៗក៏អាចឈោងប៉ះ និងគយគន់ពិនិត្យមើលរូបនេះដោយ ផ្ទាល់ដែរ ។ ផ្ទៃនៃរូបចម្លាក់នេះមានលក្ខណៈគ្រើមដូចសំបកឈើ ដែលធ្វើឲ្យយើងកាន់តែចង់ប៉ះ និងទំនាក់ទំនងជាមួយរូបចម្លាក់ នេះ ។

ពេលដែលយើងកាន់តែស្ងឹងស្មាធបញ្ចូលអារម្មណ៍គិតដល់ រូបចម្លាក់នេះ យើងកាន់តែចង់ទៅលួងលោមរូបនេះ ។ តើយើងមិន អាចទៅចាំទ្រូរូបនេះនៅពេលដែលវាធ្លាក់បានឬទេ? យ៉ាងហោច ណាស់យើងអាចបោសអង្អែលរូបនោះ ក៏ដូចជាគយគន់ទុក្ខសោក និងភាពឯកោរនៃរូបចម្លាក់ ហើយក្នុងពេលតែមួយបង្ហាញពីអារម្មណ៍ ស្រដៀងគ្នាដែល យើងកំពុងតែមានជាមួយនឹងរូបចម្លាក់នេះ ។ ខណៈ យើងធ្វើបែបនោះយើងនឹងដឹងក្នុងចិត្តថា តាមការពិតយើងកំពុង តែចងចាំ និងលួងលោមជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ ហើយ យើងកំពុងតែមានជាប់ទំនាក់ទំនងជាមួយនឹងជនរងគ្រោះ ទាំងនោះ តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនរបស់យើង ។

ដៃរបស់រូបចម្លាក់នេះ ដាក់ប្រណមចូលគ្នាក្នុងទម្រង់ជា កាយវិការសំពះអង្វរក ។ ប្រហែលជារូបចម្លាក់នេះកំពុងតែសូម អង្វរព្រះព្រោះថា រូបនេះកំពុងតែមើលទៅកាន់ឋានសួគ៌ ។ ប៉ុន្តែ សោកនាដកម្មនៃអំពើប្រល័យពូជសាសាន៍កម្ពុជា បានប្រឡែង លេងនឹងជំនឿរបស់មនុស្សចំពោះព្រះដែលទ្រង់អាចអនុញ្ញាតឲ្យ មានព្រឹត្តិការណ៍ប្រល័យពូជសាន៍នេះកើតឡើងបានដែលធ្វើឲ្យ មនុស្សស្លូតត្រង់យ៉ាងច្រើននាក់ត្រូវរងទុក្ខវេទនា ។

ទម្រង់នៃការធ្លាក់ចុះ និងការអង្វរកទៅការឋានសួគ៌របស់ រូបចម្លាក់នេះ បានបន្តប់ទៅដោយភាពស្រស់ស្អាត និងថ្លៃថ្នូរ ។ ទម្រង់ដាក្បាលចុះក្រោមរបស់រូបនោះ បង្កើតនូវរូបភាពនៃការ អស់សង្ឃឹមមួយ តែហេតុអ្វីបានជាយើងមិនបង្វែររូបនេះឲ្យមាន ទម្រង់ត្រឹមត្រូវក្នុងចិត្តរបស់យើង ហើយធ្វើឲ្យអ្វីៗត្រឹមត្រូវឡើង វិញទៅ? ពេលនោះយើងនឹងឃើញថា រូបចម្លាក់នេះកំពុងតែដើរ លើពពក ដោយលើកដៃសំពះតាមបែបប្រពៃណីខ្មែរ ។ ឬក៏រូបនេះ ជារូបអប្សរាដែលកំពុងតែរាំអណ្តែតអណ្តូង តើអាយុរបស់អប្សរា រូបនេះត្រូវកាត់បន្ថយឬ? រូបចម្លាក់នេះត្រូវបានដកផ្តាច់ផុតចេញ ពីដី ដែលជារូបភាពដែលគួរឲ្យព្រួយបារម្ភមួយសម្រាប់ប្រជាជន កម្ពុជា ដែលមានពូជពង្សជាអ្នកធ្វើកសិកម្មដោយទំនាក់ទំនងជា មួយដីយ៉ាងស្អិតរមួត ។ តើនេះជារូបស្រីម្នាក់ ដែលឆ្លុះបញ្ចាំងពី សង្គមមាតាធិបតេយ្យរបស់កម្ពុជាមែនដែរឬទេ? រូបចម្លាក់នេះ ធ្វើឡើងពីលង្ហិនដែលជាលោហៈម្យ៉ាង ដែលសិល្បៈករខ្មែរសម័យ អង្គរតែងតែប្រើប្រាស់ដើម្បីធ្វើជារូបចម្លាក់ និងត្រូវស្គាល់ដោយ ប្រជាជនកម្ពុជាគ្រប់រូប ។ ដូច្នេះហើយ ខណៈពេលដែលរូបចម្លាក់ នេះបង្ហាញពីភាពឯកកោយ៉ាងជាក់ស្តែង រូបចម្លាក់អ្នកអង្វរកនេះ

ក៏បានផ្សារភ្ជាប់ទស្សនិកជនទៅកាន់អតីតកាល និងស្រុកកំណើតរួមរបស់អ្នកទាំងនោះ ក៏ដូចជាបានផ្សារភ្ជាប់ប្រជាជនខ្មែរទាំងអស់គ្នាដែរ ។

គួរឲ្យសោកស្តាយចំពោះ សេរ៉ា ព្រោះថារូបចម្លាក់នេះស្ថិតនៅចំកន្លែងដែលគាត់ បានឃើញមុខឪពុករបស់គាត់ជាលើកចុងក្រោយ ហើយ សេរ៉ា សូមគោរពអញ្ជើញប្រជាជនកម្ពុជាទាំងអស់គ្នាមកចូលរួមជាមួយគាត់ ក្នុងការរំឭកដល់អ្នកដែលលែងនៅទីនេះទៀតហើយ ។ កម្ពុជាចាំបាច់ត្រូវមានស្តូបបូជនីយដ្ឋានទីធ្លា និងឱកាសបន្ថែមទៀត សម្រាប់ជួយឲ្យអ្នកជំនាន់ចាស់បានសះស្បើយរបួសផ្លូវចិត្ត និងក្មេងជំនាន់ក្រោយ ចងចាំដើម្បីឲ្យប្រវត្តិសាស្ត្រមួយនេះ កើតមានម្តងទៀត ។

ជាថ្មីម្តងទៀតហើយដែលស្នាដៃរូបចម្លាក់របស់ សេរ៉ា ផ្តល់ឱកាសក្នុងការលួងលោមអ្នកដែលស្លាប់ទៅក្នុងសម័យខ្មែរក្រហម ក៏ដូចជាអ្នកដែលនៅរស់រានមានជីវិត តាមរយៈមនោសញ្ចេតនាការយល់ចិត្ត និងមនុស្សជាតិរួមរបស់យើង ។ ដូចគ្នាទៅនឹងស្នាដៃសិល្បៈដទៃទៀតដែរ រូបចម្លាក់អ្នកអង្វរកររបស់ សេរ៉ា មួយនេះ ជំរុញឲ្យមានការវិភាគ បកស្រាយទៅតាមទស្សនៈនៃការយល់ឃើញរបស់បុគ្គលម្នាក់ៗ រៀងៗខ្លួន ។

**អោក ឆាត:** ជាប្រជាពលរដ្ឋរស់នៅក្នុងទីក្រុងភ្នំពេញ យល់ឃើញថា ការដាក់តាំងរូបសំណាកនេះ ពិតជាល្អខ្លាំងណាស់ ។ គាត់បានរម្លឹកពីជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហមថា គាត់ និងគ្រួសាររស់នៅស្រុកព្រះស្តេច ខេត្តព្រៃវែង ។ កាលណោះ គាត់ត្រូវបានអង្គការបានបំបែកចេញពីគ្រួសារឲ្យទៅរស់នៅកងកុមារ ។ គាត់ត្រូវរែកដី ដើររើសអាចម៍គោ និងកាប់ទន្រ្ទានខែត្ររៀងរាល់ថ្ងៃ ។ ការរស់នៅឆ្ងាយពីគ្រួសារពិតជាលំបាកខ្លាំងណាស់ សម្រាប់ ឆាត ជាកុមារ ជាពិសេសគាត់មិនដែលបានហូបគ្រប់គ្រាន់នោះទេ ។ ហេតុនេះ ការដាក់តាំងរូបសំណាកនេះ ឆាត ជឿជាក់ថា នឹងក្រើនរម្លឹកក្មេងៗជំនាន់ក្រោយអំពីរបបខ្មែរក្រហម និងដាស់តឿនដល់អ្នកជំនាន់ក្រោយ ធ្វើយ៉ាងណាការពារ និងចៀសវាងកុំឲ្យរបបនេះកើតមានឡើងម្តងទៀត ។

**សូ វិទូ និស្សិតផ្នែកស្ថាបត្យកម្ម នៃសកលវិទ្យាល័យភូមិន្ទនិងវិចិត្រសិល្បៈ:** វិទូ ធ្លាប់បានឃើញស្នាដៃរបស់ សេរ៉ា ម្តង ក្នុងអំឡុងពេលតាំងពិព័រណ៍ ។ ដ្បិតគំនូរ និងចម្លាក់របស់គាត់ពិតជាស្នាដៃវិចិត្រកម្មមួយដែលបង្កប់ន័យទាក់ទងនឹងការចងចាំអំពីរបប



រូបសំណាក់ "អ្នកអង្វរលន់តួ" បូជាបូជនីយដ្ឋាន "សម្រាប់អ្នកដែលលែងនៅទីនេះទៀតហើយ" ត្រូវបានដាក់សម្ពោធ និងដាក់តាំងជាផ្លូវការនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧ នៅសួនច្បារទល់មុខស្ថានទូតបារាំង ក្នុងរាជធានីភ្នំពេញ ។

ខ្មែរក្រហម ។ សម្រាប់ វិទូ ស្នាដៃចម្លាក់របស់ សេរ៉ា មានរចនាបថថ្មីប្លែកពីគេ និងជាមធ្យោបាយថ្មី មួយក្នុងការតំណាងឲ្យគំនិតនៃសិល្បៈ ។ ចម្លាក់នេះមានលក្ខណៈសហសម័យ និងទំនើប ហើយមានភាពល្បីរន្ទឺនៅក្នុងពិភពលោកដោយសារតែចម្លាក់នេះជំរុញឲ្យការស្រមើស្រមៃរបស់មនុស្សឈានទៅរកភាពអរូបីយ និងគំនិតគ្មានដែនកំណត់ ។

ចម្លាក់នេះធ្វើអំពីស្ពាន់ ជារូបចម្លាក់នៃមនុស្សម្នាក់ដែលទម្រេតខ្លួនលើជើងទម្រស្ពាន់ ដោយរក្សានូវលំនឹងបានយ៉ាងល្អ ។ ចលនានៃចម្លាក់នេះហាក់ដូចជាបង្ហាញអំពីការឈឺចាប់ និងកំពុងស្នើនូវក្តីមេត្តាពីនរណាម្នាក់ ។ តាមរយៈការគ្របដណ្តប់ទៅដោយស្រទាប់រឹង និងពណ៌ស្រអាប់នៃសមាសធាតុផ្សំរបស់ចម្លាក់ វិទូ គិតថា ចម្លាក់នេះតម្រូវឲ្យ មានការចំណាយពេល និងបទពិសោធន៍អមជាមួយនឹងភាពអត់ធ្មត់ដើម្បីសម្រេចបាន ។

ចម្លាក់របស់ សេរ៉ា បាននាំអ្នកទស្សនាទៅក្នុងស្ថានភាពនៃការឈឺចាប់ និងការចងចាំមួយរបស់ជាតិអំឡុងរបបខ្មែរក្រហម ជាពិសេសការក្តោបក្តាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ នៅពេលនោះ ខ្មែរក្រហមដែលទទួលបានជ័យជម្នះបានគ្រប់គ្រងលើទីក្រុងភ្នំពេញ ព្រមទាំងធ្វើការរៀបចំសង្គមកម្ពុជាសាជាថ្មី ។ ខ្មែរក្រហមបានបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុងដោយហិង្សា ។ រូបចម្លាក់នេះធ្វើការបកស្រាយយ៉ាងច្បាស់អំពីផ្នត់គំនិត អំពើហិង្សា និងទុក្ខសោក នាខណៈពេលនោះ ។

ចំណុចដំបូងបង្អស់ដែលទាក់ទាញការចាប់អារម្មណ៍របស់ វិទូ គឺ ចលនា និងលំនឹងនៃរូបចម្លាក់នេះ ។ វិទូ យល់ថា សិល្បៈករប៉ុនប៉ងបង្ហាញអំពីរូបភាពជាក់ស្តែងនៃចលនាដងខ្លួន ដែលបង្ហាញដល់អ្នកទស្សនាអំពីអារម្មណ៍ឈឺចាប់ និងការសំពះអង្វរសុំក្តីមេត្តា ។ វិទូ ចាប់អារម្មណ៍ចំពោះភាពលម្អិតនៃស្រទាប់ស្ពាន់ តាមការយល់ឃើញផ្ទាល់ខ្លួន ស្រទាប់នេះត្រូវបានគួបផ្សំទៅដោយខ្សែបន្ទាត់ចំណុចតូចៗ និងខ្សែពត់ពេន ធាតុទាំងនេះបានបង្កើតជាស្រទាប់បង្កប់និងយ៉ាងល្អិតៗ ដែលហាក់ដូចជាក្តោបនូវការចងចាំនៃរូបចម្លាក់ផ្ទាល់ ។

វិទូ យល់ថា សេរ៉ា បាននាំយកនូវអ្វីដែលតំណាងឲ្យការចងចាំរបស់ទីក្រុងភ្នំពេញ ខណៈដែលបុគ្គលនីមួយៗស្ទើរតែភ្លេចអស់បាត់ទៅហើយ ។ វិទូ មានការជឿជាក់ប្រកប ដោយសុទិដ្ឋិនិយមថា ខណៈដែលរូបចម្លាក់នេះត្រូវបានដំឡើងនៅទីតាំងរបស់ខ្លួនមនុស្សជាច្រើនប្រាកដជាមានការចាប់អាម្មណ៍ ហើយរូបចម្លាក់នេះនឹងក្លាយជាស្នាដៃនៃការចងចាំមួយ ដែលរំឭកយើងទាំងអស់គ្នាអំពីសម័យកាលដ៏ខ្មៅងងឹតរបស់ប្រទេសកម្ពុជា ។ វិទូ ក៏សង្ឃឹមថានឹងមានស្នាដៃ ឬរូបចម្លាក់ប្រភេទនេះជាច្រើនទៀត លេចរូបរាងនៅក្នុងទីក្រុងរបស់ខ្ញុំ គឺទីក្រុងភ្នំពេញ ។

***សៀង សត្យា និស្សិតផ្នែកស្ថាបត្យកម្ម នៃសកលវិទ្យាល័យភូមិន្ទ និងវិចិត្រសិល្បៈ៖*** សត្យា មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយសារតែលំនឹងនៃទ្រង់ទ្រាយរបស់រូបចម្លាក់ ក៏ដូចជាស្រទាប់ស្ពាន់គ្រើមនៃរូបចម្លាក់ ។ ដូចទៅនឹងស្ថាបត្យកម្មដែរ តុល្យភាព មានតួនាទីសំខាន់ណាស់ក្នុងការបង្ហាញនូវគោលបំណងនៃវត្ថុក្នុងលំហមួយ ។ សត្យា យល់ថា រូបចម្លាក់របស់ សេរ៉ា ពិតជាស្ថិតនៅត្រង់ចំណុចដ៏សមស្របមួយ ។ ផ្នែកទម្រេតចុះនៃចលនារបស់រូបចម្លាក់នេះ បង្ហាញអំពីភាពចលាចល និងច្របូលច្របល់ ចម្លាក់នេះបង្កើតឲ្យមានអារម្មណ៍ឈឺចាប់ ការព្រួយបារម្ភ ភាពភ័យខ្លាច ដែលធ្វើឲ្យ សត្យា យល់ថា ស្មុគស្មាញ ។ អារម្មណ៍ច្របូកច្របល់ជាច្រើនស្ថិតនៅក្នុងការគិតរបស់ សត្យា ហើយពុំអាច ផ្តង់ស្មារតីបាន ។ សត្យា ព្យាយាមតាំងខ្លួនខ្ញុំនៅក្នុងស្ថានភាពនៃរូបចម្លាក់នេះ នៅក្នុងស្ថានភាពដែលតម្រូវឲ្យ សត្យា បណ្តែតខ្លួនក្នុងលំហ តាមរយៈកាយវិការនៃរូបចម្លាក់ សត្យា ស្រមៃដល់ខណៈពេលមួយដែល សត្យា ពុំមានកម្លាំង ពុំមានអាវុធដើម្បីប្រយុទ្ធតបត ពុំមានសមត្ថភាពដើម្បីរត់គេចពីការបំពានលើសិទ្ធរស់រានរបស់ សត្យា អ្វីដែល សត្យា មានគឺត្រឹមតែដៃទទេមួយគូ ដែលប្រណមឡើងអង្វរសុំក្តីមេត្តា ។

រូបចម្លាក់នេះពិតជាបានរំលេចឲ្យមនុស្សឃើញអំពីរូបភាពនៃព្រឹត្តិការណ៍សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា ដែលបង្កឲ្យជនរងគ្រោះប្រមាណ២លាននាក់បាត់បង់ជីវិតនោះ គឺរបប ប៉ុល ពត ។ រូបចម្លាក់នេះបង្ហាញអំពីភាពអាណិតអាសូរ និងការផ្សះផ្សាអំពីប្រវត្តិសាស្ត្រនៃសោកនាដកម្មរបស់ប្រទេសកម្ពុជា ។ សត្យា ជឿជាក់ថា ការស្រមើស្រមៃ គឺជាអាហារនៃគំនិត យើងតែងមានការស្រេកឃ្លាន ដូច្នេះ ខ្ញុំរំពឹងថា រូបចម្លាក់នេះនឹងនាំ មកនូវអ្វីដែលសង្គមនេះខ្វះខាតដោយពុំដឹងខ្លួន ក៏ដូចជាសម្រាប់មនុស្សជំនាន់

ក្រោយដែលមានចំណាប់អារម្មណ៍ផ្នែកគំនិតច្នៃប្រឌិត ការស្រមើស្រមៃ និងសិល្បៈ ។

សត្យា មានការជឿជាក់យ៉ាងមុតមាំថា រូបចម្លាក់នៃការចងចាំនេះ នឹងរំឭកអំពីការចងចាំនៃអ្នកទាំងឡាយដែលបានបាត់បង់មនុស្សជាទីស្រឡាញ់របស់ខ្លួននៅក្នុងរបបខ្មែរក្រហម ក៏ដូចជាឧទ្ទិសដល់"អ្នកទាំងឡាយដែលលែងមានវត្តមាននៅទីនេះទៀតហើយ" ។ ជាជាងការរំឭកអំពីភាពព្រឺព្រួចនៃពេលវេលាដ៏ខ្មៅងងឹតទាំងនោះ រូបចម្លាក់នៃការចងចាំនេះ ធ្វើឲ្យអ្នកដើរឆ្លងកាត់មានអារម្មណ៍អាណិតអាសូរ និងក្ដីសង្ឃឹមសម្រាប់អនាគតដ៏សុខដុមមួយ ដោយមិនបំភ្លេចអំពីអតីតកាល ។

## អំពីសិល្បករ អ៊ីង ភូសេរ៉ា

សេរ៉ា កើតនៅក្នុងទីក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៦១ ។ បន្ទាប់ពីបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកវិចិត្រសិល្បៈ និងថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រសិល្បៈនៅសាកលវិទ្យាល័យសូបិនក្នុងទីក្រុងប៉ារីស សេរ៉ា បានបំពេញការងារក្នុងវិស័យនេះ ក្នុងនាមជាសាស្ត្រាចារ្យ និងជាសិល្បករ ។ ស្នាដៃរបស់ សេរ៉ា រួមមានគំនូរ ចម្លាក់ ការគូររូបការដាប់ និងសៀវភៅគំនូរបែបក្រាហ្វិក ។ អ្វីដែលគួរជាទីកត់សម្គាល់នោះ គឺ សេរ៉ា ជាអ្នកនិពន្ធសៀវភៅគំនូរ បែបក្រាហ្វិកនានាដែលបង្ហាញអំពីសោកនាដកម្មរបស់កម្ពុជារួមមាន៖ *Impasse et rouge* (ឆ្នាំ១៩៩៥ បោះពុម្ពជាថ្មីនៅឆ្នាំ២០០៣) , *L'eau et la terre* (ឆ្នាំ២០០៥) , *Lendemains de cendres* (ឆ្នាំ២០០៧) ។ ចាប់តាំងពីឆ្នាំ១៩៩៩មក គាត់តែងតែរៀបចំសិក្ខាសាលាស្ដីពីការនិពន្ធសៀវភៅគំនូរបែបក្រាហ្វិកនៅវិទ្យាស្ថានភាសាបារាំងក្នុងទីក្រុងភ្នំពេញ ក៏ដូចជាសិក្ខាសាលាដែលជំរុញឲ្យមានការចូលរួមផ្ដោតលើគោលគំនិតនៃសិល្បៈមានរូបរាងនោះគឺ *Les Ateliers de la Mémoire* (សិក្ខាសាលានៃការចងចាំ) ។ សិក្ខាសាលាជំរុញឲ្យមានការចូលរួមក្នុងផ្នែកសិល្បៈមានរូបរាង ត្រូវបានប្រារព្ធឡើងនៅមជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា បានដើរតួនាទីជាការដាស់តឿនរំឭកដល់សកម្មនិងមានអានុភាពអំពីប្រវត្តិសាស្ត្រខ្លោចផ្សាររបស់កម្ពុជាតាមរយៈការបង្កើតឲ្យមានការចូលរួមពីសំណាក់ប្រជាជនជំនាន់ក្រោយ នៅក្នុងស្នាដៃនៃការចងចាំ អំពីអតីតកាលដែលហាក់ដូចជាត្រូវបានស្គាល់ច្បាស់ តែមិនធ្លាប់បានដឹងសោះ ។ តាមរយៈភាសាសម្ដែងចេញ របស់សៀវភៅគំនូរបែបក្រាហ្វិក សេរ៉ា ព្យាយាមពង្រីកឲ្យលើសពីការចែករំលែកកំណត់ត្រាប្រវត្តិសាស្ត្រពីជំនាន់មួយទៅជំនាន់មួយទៀត ដោយផ្ដល់ដល់យុវជនកម្ពុជានូវឱកាសមួយ ដើម្បីយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់ខ្លួនតាមរយៈការបង្កើតស្នាដៃសិល្បៈ ។

នៅក្នុងឆ្នាំ២០០៧ សេរ៉ា បានបង្កើតស្នាដៃចម្លាក់នៃការចងចាំសម្រាប់ដាក់តាំងនៅទីវាលមួយ សម្រាប់សហគមន៍កម្ពុជានៅក្នុងទីក្រុងប៉ូស៊ីសានចេច ។ បូជនីយដ្ឋានតំណាងនេះ ឧទ្ទិសដល់អ្នកដែលគ្មានឈ្មោះត្រូវបានតម្កល់នៅវត្តធំមួលមួយដែលក្រោយមក ទីតាំងនេះ ត្រូវបានកែឈ្មោះទៅជាទីតាំងក្រុងភ្នំពេញ ។

ក្នុងរយៈពេលជាង២៥ឆ្នាំ កន្លងមក ការងាររបស់ សេរ៉ា ត្រូវបានដាក់តាំងបង្ហាញជាច់ដោយឡែក និងរួមជាមួយស្នាដៃរបស់អ្នកដទៃទៀត នៅក្នុងប្រទេសបារាំង និងប្រទេសកម្ពុជា ។ នៅក្នុងខែមេសា ឆ្នាំ២០១២ វិទ្យាស្ថានភាសាបារាំង ក្នុងទីក្រុងភ្នំពេញ បានប្រារព្ធគម្រប់ខួប២០ឆ្នាំ របស់ខ្លួនដោយរៀបចំការតាំងពិព័រណ៍ស្នាដៃដ៏ច្រើនសន្ធឹកសន្ធាប់របស់ សេរ៉ា ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ក្រុមសិល្បៈ *Art Absolument* បានសម្រេចជ្រើសរើស សេរ៉ា ជាសិល្បករបែបសហសម័យដ៏ល្អប្រសើរមួយរូប ក្នុងប្រទេសបារាំង នាអំឡុងពេលដប់ឆ្នាំកន្លងមក ។ នេះគឺជាការទទួលស្គាល់ដ៏វិសេសវិសាលមួយដែលផ្ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះដល់ទេពកោសល្យឆ្នើមរបស់សិល្បកររូបនេះ ។

បន្ថែមពីនេះទៅទៀត សេរ៉ា ក៏មានកិត្តិស័ព្ទល្បីរន្ទឺចំពោះស្នាដៃគំនូររស់រវើក តាមរយៈការសម្ដែងយ៉ាងពិសេសជាសាធារណៈ ។ សេរ៉ា បានទទួលរង្វាន់ និងអាហារូបករណ៍ ជាច្រើនអនេក អ្វីដែលគួរជាទីកត់សម្គាល់ជាងគេបំផុតនោះគឺ រង្វាន់ពីវិទ្យាស្ថានសិល្បៈជាតិនៃប្រទេសបារាំង ។ សេរ៉ា បានរក្សាតំណែងបង្រៀនដ៏ថ្លៃថ្នូររបស់ខ្លួននៅសូបិនចាប់តាំងពីឆ្នាំ១៩៨៩ ។ នៅក្នុងឆ្នាំ២០១២ សេរ៉ា ត្រូវបានតែងតាំងជាប្រធានកម្មវិធីសិក្សានៅសាលាហ្វារពន្ធឺសិល្បៈក្នុងខេត្តបាត់ដំបង ប្រទេសកម្ពុជា ។ បច្ចុប្បន្ន សេរ៉ា កំពុងធ្វើការសិក្សាស្រាវជ្រាវនិក្ខេបបទថ្នាក់បណ្ឌិតរបស់ខ្លួននៅឯ *Paris I Panthéon-Sorbonne* ក្រោមការដឹកនាំរបស់ យ៉ាន់ ថូម៉ា ។ **ឡាច សារៈមុនិន្ទ**

# ផ្ទាំង និងអត្ថន័យរបស់ពាក្យស្លោកនៃការចងចាំពីអំពើប្រល័យពូជសាសន៍

អស់រយៈពេលជាង៧ឆ្នាំកន្លងមកហើយ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាតម្លើងផ្ទាំងពាក្យស្លោកស្តីពីការចងចាំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅតាមវិទ្យាល័យមួយចំនួនក្នុងទូទាំងប្រទេសកម្ពុជា ។ រហូតមកដល់ពេលបច្ចុប្បន្ន មានវិទ្យាល័យចំនួន២៥ហើយ ដែលទទួលបានការដំឡើងផ្ទាំងពាក្យស្លោកស្តីពីការចងចាំ នៅក្នុងបរិវេណនៃវិទ្យាល័យរបស់នីមួយៗ ។ កិច្ចការនេះ ប្រព្រឹត្តទៅក្រោមការសហការពីក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសក្រោមការខ្នះខ្នែង និងជ្រោមជ្រែងពីលោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាអតីតជនរងគ្រោះនៃរបបខ្មែរក្រហមម្នាក់ដែលបានបាត់បង់សាច់ញាតិជាច្រើននាក់ក្នុងរបបឃោរឃៅនេះ ។ លោកជំទាវតែងរំឭកពីការបាត់បង់សមាជិកគ្រួសារយ៉ាងច្រើនប្រាប់ទៅកាន់ប្រជាជន គ្រូបង្រៀន មន្ត្រីរាជការ និងសិស្សានុសិស្ស នៅរៀងរាល់ពេលលោកជំទាវត្រូវបានអញ្ជើញធ្វើជាគណអធិបតី នៅក្នុងកម្មវិធីផ្សេងៗដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មិនតែប៉ុណ្ណោះ លោកជំទាវតែងតែចង់ឲ្យកូនខ្មែរជំនាន់ក្រោយទាំងអស់ចងចាំពីរបបខ្មែរក្រហម ចេះយោគយល់ អធ្យាស្រ័យ និងផ្សះផ្សាគ្នា ព្រោះលោកជំទាវយល់ឃើញថា ការកកើតរបបខ្មែរក្រហមឡើងក្នុងពេលអតីតកាល ដោយសារតែការមិនចេះយល់យោគ និងអធ្យាស្រ័យគ្នា ។ ផ្តើមចេញពីមូលហេតុនេះ លោកជំទាវបានសរសេរពាក្យស្លោកប្រឆាំងនឹងរបបខ្មែរក្រហមចំនួនពីរឃ្លា គឺៈ

១) និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ឱន អធ្យាស្រ័យគ្នា

និង២) រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។

ពាក្យស្លោកទាំងពីរឃ្លានេះ ត្រូវបានផ្សព្វផ្សាយនៅតាមសាលារៀនទូទាំងប្រទេស ដើម្បីជាសារដ៏មានសារសំខាន់មួយផ្ញើទៅកាន់ប្រជាជនកម្ពុជាគ្រប់ជំនាន់ ឲ្យស្វែងយល់ពីខ្លឹមសារ និងអត្ថន័យរបស់ពាក្យស្លោកនេះ និងដើម្បីលើកកម្ពស់ការយល់ដឹងរបស់សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ ពីអំពើប្រល័យពូជសាសន៍ និងការទប់ស្កាត់អំពើនេះ ។ តាមរយៈពាក្យស្លោកចំនួនពីរឃ្លាដែលចារឹកនៅលើផ្ទាំងពាក្យស្លោកនីមួយៗ គឺបង្ហាញពីអត្ថន័យលើកកម្ពស់ឲ្យមានការអត់ឱន អធ្យាស្រ័យ អប់រំ និងផ្សះផ្សាគ្នា ។ គម្រោងដែលមានលក្ខណៈសាមញ្ញ និងមានអត្ថន័យធំធេងនេះ បានផ្តល់សារសំខាន់មួយចំនួនដូចជាៈ

១) រំឭកយើងពីទំនាក់ទំនងដែលមិនអាចកាត់ផ្តាច់បានរវាងការអប់រំ ការចងចាំ និងប្រវត្តិសាស្ត្រនៃការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។ ទំនាក់ទំនងនេះ មានសារសំខាន់បំផុតសម្រាប់ការអនុវត្តប្រកបដោយជោគជ័យនៃកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍តាមរយៈការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមវិទ្យាល័យ ដែលសិស្សានុសិស្សច្រើនជាង១លាននាក់កំពុងសិក្សាមុខវិជ្ជាប្រវត្តិវិទ្យានេះជារៀងរាល់សប្តាហ៍ អាចស្វែងយល់ពីអំពើឃោរឃៅដែលបានសម្លាប់មនុស្សអស់ប្រមាណ២លាននាក់ ។

២) ពាក្យស្លោកទាំងពីរឃ្លានេះ ផ្តល់ការរំឭកយ៉ាងពិតប្រាកដថា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ត្រូវតែបង្រៀនដើម្បីជាប្រយោជន៍ដល់ការចងចាំ ការផ្សះផ្សា និងការអធ្យាស្រ័យគ្នា ។ បើមិនដូច្នេះទេ ភាពមិនអើពើនាពេលបច្ចុប្បន្នពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នឹងក្លាយទៅជាចំណេះដឹងពីប្រវត្តិសាស្ត្រនេះ ។ ចុងបញ្ចប់ គម្រោងនេះជួយធ្វើឲ្យមានការបង្រួបបង្រួមគ្នារវាងគ្រូបង្រៀន និងសិស្សានុសិស្សដែលកំពុងសិក្សានៅក្នុងវិទ្យាល័យនាពេលបច្ចុប្បន្ន ជាមួយនឹងអតីតសិស្សដែលធ្លាប់សិក្សានៅក្នុងវិទ្យាល័យ កាលពីពេលកន្លងទៅ ។ **រដេង ពង្សរ៉ាស៊ី**

# កម្ពុជា ដំណើរដ៏វែងឆ្ងាយឆ្ពោះទៅរកភាពសះស្បើយ

នៅខែកក្កដា ឆ្នាំ២០១៧នេះ មានប្រជាពលរដ្ឋខ្មែរប្រហែលជាងកន្លះលាននាក់ បានចូលរួមស្តាប់ការកាត់ក្តី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា ដែលត្រូវបានស្គាល់ជាទូទៅថា តុលាការខ្មែរក្រហម ។ តុលាការនេះបានជំនុំជម្រះ នួន ជា, ខៀវ សំផន និង កាំង ហ្គេកអ៊ាវ ជាមួយនឹងការចំណាយទឹកប្រាក់សរុបប្រហែល



កាំង ហ្គេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ នៅបន្ទប់សវនាការសំណុំរឿង០០១ (រូបថត៖ អ.វ.ត.ក)

៣០០លានដុល្លារ ក្នុងរយៈពេល ១១ឆ្នាំ នៃការជំនុំជម្រះក្តីនេះ ។ ខណៈពេលដែលតុលាការខ្មែរក្រហមជិតនឹងបញ្ចប់ អ្នកសង្កេតការណ៍លោកខាងលិច ដែលធ្វើការទាក់ទងនឹងសមាគមសិទ្ធិមនុស្សអន្តរជាតិ បានធ្វើការវិនិច្ឆ័យថា រាល់ការជំនុំជម្រះក្តីនេះពិតជាទទួលបាននូវភាពជោគជ័យ លើយន្តការនៃយុត្តិធម៌អន្តរកាល ។ ប៉ុន្តែសម្រាប់ប្រជាជនកម្ពុជាវិញបានគិតថា លទ្ធផលនៃការប៉ះពាល់អំពីរបបខ្មែរក្រហម បានស្ថិតនៅរហូតមកដល់សព្វថ្ងៃនេះ ។ ជនរងគ្រោះម្នាក់ឈ្មោះ យ៉ាន់ណា រស់នៅភូមិកោះខ្យង ដែលស្ថិតនៅក្បែរក្រុងព្រះសីហនុបានរៀបរាប់ថា គាត់ត្រូវបានខ្មែរក្រហមបំបែកចេញពីកូនៗ ឲ្យទៅរស់នៅតាមជំរំផ្សេងៗ តាមការចាត់តាំងរបស់ខ្មែរក្រហម ដូចជា ផែនការបញ្ជូនទៅរៀនសូត្រ ។ ការងារប្រចាំថ្ងៃរបស់ យ៉ាន់ណា គឺធ្វើស្រែ លើកទំនប់ ជីកប្រឡាយ តាំងពីថ្ងៃរះរហូតដល់ថ្ងៃលិច ។ បន្ទាប់ពីថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ នាងបានវិលត្រឡប់មកស្រុកកំណើតវិញ និងបានរស់នៅប្រឈមមុខជាមួយនារីចំណាស់ម្នាក់ ដែល យ៉ាន់ណា ជឿជាក់ថាបានបង្អត់អាហារកូនរបស់ខ្លួនរហូតដល់ស្លាប់ក្នុងរបបខ្មែរក្រហម ។ យ៉ាន់ណា បានជឿជាក់យ៉ាងមុតមាំទៅលើទស្សនកម្មផលរបស់ព្រះពុទ្ធសាសនា ដែលថាបុគ្គលណាធ្វើអំពើអ្វី បុគ្គលនោះនឹងទទួលបានផលនោះ ហើយបានអនុញ្ញាតឲ្យស្ត្រីវ័យចំណាស់នោះ រស់នៅដោយស្ងប់ស្ងៀម ។

សព្វថ្ងៃនេះ ទាំងជនរងគ្រោះ និងអតីតខ្មែរក្រហមបានសង្កត់ធ្ងន់អំពីសារសំខាន់នៃការអប់រំអំពើប្រល័យពូជសាសន៍ដល់ក្មេងជំនាន់ក្រោយ ប៉ុន្តែ ដោយសារប្រភពធនធានមានកម្រិតជាឧបសគ្គរាំងស្ទះដល់ការខិតខំប្រឹងប្រែងរបស់ពួកគេ បណ្តាលឲ្យគ្រូបង្រៀនផ្នែកប្រវត្តិសាស្ត្របានសង្កត់ធ្ងន់ថា ភាពចាំបាច់ដើម្បីអប់រំក្មេងៗ អំពីព្រឹត្តិការណ៍ដែលបានកើតឡើងពីអតីតកាល គឺដើម្បីទប់ស្កាត់កុំឲ្យអំពើប្រល័យពូជសាសន៍បែបនេះ កើតឡើងជាថ្មីម្តងទៀត ។

ជនរងគ្រោះតែងតែសញ្ជឹងគិតអំពីរឿងរ៉ាវដែលបានកើតពីអតីតកាល ហើយតែងតែស្រមៃគិតថា តើជីវិតរបស់ពួកគេទៅជាយ៉ាងណា ប្រសិនបើពុំមានរបបខ្មែរក្រហម ។ យ៉ាន់ណា ជាអ្នកជំនួញស្រីដ៏ជោគជ័យម្នាក់នៅសម័យមុន ហើយត្រូវបានខ្មែរក្រហមបង្ខំឲ្យដុតលុយចោលទាំងអស់ ហើយនាងតែងតែស្រមៃថា ប្រសិនបើនាងមានគ្រួសារដ៏ធំ និងកក់ក្តៅមួយ នាងមិនដឹងជាសប្បាយចិត្តយ៉ាងណាទេ!

អ្នកយាមគុកស-២១ ឈ្មោះ ខៀវ ជេស ហៅ ពៅ បានទទួចថា ដៃរបស់គាត់ពុំបានប្រឡាក់ឈាមដោយសារសម្លាប់នរណាម្នាក់នោះទេ ហើយគាត់បានបន្តថា គាត់សោកស្តាយនូវភាពយុវវ័យរបស់គាត់ណាស់ ពីព្រោះគាត់បានចំណាយពេលជាច្រើនក្នុងការធ្វើសង្គ្រាម ហើយគាត់តែងតែនឹករលឹកដល់ផ្ទះរបស់គាត់យ៉ាង

ខ្លាំង ។ ដេស តែងតែគិតថា រឿងរ៉ាវជីវិតរបស់គាត់នឹងអាចខុសពីនេះ ។ រីឯអតីតអ្នកយាមគុកស-២១ ម្នាក់ទៀត ឈ្មោះ ជាម សឿ បានបន្ថែមថា គាត់ធ្លាប់ស្រមៃចង់ធ្វើជាគ្រូបង្រៀនកាលពីស្រុកមិនទាន់មានសង្គ្រាម ។ ស្របពេលដែលពួកគាត់បានសញ្ជឹងគិតពីជីវិតរបស់គាត់ បើមិនមានរបបខ្មែរក្រហម ជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហមមិនបានយល់នូវសារសំខាន់នៃការសិក្សា និងអំពីការអប់រំដល់ក្មេងៗជំនាន់ក្រោយ ស្តីអ៊ីដែលបានកើតឡើងពីអតីតកាលទេ ។ យ៉ាន់ណា មានជំនឿយ៉ាងមុតមាំថា នេះជាតួនាទីរបស់គាត់ក្នុងការបង្ហាត់បង្ហាញក្មេងជំនាន់ក្រោយឲ្យបានយល់ដឹងអំពីរឿងរ៉ាវដែលបានកើតឡើងពីអតីតកាល គាត់បានបន្ថែមទៀតថា វាជាគន្លឹះមួយដើម្បីឲ្យក្មេងជំនាន់ក្រោយផ្សារជាប់គ្នាកាន់តែខ្លាំងឡើង ។ ជានិច្ចកាលគាត់ធ្លាប់ជួបប្រទះ ជាមួយនឹងក្មេងៗខ្លះដែលតែងតែសើចលេងពេលគាត់និទានរឿងរ៉ាវពីជីវិតរបស់គាត់ នៅពេលដែលខ្មែរក្រហមបង្ខំគាត់ឲ្យទៅជំរំប្រមូលផ្តុំ ចំណែកឯក្មេងខ្លះទៀត ហាក់ដូចជាមិនសូវជឿជាក់រឿងរ៉ាវដែលបានកើតឡើង ។ លោក ឃុន វុន គឺជាជនរងគ្រោះម្នាក់ទៀតដែលសព្វថ្ងៃរស់នៅភូមិបន្ទាយឈើ ដែលស្ថិតនៅជាយក្រុងសៀមរាប បានប្រាប់ថា លោកបានជួបប្រទះនូវបញ្ហាពេលដែលអប់រំដល់យុវវ័យជំនាន់ក្រោយ អំពីរឿងរ៉ាវកាលពីអតីតកាល ។ ក៏ដូចជនរងគ្រោះដទៃទៀតដែរ លោកពិតជាខ្លាចរឿងរ៉ាវនេះនឹងកើតឡើងសាជាថ្មីម្តងទៀត ដូចនេះទើបលោកយល់ថាមានតែការសិក្សាអប់រំតែប៉ុណ្ណោះ ដែលអាចបញ្ចៀសរឿងរ៉ាវនេះកើតឡើងជាថ្មីម្តងទៀត ។ ទោះបីជាកូនៗរបស់គាត់មិនអាចដឹងច្បាស់ អំពីការសម្លាប់រង្គាល ឬការបង្អត់អាហារជាទ្រង់ទ្រាយធំ ដែលបានកើតឡើង ទោះបីជាឪពុកម្តាយ និងបងៗបានដំណាលរឿងរ៉ាវដែលពួកគាត់បានជួបប្រទះនៅក្នុងរបបខ្មែរក្រហមក៏ដោយ ។

កូនចៅរបស់អតីតកម្មាភិបាលខ្មែរក្រហម សឹងតែមិនជឿថាមានការសម្លាប់រង្គាល និងការអត់អាហារដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមឡើយ ពីព្រោះពួកគេត្រូវបាននិយាយប្រាប់ខុសៗគ្នា នៅអំឡុងពេលដែលពួកគេបានធំធាត់ឡើង ។ ឧទាហរណ៍ ឈ្មោះ ងិន ស៊ីនួន រស់នៅអន្លង់វែង ។ ស៊ីនួន គឺជាក្មួយស្រីរបស់តាម៉ុក ដែលជាមេដឹកជាន់ខ្ពស់ខ្មែរក្រហមម្នាក់ដែលល្បីល្បាញខាងកាប់សម្លាប់ ។ ស៊ីនួន ពុំដែលត្រូវបានក្រុមគ្រួសារនិយាយរឿងរ៉ាវដ៏ឃោរឃៅ ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ១៩៧៥-១៩៧៩ បើទោះបីជាឪពុករបស់នាងជាអតីតកងទ័ពខ្មែរក្រហមក៏ដោយ ។ គ្រួសាររបស់នាងបាននិយាយប្រាប់នាងថា



រូបខាងស្តាំដៃបង្អស់ ៖ កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅមន្ទីរសន្តិសុខស-២១

បដិវត្តន៍ខ្មែរក្រហមបានកកើតឡើង គឺដើម្បីទប់ស្កាត់អំពើឈ្លានពានរបស់វៀតណាម ហើយបានបន្តថា ជនជាតិវៀតណាមជាអ្នកសម្លាប់ជនជាតិខ្មែរ ក៏ដូចជាបញ្ញវន្តរបស់ខ្មែរដែរ ។ ទស្សនៈយល់ច្រឡំមួយអំពីបដិវត្តន៍ខ្មែរក្រហមនេះបានបន្តរហូតមកដល់សព្វថ្ងៃ ។ បដិវត្តន៍របស់ខ្មែរក្រហម គឺមិនត្រឹមតែនូវអ្វីដែលនាងបានឮ ឬអានសៀវភៅសិក្សាប្រវត្តិសាស្ត្រនោះទេ តែវាជាអ្វីដែលជាបទពិសោធន៍របស់នាងបានឃើញ នៅក្នុងសហគមន៍ខ្មែរក្រហមសព្វថ្ងៃនេះ ។ នៅពេលដែលនាងធំដឹងក្តីឡើង តែងតែត្រូវរត់ភៀសខ្លួនទៅតំបន់ភ្នំ ដើម្បីគេចពីការវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម ។ តាម៉ុក ថែមទាំងបានប្រាប់នាងឲ្យខិតខំរៀនសូត្រការពារកុំឲ្យពួកវៀតណាមបញ្ចុះបញ្ចូល ឬផ្លាស់ប្តូរគំនិតនាងបាន ។

យ៉ាងណាក៏ដោយ យើងចាំបាច់ត្រូវតែចងចាំក្នុងចិត្តថា បទពិសោធន៍របស់នាងគឺមានលក្ខណៈខុសប្លែកពីកូនចៅរបស់ជនរងគ្រោះ ។ នាងបានធំធាត់នៅតំបន់អន្លង់វែង ដែលជាតំបន់មួយត្រូវបានខ្មែរក្រហមកាន់កាប់រហូតដល់១៩៩៧ ។ ជារបបខ្មែរក្រហមមួយ ដែលនាងបានរស់នៅ និងធំធាត់ឡើង ។ ខ្មែរក្រហមចន្លោះទសវត្សរ៍ ១៩៨០-១៩៩០ វាខុសគ្នាអំពីខ្មែរក្រហមដែលបានសម្លាប់រង្គាលនាឆ្នាំ១៩៧០ ប្លាយ ។ ចំណុចត្រង់នេះហើយដែលជាផ្នែកសំខាន់ ក្នុងការប្រមែប្រមូលសំណៅឯកសារប្រវត្តិសាស្ត្រ ដើម្បីឲ្យជនរួមជាតិទាំងមូល បានយល់ឲ្យបានស៊ីជម្រៅអំពីភាពស្មុគស្មាញនៃប្រវត្តិសាស្ត្រ ។

បច្ចុប្បន្ននេះ ទាំងជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហមបានផ្តោតលើសារសំខាន់លើការសិក្សាអប់រំអំពើប្រល័យពូជសាសន៍សម្រាប់ក្មេងៗជំនាន់ក្រោយ ប៉ុន្តែ វាមានបញ្ហាផ្នែកធនធានបានរាំងដល់ការខិតខំប្រឹងប្រែងរបស់ពួកគាត់ ។ លោកគ្រូអ្នកគ្រូ បានបង្ហាត់បង្រៀនផ្នែកប្រវត្តិសាស្ត្រ បានបញ្ជាក់ថា យើងចាំបាច់ត្រូវតែអប់រំកូនចៅជំនាន់ក្រោយ អំពីអ្វីដែលបានកើតឡើងកាលពីអតីតកាល ដើម្បីការពារកុំឲ្យអំពើប្រល័យពូជសាសន៍បែបនេះកើតឡើងជាថ្មីម្តងទៀត ។ ការអប់រំគឺជាការទប់ស្កាត់ ។ នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ជាកន្លែងមួយក្នុងចំណោមកន្លែងដែលខ្មែរក្រហមបានជ្រើសរើសមនុស្សឲ្យចូលបម្រើបដិវត្តន៍ លោកគ្រូ សុខ សារួន និងលោកគ្រូ គុម ចាន់ដារ៉ា គឺជាអ្នកដែលកើតក្រោយរបបខ្មែរក្រហមបានសោកស្តាយចំពោះកម្មវិធីសិក្សាបច្ចុប្បន្ននេះដែលបានបញ្ចូលរឿងរ៉ាវនេះតិចតួចបំផុតក្នុងកម្មវិធីសិក្សា ។ ពួកគាត់បានជឿជាក់ថា ទម្រង់នៃការអប់រំនឹងមានភាពប្រសើរជាងនេះប្រសិនបើយើងអញ្ជើញជនរងគ្រោះ ដែលនៅសេសសល់ពីរបបខ្មែរក្រហម មកចែករំលែកបទពិសោធន៍ដែលពួកគាត់បានជួបប្រទះ និងមានដំណើរទស្សនកិច្ចសិក្សាទៅកាន់សារមន្ទីរទួលស្លែង និងសារមន្ទីរប្រល័យពូជសាសន៍ជើងឯក ហើយប្រើរូបភាពផ្សេងៗ ដូចជា រូបថត ខ្សែភាពយន្តឯកសារជាដើម ។

សកម្មជនផ្នែកសន្តិភាព និងផ្សះផ្សា ឈ្មោះ ម៉ន សុខគៀន ដែលធ្វើការនៅអង្គការយុវជនដើម្បីសន្តិភាព បានជ្រើសរើសយកគំនិតមួយ ដោយលោកបានបង្ហាញនូវរូបភាព និងខ្សែភាពយន្តទៅកាន់យុវជនផ្សេងៗ ដើម្បីឲ្យពួកគេបានយល់ច្បាស់ អំពីរបបខ្មែរក្រហម និងទាញចំណាប់អារម្មណ៍ពួកគេឲ្យយកចិត្តទុកដាក់លើបញ្ហាប្រវត្តិសាស្ត្រជាតិ ។

ខណៈដែលអង្គការសហប្រជាជាតិ និងសមាគមសិទ្ធិមនុស្សជំរុញឲ្យបញ្ចប់នូវដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមអំពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មសង្គ្រាម បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឲ្យបានឆាប់ៗនេះ ។ ប្រជាជនកម្ពុជានាពេលបច្ចុប្បន្នមានតួនាទីចម្បងថែរក្សាអំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ និងការចងចាំរបស់ជនរងគ្រោះ ដើម្បីទុកឲ្យក្មេងៗជំនាន់ក្រោយ ។

រហូតមកដល់ឆ្នាំ២០០៩ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាអង្គការក្រៅរដ្ឋាភិបាលបានប្រមែប្រមូលចងក្រងឯកសារដែលទាក់ទងនឹងអំពើឃោរឃៅរបស់ខ្មែរក្រហម តាំងពីឆ្នាំ១៩៩៥ ហើយបានធ្វើការសហការជាមួយក្រសួងអប់រំយុវជន និងកីឡា ដើម្បីធ្វើការជាមួយសាលាក្នុងការផ្តល់ព័ត៌មាន និងឯកសារចំពោះការអប់រំសិស្សានុសិស្សអំពីរបបខ្មែរក្រហម ។ នេះជាលើកទី១ ហើយនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប ដែលកម្ពុជាបានចាប់ផ្តើមចងក្រងឯកសារ និងសរសេរប្រវត្តិសាស្ត្រដោយខ្លួនឯង ។

**លី លីលី, ណាតាលី ប៉ាដូ និង ក្សី តាំ**

# ព្រលឹងមាសម្ដាយ

**(តពីលេខមុន)**

យើងមកដល់ព្រៃដំបូកប្រយ៉ាបនេះ ទុកថាបានរស់ហើយ អ្នកភូមិស្ដៅ និងភូមិពន្លៃ ចាត់ទុកថា មិនធ្ងន់ធ្ងរទេ ប៉ុន្តែអ្នកភូមិព្រៃកណ្ដៀងវិញ ប្រសិនបើមានអ្នកណាមិនបានចាកចេញពីភូមិទេនោះ ច្បាស់ជាត្រូវទទួលរងនូវគ្រោះអាសន្នធ្ងន់យ៉ាងណាទៅ ។ "ការវិភាគ របស់ឪពុកខ្ញុំ" ។

ជាការពិតមែន មួយសន្ទុះមក ក្រុមគ្រួសារយើងដែលនៅដើមព្រៃដំបូកប្រយ៉ាបជាងគេ ព្រោះយើងរត់មកក្រោយគេ បានជួបនឹងពូ ឡោ ពូ ឡុន ព្រៃកណ្ដៀង ដែលកំពុងរត់មុជ ងើបៗ យ៉ាងដង្ហក់សៀរជើងព្រៃនាមដំបូកប្រយ៉ាប ស្រែកសួររកក្រុមគ្រួសារគាត់ គឺទើបនឹងចាកចេញពីភូមិព្រៃកណ្ដៀងក្រោយការទម្លាក់គ្រាប់បែក នៅព្រៃកណ្ដៀងដែលទើបនឹងស្ងាត់ទៅមួយម៉ោងមុននេះ ។ ពួកគាត់បានឲ្យដឹងថា ពួកគាត់ត្រូវទ័ពវៀតណាម ចាប់ឲ្យសែងខ្មោចនៅសមរភូមិព្រៃកណ្ដៀងកាលពីព្រលឹមមិញ រួចគាត់ប្រាប់ដំណឹងពីការបានជួបនឹង បង ហម ដែលរងរបួសធ្ងន់ ដោយសារការបាញ់ប្រហាររបស់បង កន និងថាទ័ពសម្ព័ន្ធមិត្ត ខ្មែរ-វៀតណាម ត្រូវស្លាប់អស់២០០នាក់ ក្នុងនោះ អ្នកស្លាប់ភាគច្រើនគឺ ទាហានវៀតណាម ពីព្រោះ ជាអ្នកមិនស្គាល់ភូមិសាស្ត្រ ។ ដំណឹងនេះ ធ្វើឲ្យអ៊ំ សៀន របស់ខ្ញុំប្រែទឹកមុខជាខ្មោរលដូច កំពុងត្រូវអសិរពិសរត់ពាសពេញក្នុងចរន្តឈាមគាត់យ៉ាងឈឺចុកចាប់ពើតជ្រួតគណនា ។ គាត់ចាប់ទាញក្រមាឈ្នួតក្បាលរបស់គាត់ មកខ្ទប់មុខទ្រហោរយំយ៉ាងទន្ទឹះខ្សឹកខ្សួល គាត់ទន់ខ្លួនស្ទើររលំដួល ក្រុមគ្រួសារទាំងមូលក៏ឈឺចុកចាប់ងងឹតមុខឈឺង ស្ទើររកអ្វី ថ្លែងពុំបាន ។ លោកកូន ហម ហឺៗ ហឺៗ លោកកូន ហម ។។។ លោកកូន កូនខ្ញុំ វាធ្វើអ្វីខ្លះទៅ លើបងប្រុសវា? សូមប្រាប់ខ្ញុំម្ដងទៀតមក ។ អ៊ំ សៀន ត្រឡប់ភ្នែកភ្លឹកបាត់ស្មារតី ឪពុកខ្ញុំ ស្ទុះទៅទ្របងស្រីគាត់ជាប់ បើពុំនោះទេ អ៊ំ សៀន អាចនឹងដួលទាំងដំហរ ។ ពូ ឡោ ស្រឡាំងកាំងរកឈាមមួយតំណក់គ្មាន គាត់ស្ដាយក្រោយជាខ្លាំងដោយនឹកថា គាត់មិនគួរយករឿងពិតនេះមកប្រាប់អ៊ំ សៀន នៅពេលនេះសោះ ។ ដំណឹងបែបនេះ បើយើងពុំបាន ដឹងពុវិញ វាប្រសើរជាង១០០ដង មិនគួរទេ ហេតុអ្វីកម្មផលអ្វី ក៏រឿងបែបនេះ ធ្លាក់មកលើ វង្សត្រកូលអ្នកធម៌អារ្យប្រចាំភូមិរបស់យើងទៅវិញ ។ ខ្ញុំបារម្ភណាស់ ខ្លាចតែអ៊ំ សៀន របស់ខ្ញុំត្រូវមច្ចុរាជកំណាចផ្ដាច់យកសង្ខារគាត់ ដោយសារតែការឈឺចុកចាប់នេះ ។ យើងបានរីតប្របាច់ ថៃទាំអ៊ំ សៀន រហូតគាត់បានដឹងស្មារតីឡើងវិញ ។ គួរឲ្យស្ងើចសរសើរណាស់ដែលលោកឪពុកខ្ញុំ អាចរកឃើញនូវប្រយោគបញ្ឆោសមួយឃ្លា ជួយរំលែកទុក្ខសោកអ៊ំ សៀន ។ "ខំកាត់ចិត្តទៅបង បង សៀន ឯងជាស្ត្រីមានភ័ព្វវាសនាខ្ពស់ជាងគេបំផុត នៅម្តុំភូមិឃុំយើងនេះ ពីព្រោះបង មានកូនក៏ក្លៀវក្លា៤នាក់ បម្រើឲ្យនយោបាយទាំងសង្ខាង" ។ ខ្ញុំមិននឹកស្មានសោះថា ពាក្យពេចន៍មួយឃ្លាដ៏ខ្លីនេះមានន័យគ្រប់គ្រាន់សម្រាប់ដួងចិត្តអ៊ំ សៀន ធ្វើឲ្យចង្វាក់ដង្ហើមនៃការទួញយំដ៏ទន្ទឹះ ខ្សឹកខ្សួលរបស់គាត់ត្រូវបានស្រាកចុះបន្តិចម្ដងៗទៅរកភាពស្ងប់ស្ងាត់ ។ ទឹកមុខអ៊ំស្រីខ្ញុំបានប្រែមករកភាពដើម មានចរន្តឈាមជ្រាបចូលមកវិញបណ្ដើរៗហើយ ។

**អ៊ំ សៀន:** ខ្ញុំស្ដាយ លោកប្អូនអើយ ខ្ញុំមិនគួរបណ្ដោយឲ្យកូនគង់ និងនាង ម៉ាច ទៅចូលរួមជាមួយអា កន សោះ ។

នេះជាលើកទី១បំផុត ដែលខ្ញុំបានឮអ៊ំ សៀន ប្រើពាក្យគ្រោតគ្រាតបែបនេះទៅលើ លោកកូន កន របស់គាត់ ពីព្រោះកន្លងមក អ៊ំហៅតែបង កន ថា លោកកូនកនៗ មិនដាច់ពីមាត់ទេ ។

**អ៊ំ សៀន:** តើរបួសកូន ហម ខ្ញុំធ្ងន់ប៉ុណ្ណា ហើយតើលោកប្អូនឃើញថាយ៉ាងណាទៅ?

គឺត្រូវតែដើងទេ ប៉ុន្តែប៉ុន្មានគ្រាប់ខ្ញុំចាំមិនច្បាស់ទេ អន្ទិតកនទំនងជាវាបាញ់បងវា តម្រង់ជើង ជាការព្រមានទេ វាក៏មិនដាច់ចិត្តសម្លាប់បងវាដែរ ហើយកន្ទុំរុយព្រៃវែងបានចុះដឹកយកអ្នកមានបណ្ដាស័ក្តិដែលរងរបួសទៅកាន់មន្ទីរពេទ្យព្រៃវែងប្រហែលជាពីរម៉ោង ក្រោយពីគេជគុណ ហម ត្រូវរបួសនោះ ។ មុននោះ ពេទ្យយោធាប្រចាំសមរភូមិគេបានមើលថែហើយ ប៉ុន្តែបង សៀន អើយ ខ្ញុំសុំខមាលទោស មិនគួរប្រាប់បងទេ គេជគុណ ហម ត្រូវហូរ

ឈាមខ្សោះខ្លួនជាប់មួយម៉ោង ទម្រាំនឹងគ្រូពេទ្យអាចចូលទៅដល់លេណដ្ឋានគាត់ ដោយទ័ពរំដោះបាញ់សម្រុកខ្លាំងពេក ។ អន្និត កន ស្រែកបញ្ជាទ័ពរំដោះឲ្យចូលចាប់ខ្លួនគេជគុណ ហម ទាំងរស់ ។ សម្រែកនៃការសន្ទនារវាងបងប្អូនទាំងពីរនាក់នេះឮខ្ទរពេញសមរភូមិទាហានព្រៃកណ្ដៀងដែលនៅរស់និយាយរឿងនេះគ្រប់មាត់ ។ មកដល់ត្រង់នេះ អារម្មណ៍អ៊ំ សៀន ប្រែជាតានតឹងឡើងវិញមួយរំពេច គាត់ដង្ហឹតដង្ហក់ស្ទើរបាត់ដង្ហើម ដែលយើងអាចស្មានបានថា ប្រសិនបើអ៊ំនៅក្នុងហេតុការណ៍នោះវិញ ច្បាស់ជាអ៊ំយកជីវិតអ៊ំទៅពាំងជំនួសបង ហម ហើយស្រែកហៅប្រាប់មកបង កន ថា បើចរន្តឈាមម៉ែដែលកំពុងរត់ ក្នុងសារពាង្គកាយកូនមាសម្ដាយទាំងពីរ បញ្ជាឲ្យកូនបាញ់ប្រហារគ្នាឯងយ៉ាងនេះ គឺម៉ែនេះទេ ដែលស័ក្តិសមជាអ្នកត្រូវទទួលរងនូវឃាតកម្ម និងទារុណកម្មនេះ មិនមែនហម ទេ ។ ព្រលឹងមាសម្ដាយអើយ! ហេតុអ្វីក៏កូនទាំងពីរត្រូវរងនូវភ័ព្វវាសនាចង្រៃយ៉ាងនេះ តាំងពីក្មេងរហូតពេញវ័យ កូនមាសម្ដាយ ស្រឡាញ់បងប្អូនណាស់ ហម គោរព កន ណាស់ កន តែងតែធ្វើជាគ្រូបង្ហាត់បង្រៀន ហម ។ កូនទាំងពីរសុទ្ធតែជាអ្នកបានបួសរៀនបានទៅសាលាចេះដឹង ទោះបីម្ដាយមេម៉ាយគោកយ៉ាកយ៉ាងណា ម្ដាយតស៊ូគ្រប់ការលំបាកតែម្នាក់ឯង ទុកឱកាសឲ្យកូនបានទៅរៀនចេះដឹងនឹងគេ កូនគេមិនមែនមនុស្សល្ងង់ខ្លៅទេ ហេតុអ្វីក៏កូនអាចធ្វើអំពើដែលធ្វើឲ្យម្ដាយអាម៉ាសអស់ពិភពលោកយ៉ាងនេះ? មាសម្ដាយទាំងពីរ ដែលម្ដាយថែថ្នាក់ថ្នមដូចជាកែវភ្នែកទាំងគូរបស់ម៉ែ មិនឲ្យស្រមោចវារលើបាន ឥឡូវនេះ ទាំង កន ទាំង ហម កំពុងឈឺផ្សាយ៉ាងណា? កន លំបាកជាង ហម ពីព្រោះត្រូវ មុជលូនកាត់ព្រៃ កាត់ទឹក កាត់ភក់ល្បាប់ ហើយមកអូសទាញយក គង់ និង នាង ម៉ាច ចេញពីម្ដាយទៅទៀត អ៊ំយំយ៉ាងកកគាំងណែនរហូតនិយាយលែងរួច ខ្ញុំយល់បានថា ប្រយោគទាំងនេះ កំពុងចាក់ដោតក្នុងដួងវិញ្ញាណអ៊ំ ។ ពុទ្ធំ! ធម្មំ! សង្ឃំ! សូមព្រះនាងគង្ហីង ធរណី ជួយរក្សាជីវិតកូនខ្ញុំទាំង៤ ដោយអ៊ំបន្លឺប្រយោគនេះឡើង ដោយកាយវិការចាប់យក ដីមួយដុំដាក់ទូលលើព្រះកេសគាត់ អ៊ំយកក្រមាជូតវាសទឹកភ្នែកម្ដងហើយម្ដងទៀត ។

ពូ ឡោ ពូ ឡុន អន្ទះសារណាស់ចង់ប្រញាប់លាពួកយើងទៅស្វែងរកក្រុមគ្រួសារ គាត់តែដោយការចង់យល់ចង់ដឹងពីស្ថានភាពនៃសមរភូមិព្រៃកណ្ដៀងខ្លាំងពេក និងចង់ដឹងថាតើហេតុផលយ៉ាងណាបានជាគាត់ទាំងពីរនាក់បងប្អូនមិនរត់ចេញមកជាមួយប្រពន្ធកូន និងអ្នកស្រុកមុនពេលការផ្ទុះអាវុធទ្រង់ទ្រាយធំនេះកើតឡើង ពូ សេន និងពុកខ្ញុំបានទទូចសុំឲ្យពូ ឡោ ពូ ឡុន រៀបរាប់ហេតុការណ៍នោះ ម្យ៉ាងវិញទៀត យើងជឿថា ក្រុមគ្រួសារពូ ឡោ ពូ ឡុន ប្រាកដជាក្នុងរនាមនេះទាំងអស់គ្នា ហើយពួកយើងដែលបានមកដល់ដើមព្រៃរនាមនេះ ទុកដូចជាដល់គោលដៅចុងក្រោយហើយ ។ យើងរត់ចូលព្រៃរនាមនេះ មិនមានន័យថា ព្រៃអាចជួយយើងឲ្យរួចផុតពីគ្រោះថ្នាក់ដោយសង្គ្រាមទេ ប៉ុន្តែយើងចង់ជៀសចេញពីមុខទ័ពដែលតែងតែយកភូមិដ្ឋានអ្នកស្រុកជាជម្រករាល់ពេលមានការបាញ់ប្រហារគ្នាតូចៗពីមុនមក ។ ម្យ៉ាងទៀត យើងខ្លាចទ័ពវៀកយ៉ាដ្លោងតម្រង់ និងបន្តក់បណ្ដាក់ជុំវិញជើងភូមិ ដូចពីយប់មិញទៀត យើងក៏បារម្ភទៀតខ្លាចការទម្លាក់គ្រាប់បែក ដោយទាហានចក្រពត្តិនឹងផ្ដោតមកលើភូមិដ្ឋានអ្នកស្រុកជាងក្នុងព្រៃ ពីព្រោះគេតែងគិតថា តែកាលណាបាញ់ប្រហារទៅលើទ័ពសម្ព័ន្ធមិត្តហើយ ទ័ពរំដោះតែងតែរត់ចូលភូមិអ្នកស្រុក នោះជាការគិតក្រែងប៉ាន់ប្រមាណពីចិត្តសាស្ត្រទ័ពទាំងសង្វាងរបស់ប្រជាកសិករយើង ក្នុងពេលរងនូវព្រឹត្តិការណ៍បំផ្ទុះអាវុធធំលើកទី១ ។ ជាមួយនឹងសំណួរឪពុកខ្ញុំ ពូ ឡោ បានដាក់គូទអង្គុយចុះដីជាមួយយើងវិញ ជាមួយនឹងដង្ហើមធំយ៉ាងធ្ងន់ណែន ហើយរៀបរាប់ថាៈ

ក្នុងអំឡុងពេលផ្ទុះអាវុធលើដីអស់ប្រមាណ៧ម៉ោងមក សង្គ្រាមអាកាសក៏បន្តបេសកកម្មដើម្បីជួយដេញកម្ចាត់ទ័ពរំដោះ និងរំដោះយកទាហានត្រូវរបួស ជាពិសេសគេជ គុណ ហម ដែលជាមេបញ្ជាការបន្ទាយព្រៃកណ្ដៀងនេះ ដូចលោកគ្រូមើលឃើញពីភូមិស្ដៅទៅស្រាប់ (ភូមិស្ដៅទៅព្រៃកណ្ដៀងមានចម្ងាយប្រមាណជិត៧គីឡូម៉ែត្រ) ។ កងទ័ពរដ្ឋាភិបាលបានយករោងម៉ាស៊ីនស្រូវចឹក អាង ជាចំណុចប្រមូលផ្ដុំចុងក្រោយបំផុត ដូច្នេះការទម្លាក់គ្រាប់បែកត្រូវរាយព័ទ្ធទីនោះ ដើម្បីរុញច្រានទ័ពរំដោះឲ្យចាកចេញ ស័ង្កសីរាប់រយសន្លឹកនៃគំបូលរោងម៉ាស៊ីនស្រូវចឹក អាង នេះបានហើររបាត់របាយ ខ្លះទៅលើចុងឈើ ខ្លះធ្លាក់តម្រៀបគ្នាសស្វាចតាមបណ្ដោយផ្លូវជាតិ និងវាលស្រែក្រោរបង ។ គ្រាប់ធ្លាក់ជុំវិញជើងភូមិក៏មិនដឹងជាប៉ុន្មានគ្រាប់ដែរ ហើយក៏មានធ្លាក់ក្នុងភូមិ៤-

៥ គ្រាប់ដែរ ផ្ទះរាប់សិបខ្នងទៀតតាមបណ្តោយផ្លូវជាតិ ជាពិសេស ផ្ទះអមសង្ខាងម៉ាស៊ីនស្រូវចឹក អាង ត្រូវបាក់បែកធ្លាក់យ៉េកយ៉ាក ដោយកម្លាំងគ្រាប់ផ្លោងផង គ្រាប់បែកផង និងផ្ទុះធ្លាយដោយគ្រាប់កាំភ្លើងដៃវផង ពិបាកភ្នែកណាស់ លោកគ្រូអើយ ខ្ញុំស្រែករកតែពុទ្ធោទេ ។

ហ៊ឺ ហ៊ឺ តែសំណាងណាស់ដែលគុណទឹកដោះម្តាយថ្ងៃទុកជីវិតអ្នក ឡោ អ្នក ឡុន ឯងឲ្យរួចរស់បានមករកគ្រួសារយ៉ាងនេះ ។ លោកឪពុកខ្ញុំឆ្លើយតបយ៉ាងនេះ ដោយលើកដៃទាំងពីររបស់លោកដាក់លើស្មាពូ ឡោ ផង ។

ពូ ឡោ ចាប់លើកដៃទាំងពីររបស់លោកឪពុកខ្ញុំទោលលើក្បាលគាត់រួចយំយ៉ាងដង្ហក់ លោកឪពុកក៏អួលអាក់យ៉ាងតឹងណែនរួចពូ ឡោ លុតជង្គង់ចុះដីថ្វាយបង្គំ លោកឪពុកខ្ញុំបីដង ដោយពោលថាៈ គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងគុណលោកគ្រូ ក៏បានតាមជួយថែរក្សាខ្ញុំដែរ សូមអរគុណលោកគ្រូជាថ្មីម្តងទៀត ដែលបានជួយបំបួសខ្ញុំ នៅពេលដែលម្តាយខ្ញុំរកតែស្បង់ចីវរឲ្យខ្ញុំបួសមិនបានខបការគុណទាំងអស់នេះ ខ្ញុំបាទទន្ទេញជាប់មាត់ នៅពេលគ្រោះអាសន្ននេះ ។ ប្រវត្តិសាស្ត្រទាំងនេះ លោកឪពុកមិនដែលនិយាយប្រាប់ខ្ញុំទេ បើកុំតែមានហេតុការណ៍ដែលបណ្តាលឲ្យពូ ឡោ រម្លឹកខបការគុណ កាលលោកនៅបួស ជាសង្គ្រាជវត្តស្តៅនេះឡើង ខ្ញុំប្រហែលជាអាចនឹងមិនបានដឹងពត៌ិកម្រិតគុណសម្បត្តិ លោកឪពុកខ្ញុំជារៀងរហូត ។

ពេលនេះហើយ គឺមានផ្ទះគ្មានមនុស្សនៅ មានផ្លូវគ្មានមនុស្សដើរ ដូចពុទ្ធទំនាយថាមែន ។ លោកឪពុកខ្ញុំតប ដោយកាន់ដៃទាំងពីររបស់ពូ ឡោ យ៉ាងជាប់ ពូ ឡោ ពេលនោះ ទំនងជាបានទទួលអារម្មណ៍កក់ក្តៅឡើងវិញខ្លះ ។

រឿងខ្ញុំនៅក្រោយគេក៏មិនខុសពីក្រុមគ្រួសារលោកគ្រូដែរ ម្តាយខ្ញុំចាស់ជរាមានជំងឺ មហារីកក្រពះ ដាច់បាយសំរាន្តនៅកន្ទេល ២០ ថ្ងៃមកហើយ ខ្ញុំឲ្យគ្រួសារចេញមកមុន ជាមួយអ្នកភូមិខ្ញុំពីរនាក់បងប្អូននៅមើលថែម៉ែ ១ គ្រាប់បានធ្លាក់ចំកណ្តាលភូមិ គឺចំចែងលេណដ្ឋានខ្ញុំ ដែលក្រាលដោយដើមត្នោត និងដើមដូង ធ្វើឲ្យលេណដ្ឋានត្រូវបាក់ស្រុត សង្កត់ចំពីលើរាងកាយគាត់ ។ និយាយដល់ត្រង់នេះ ពូ ឡោ និង ពូ ឡុន តឹងទ្រូងស្ទើរដកចង្ការមោន់ងឹត១ ។ ពួកយើងទាំងពីរបានខំស៊ុះរត់ចេញតាមមាត់លេណដ្ឋានរួច ដាច់ដៃដាច់ជើងអស់ហើយ លោកគ្រូឃើញស្រាប់ យន្តហោះនៅតែឆាបង៉ាវៗលើភូមិមិនអាចទ្រាំតទៅទៀតបាន ពួកយើងលើកដៃសំពះសុំខមាលទោសម្តាយ ដោយសារកាលៈទេសៈមិនអាចនៅសង្គ្រោះជីវិតម្តាយបន្តទៅទៀតបាន យើងទាំងពីរនាក់បងប្អូនក្រាបលូនសំដៅទៅថ្នល់ជាតិ សំដៅចូលទៅបន្ទាយទាហានរដ្ឋាភិបាលឲ្យរួចផុតពីគ្រោះថ្នាក់ដោយគ្រាប់បែកមួយរយៈសិន ប៉ុន្តែយើងត្រូវពួកទាហានវៀតយ៉ាភ្ជង់កាំភ្លើងស្ទាបរាបសព្វរាងកាយ និងគេរខ្វាស់ទាំងអស់ ដើម្បីឆែករកខ្មាំងយើងមានអាវុធបង្កប់រួចបង្ខំឲ្យសែងខ្មោចពួកវាទៅដាក់ ម៉ាស៊ីនស្រូវចឹកអាង ។

ពូសនខ្ញុំគ្រវីក្បាលតគាត់រួចតបថាៈ នេះប្រសិនបើពុំចំពេលវាត្រូវការអ្នកជួយសែងខ្មោចទេនោះ ប្រហែលជាគេមិនទុកជីវិតអន្ទិត ឡោ និង ឡុន ឯងទេ ។

ពូ ឡោ ងក់ក្បាលយល់ស្រប រួចនិយាយបន្តមកកាន់ឪពុកខ្ញុំៈ លោកគ្រូអើយ គេចពីគ្រាប់បែកទៅត្រូវចុងកាណុង ពេលនោះការទម្លាក់គ្រាប់បែក នៅតែបន្តការបាញ់ទឹកក្រុត ក៏ចាប់ផ្តើមស្រោចជុំវិញបន្ទាយ ដើម្បីការពារប្រតិបត្តិការដឹកខ្មោច និងអ្នករងរបួសផង ។ ណាខ្ពើមឈាម ណាភ័យនឹងជីវិតខ្លួនឯង ណាតក់ស្លុតនឹងម្តាយមិនទាន់បានធូរស្រាលផង ណាគិតទៅដល់ប្រពន្ធកូន លោកគ្រូអើយ ខ្ញុំយំមិនចេញទេ ។ ខ្ញុំនឹកដល់គុណទឹកដោះថ្លៃ របស់អ្នកម្តាយខ្ញុំបណ្តើរ បន់វត្ថុស័ក្តិសិទ្ធិបណ្តើរ សុំជីវិតរស់មករកប្រពន្ធកូន ។ លោកគ្រូអើយ ខ្ញុំស្រណោះសម្តីម្តាយខ្ញុំណាស់ ជាច្រើនដង គាត់បានដេញខ្ញុំទាំងពីរនាក់បងប្អូនឲ្យចាកចោលគាត់ចុះ ពីព្រោះយូរ ឬឆាប់គាត់គង់តែស្លាប់ តែលោកគ្រូអើយ នរណាដាច់ចិត្ត ។

ភ្លៀងធ្លាក់មួយមេធំ បានលាងឈាមអ្នកស្លាប់ទាំងនោះ យើងដូចជាមានកម្លាំងបន្តិច យើងត្រូវគេតាមភ្ជង់កាំភ្លើងជាប់ឲ្យសែងខ្មោចរាប់រយនាក់ ដែលសុទ្ធសឹងតែឆេះ រោលរួញក្រញូង់នៅក្នុងរថយន្ត GMC ២ គ្រឿង ដែលទំនងត្រូវឆេះដោយគ្រាប់បេ-៤០ និង បេ-៦៩ របស់ចិន (អាវុធយុទ្ធភណ្ឌពីស្រុកចិនជាអាវុធដែលប្រើប្រាស់ដោយទ័ពខ្មែររំដោះ) ។ កងទ័ពទាំងអស់ខ្លះសែងកណ្តៀតសាកសព និងអ្នករបួសមកដាក់លើទីលានម៉ាស៊ីនស្រូវដោយអូសយកស័ង្កសីរាប់សិបសន្លឹកមកធ្វើទ្រនាប់ តេជគុណ ហាម

ត្រូវបានគេសែងដាក់ លើគ្រែឬស្សី លោកបិទភ្នែកថ្ងូរហើស រាយកាយគាត់ពើតរមួល ជើងគាត់ម្ខាងដោតទៅដោយ ឈាមចាប់តាំងពីជង្គង់ចុះទៅ ។

មេបញ្ជាការរងបន្ទាប់ពីតេជគុណ ហម វរសេនីយ៍ ហេង ម្តងក្រោកឈរ ម្តងក្រាបចុះ នៅក្បែរគល់អំពិលទឹកធំមុខរោងម៉ាស៊ីន ស្រែកបញ្ជាតាមតេអូ ទាំងញ័រតគាត់ទៅព្រៃវែង ថា "ហង្សនាគ១ សូមប្រញាប់មកដឹកដីរទឹក នៅចំណុច១៨-១៦" ដូនៗ ហើយ ដូនៗទៀត ស្រាប់តែកន្ទុំរុយ៦គ្រឿង បានចុះប្រសាចមកចតតម្រៀបគ្នានៅលើថ្នល់ជាតិមុខម៉ាស៊ីនកិនស្រូវ ទ័ពដែលនៅសល់ប្រមាណ៣០នាក់ រាប់ទាំងរីកយ៉ា ទាំងខ្ញុំ និង ឡុន ផង បានខំមមាញឹកសែងអ្នករបួស និងអូសខ្មោចឡើងលើឧទ្ធម្ភាគចក្រ ។

***វរសេនីយ៍ ហេង៖*** ឡើងយន្តហោះមក ទៅខេត្តជាមួយនឹងខ្ញុំពូទាំងពីរ ។

***ពូទាំងពីរ៖*** សូមទានទោស ខ្ញុំបាទទៅមិនបានទេ មិនដឹងជាកូនប្រពន្ធរបាត់របាយដល់ណាទេ ស្លាប់ ឬរស់យ៉ាងណាទេ សូមទានមេត្តាអធ្យាស្រ័យដល់ខ្ញុំបាទ ។ ខ្ញុំបាទត្រូវតែទៅតាមរកគ្រួសារសិន ។ ឡុន និង ខ្ញុំ លើកដៃទាំងពីប្រណម លោកវរសេនីយ៍ទោ ហេង លោកងក់ក្បាលយល់ព្រម ។ កងឧទ្ធម្ភាគចក្រហក់ឡើងត្រង់ទៅលើមេឃយ៉ាងខ្ពស់ត្រដួច ចូលទៅក្នុងលំហអាកាស រួចបោះពួយទៅទិសខាងជើង សំដៅទៅទីក្រុងព្រៃវែង ។ នៅសល់តែយន្តអង្កេតការណ៍មួយប៉ុណ្ណោះ ដែលនៅវេរ៉េៗ ឆេ្វចឆ្វាច ការពារការហោះឡើង របស់កងកន្ទុំរុយ ។

***ពូ សន និយាយកាត់៖*** កន្ទុំរុយហោះឡើងខ្ពស់ត្រង់ទៅលើយ៉ាងនេះ ទំនងជាបារម្ភខ្លាំងណាស់នឹងកាំភ្លើងធ្លោងរបស់ទ័ពរំដោះ ។

## សង្គ្រាមបុម (គ្រាប់បែក)

ក្រោយពីសភាពស្ងប់ស្ងាត់កើតឡើងមួយសន្ទុះ ម្នាក់ៗប្រញាប់ប្រញាល់ចាត់កម្លាំង ប្រុសៗចូលមកភូមិដើម្បីយកស្រូវអង្ករ ប្រហុកផ្អក តាមចំនួនដែលអាចយករួច ជាស្បៀង ត្រឡប់មកព្រៃវិញ ។ អ្នកស្រុកពេលនោះបានគិត និងសម្រេចចិត្តថា មិនចូលភូមិវិញទេ គឺ នាំគ្នាធ្វើដំណើរទៅភូមិពាមស្តីដែលនៅចម្ងាយ៨គីឡូម៉ែត្រខាងលិចសមរភូមិព្រែកណ្តៀង ។ ស្មារតីអ្នកស្រុកនៅពេលនោះ យល់ថា ការទៅឲ្យឆ្ងាយពីថ្នល់ជាតិ ជាការប្រសើរ ដោយម៉្យាងការវាយប្រហារកន្លងមក ក៏ដូចជាប៉ុន្មានថ្ងៃមកនេះ សង្គ្រាមផ្តោតទៅលើបន្ទាយទាហាន និងថ្នល់ជាតិដែលប្រើប្រាស់ដោយទាហានចក្រពត្តិ និងម៉្យាងទៀត ប៉ុន្មានថ្ងៃនេះ ភូមិពាមស្តីមានសន្តិភាពល្អ ប៉ុន្តែសំខាន់ជាងនេះ គឺអនុភាពនៃស្មារតីនិន្នាការទោរទន់ទៅ រកចលនាបដិវត្តន៍របស់រណសិរ្សរំដោះជាតិនោះ ហើយដែលធ្វើឲ្យប្រជាពលករប្រកាន់យកជម្រើសនេះ ។

សង្ឃឹមថា យប់នេះ បានសម្រាកលក់ស្កាយកកម្លាំងឡើងវិញ ពីការរត់សង្គ្រាម ប៉ុន្មានថ្ងៃមុននេះ តែផ្ទុយស្រឡះ យើងមកដល់ពាមស្តីបានតែប៉ុន្មានម៉ោងប៉ុណ្ណោះ គ្រាប់ធ្លោងរបស់ទ័ពរីកយ៉ា នៅជ្រោយជ្រែចាប់ប្រតិបត្តិការបាញ់ផ្តក់ជុំវិញភូមិពាមស្តីជាជំនួសការបាញ់ផ្តក់ទៅថ្នល់ជាតិទៅវិញ ។ តើមកពីសង្ស័យនឹងពួកយើងអ្នកភូមិផ្សេងៗនាំគ្នាចូលមកទីនេះ រង្គើព្រឹកព្រៃ ហើយកែវយឺតរបស់វាមិនអាចមើលស្គាល់ថា ជាអ្នកស្រុកឬជាទ័ព ហើយគិតតែបាញ់លេង ជាល្បែងកំសាន្តចិត្តវា ឬយ៉ាងណា? "ពុទ្ធំ ធម្មំ អើយ សូមព្រះអង្គជួយជីវិតកូនចៅផង ។ នៅទីនេះ គ្មានលេណដ្ឋានទេ អ្នកស្រុកគេសង់លេណដ្ឋាន សម្រាប់តែល្មមក្រុមគ្រួសារគេ យើងអ្នកចម្ងាយមានតែនាំគ្នាចូលប្រឡាយទឹកជាទីពឹង ហើយជាទូទៅប្រឡាយទឹកជីកនៅក្រៅភូមិ គឺជាទីដែលត្រូវរងភ័យជាងអ្នកស្រុកមូលដ្ឋាន ។ រំទាំង១ ១ មួយយប់ទល់ភ្លឺ គ្មានសម្រាកមួយប្រឹមសោះ ថែមទាំងត្រូវអ្នកស្រុកពាមស្តីចោទប្រកាន់ថា ប្រសិនបើអ្នកភូមិទាំង៣នេះមិនបានរត់ចូលមកពាមស្តីទេនោះ ភូមិពាមស្តីប្រហែលជាមិនបានទទួលរងគ្រោះភ័យបែបនេះឡើយ ។ ម៉ោងបួនភ្លឺសកម្មភាពធ្លោងផ្តក់បានស្ងប់ស្ងាត់ ពួកយើងសន្និដ្ឋានថាទ័ពរីកយ៉ាសម្ងំដេកហើយ យើងបន្ទំចិត្តប្រញាប់ ប្រញាល់សែងលោកយាយ ត្រឡប់មកភូមិដ្ឋានយើងវិញ ដោយយើងយល់បណ្តើរៗហើយថា យើងមិនអាចស្មានត្រូវទេ អំពីផែនការសង្គ្រាម ។ អ្នកភូមិទាំងបី ស្ទើរទាំងអស់វិលមកលំនៅវិញ មានតែអ្នកភូមិមួយចំនួនតូច ដែលមាននិន្នាការបដិវត្តន៍ជ្រាលជ្រៅទេ ដែលជាអ្នកបន្តស្នាក់នៅភូមិពាមស្តី ឬចុះទៅខាងអន្លង់ទ្រា ព្រែកជ្រៃ ដែលជាតំបន់រំដោះស៊ប់ ។

ដំណើរវិលត្រឡប់របស់យើងបានពាក់កណ្តាលផ្លូវ ស្រាប់

តែលោកយាយបានលាចាកលោកនៅក្នុងអគ្រីងស្នែងយ៉ាងស្ងប់ស្ងាត់ ដោយគ្មាននរណាចាប់អារម្មណ៍ឡើយ ។ ប្រហែលជាគាត់ឡើងឈាម ស្របជាមួយនឹងដំណើរដ៏រឡាក់រឡើកបានផ្តាច់សង្ខារលោកយាយទៅហើយ ។ អគ្រីងស្នែងបានត្រូវដាក់ចុះកណ្តាលព្រៃល្បាស់ លោកឪពុកខ្ញុំ ពូសន និង អ៊ុំ សៀន បានលើកដៃបិទភ្នែកលោកយាយជាមួយនឹងទំនួញឈឺចុកចាប់ លាយនឹងការសូត្រធម៌នមោធសៈ បីចប់ ដើម្បីជូនដំណើរលោកយាយ យើងសម្រេចសែងសាកសពលោកយាយតម្រង់វត្ត ។ ខ្ញុំបារម្ភណាស់ ខ្លាចតែអ្នកម្តាយខ្ញុំរើដំងឺបេះដូងម្តងទៀត ដោយសារ មរណភាពលោកយាយនៅក្នុងទ្រូងព្រៃនេះ តែមិនអីទេ ពេលនេះ ម៉ែហាក់ដូចជារឹងបឹងល្អ មិនតក់ស្លុតដូចមុនទៀតឡើយ ។ មកដល់វត្ត យើងបានជួបព្រះសង្ឃបីព្រះអង្គបានវិលចូលវត្តវិញហើយ ក្រោយពីព្រះសង្ឃឡូព្រះធម៌យ៉ាងសង្ខេប យើងសម្រេចចិត្តបញ្ចុះសពលោកយាយនៅកៀនវត្តភ្លាមៗ ដោយឥតបង្អង់ ។ យើងមិនអាចធ្វើបុណ្យបូជាសពតាមប្រពៃណីបានឡើយនៅពេលនោះ ពីព្រោះផ្សែងភ្លើងជាមូលហេតុមួយនាំឲ្យទាហាន វឹកយ៉ា ដក់គ្រាប់ផ្លោងតម្រង់ យើងត្រូវតែសុំសមាលទោសពីលោកយាយដោយសារកាលៈទេសៈ ។ លោកឪពុកមានប្រសាសន៍ថា លោកយាយផុតទុក្ខហើយ យើងទេដែលត្រូវបន្តរងទុក្ខភ័យតទៅទៀតនោះ ។

ក្នុងដំណើរចាកចេញពីការបញ្ចុះសពលោកយាយមកកាន់លំនៅដ្ឋាន យើងប្រទះ ឃើញពូ យី អ្នកភូមិបារាយណ៍ខាងកើតកំពុងបណ្តើរកូនប្រុសពិការជើងអាយុ១០ឆ្នាំ ដែលទប់ដងខ្លួនដោយឈើច្រត់កាត់ដីវាលក្រឡឹកក្រឡុកយ៉ាងលំបាក ពូ យី ត្រូវលីកូនស្រីអាយុប្រមាណ១៨ឆ្នាំ នៅលើស្មាទាំងបែកញើសគយៀរ ដង្ហើមហត់គឃូសស្ទើរមិនដល់គ្នា ។

**ឪពុកខ្ញុំ:** ចុះមកពីណាទៅណាទាំងថ្ងៃត្រង់ បង យី ហើយកូនស្រី កូនប្រុសនឹងកើតអី?

**ពូ យី:** កាលពីពខែមុន គ្រាប់ផ្លោងបានធ្លាក់ចំក្រោលក្របីខ្ញុំ ក្របីទាំង៥របស់ខ្ញុំ ស្ទើរតែរកបំណែកសាច់មិនឃើញ ក្រោលក្របីខ្ញុំ ក្លាយជារណ្តៅត្រឹមចង្កេះ កូនខ្ញុំទាំងពីរបានត្រូវរបួស លោកបងឃើញស្រាប់ កូនប្រុសកំបុតជើងម្ខាង ចំណែកឯកូនស្រីត្រូវអេក្លាបំផ្លិងខ្នងវានោះ ត្រូវគ្រូពេទ្យកាត់ចោលពីរកង់ តដ្ឋាស្និក ឥឡូវនេះវាមិនទាន់អាចដើបអង្គុយ ឬឈរបានទេ ។ ខ្ញុំបានយកកូនខ្ញុំទៅដេកពេទ្យឯភ្នំពេញ ហើយទើបនឹងត្រឡប់មកវិញ ចុះឡានត្រង់ជ្រោយជ្រៃ លីកូនដើរកាត់វាលប្រាំងមក ។

**ឪពុកខ្ញុំ:** ឈប់សម្រាកមួយស្របក់ទៅ ចូលទៅផ្ទះខ្ញុំពិសាបាយសិន ម្ចាស់ថ្ងៃអើយ ហេតុតែឪពុកត្រូវតែតស៊ូនឹងកូនយ៉ាងនឹង ។

ពូ យី និងកូនគាត់រួមដំណើរជាមួយយើង យើងជួយលីកូនស្រីពូ យី មកដល់ផ្ទះនៅពេលថ្ងៃត្រង់ក្តៅខ្លោច យើងដើរកាត់ភូមិគយគន់ទិដ្ឋភាពដ៏ស្ងាត់ជ្រងំ និងផ្ទះទាំងឡាយ ដែលដាច់ដោចដោយកម្លាំងខ្យល់ និងរំសេវនៃគ្រាប់បែក គ្រាប់ផ្លោង គួរឲ្យស្រយុតចិត្តណាស់ រុក្ខជាតិហាក់នៅទ្រឹងលែងហានដកដង្ហើមទាំងអស់ មាន់ ទានៅតែភិតភ័យរងារ ញាក់ញ័រទាំងថ្ងៃត្រង់ ពួកវានាំគ្នាក្រាបកំប្រោនក្នុងគុម្ពោធឈើតាមដើងរបង មិនព្រមរត់ មករកម្ចាស់ឡើយ ពាហណៈក៏មិនវិលចូលមកភូមិវិញដែរ ។ បក្សាបក្សីព្រៃ ក៏លែងឃើញមានមួយទាល់តែសោះ ទាំងនៅតាមបណ្តោយដងព្រៃដែលយើងធ្វើដំណើរមក ក៏ដូចជា ក្នុងភូមិគ្មានសត្វស្លាបទៀតទេ ពួកគេផ្អើលឈូរឆរតាំងពីគ្រាប់ធ្លាក់លើកដំបូង ហើយរហូតមកដល់ពេលនេះ គេមិនត្រឡប់មករកទឹកដីអសន្តិសុខនេះវិញទេ ។ ឱ! បក្សាបក្សីសត្វទាំងនោះ គេមានសេរីភាព និងឯករាជភាពជាងយើង ពួកគេអាចហោះហើរទៅរកកន្លែងដែលមានសន្តិសុខ និងសន្តិភាពសម្រាប់ពួកយើង គេទៅឆ្ងាយហើយ ប្រហែលជាទៅផុតពីតំបន់ដែលព្យុះស្ទូរគ្រាប់កាំភ្លើងនេះ ។

**ពូ យី:** ខ្ញុំមិនដែលប្រព្រឹត្តអាក្រក់ទាល់តែសោះ មួយជាតិរក្សាសីលទាន ហេតុអ្វីក៏ខ្ញុំ រងទុក្ខ រងកម្មយ៉ាងនេះ?

**ឪពុកខ្ញុំ:** កុំដាក់ទោសទៅលើកម្មផលអីអ្នក យី គឺមកពីសង្គ្រាម វាបំផ្លាញជោគវាសនាយើង ពេលនេះនិយាយពីកម្មផលលែងត្រូវហើយ ខំពិសាបាយយកកម្លាំងទៅ ។

**ពូ យី:** ថាខ្ញុំខ្លួនឯងហើយវាពិបាក អាក្មួយខ្ញុំធ្វើទាហានកំបុតជើងទាំងសងខាង ដេកនៅមន្ទីរពេទ្យសេតសង់អង(៧០១) ។ ខ្ញុំបានឆ្លៀតទៅមើលក្មួយ លោកបងអើយ ឃើញ (៧០១) ជាងចុះទៅឃើញឋាននរកទៅទៀត ម៉ាកណា ធុនណា ក៏មានដែរ ទាហានខ្លះត្រូវគ្រាប់មីនកំបុតទាំងដៃ ទាំងជើង ដល់តែខ្លួនមូល

គ្រន់ខ្លាំក៏មាន ។ ខ្លះខ្វាក់ភ្នែក ខ្លះស្រែកឃើ យ៉ូយ រើសរាំស់ពាស ពេញមន្ទីរពេទ្យ ។ អគារពេទ្យប្រឡាក់រលេះរលួយ ឆ្អាបឆ្អេះទៅដោយក្លិនឈាមខ្ទុះ លាយនឹងក្លិនថ្នាំពេទ្យ និងខ្ទុះទៅដោយសម្រែកឈឺចាប់ វេទនាភ្នែក វេទនាត្រចៀកណាស់ ។ ទាហានរបួសណែនណាន់តាន់តាប់ ហៀរហូរក្នុងមន្ទីរពេទ្យ ខ្លះដេកលើគ្រែ ខ្លះដេកនឹងឥដ្ឋផ្ទាល់ ខ្លះដេកនៅរានហាលខាងមុខ ខ្លះនៅក្រោមជណ្ដើរ ខ្លះដេកទៅដល់គៀនបន្ទន់ ហើយមន្ទីរពេទ្យស៊ីវិល ក៏មិនចាញ់ពេទ្យទាហានដែរ ។

យើងស្ដាប់ពុទាំងពិបាកចិត្ត ស្ទើរលេបបាយមិនចូល ទោះបីជាយើងកំពុងតែឃ្លានយ៉ាងណាក្ដី ។ ក្រោយពីពិសាបាយរួច ពូ យើថ្លែងអំណរគុណដល់ក្រុមគ្រួសារយើង រួចគាត់បន្តដំណើរតាមវិធីដដែលរបស់គាត់ទៅមុខទៀត ។

សេចក្ដីភិតភ័យ និងការនឿយហត់អំពល់ទុកយើងស្ទើរតែបែកប្រមាត់ យើងអាស្រ័យបាយរួច ប្រាសខ្លួនសម្រាន្តលើគ្រែរនាបក្រោមផ្ទះ ដោយក្ដីនឹករលឹកផ្ទះយ៉ាងខ្លាំង និងក្នុងសភាពធូរចិត្តបន្តិចពីព្រោះប៉ុន្មានថ្ងៃមកហើយ យើងមិនត្រឹមតែដេកផ្ទាល់នឹងព្រះធរណី យកគល់ឈើជាខ្នើយ និងម្ជប់ព្រឹកព្រៃជាដំបូលបាំងកំដៅនិងទឹកសន្សើមប៉ុណ្ណោះទេ ផ្ទុយទៅវិញ គឺពុំមានឱកាសប្រាស់ខ្លួនសម្រាកឡើយ ទោះជាត្រូវចុករោយស្ពឹកស្រពន់យ៉ាងណាក្ដី ។ ស្អែកឡើង ចាស់ៗបង្គាប់ឲ្យយើងហាលស្រូវដាន់អង្ករឲ្យបានច្រើន ។ យើងយល់ហើយថា ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ គ្រួសារណាក៏ដូចជាគ្រួសារណាដែរ គ្មានអ្នកណាគិតពីរឿងភ្ជួរស្រែធ្វើស្រូវទៀតឡើយ ប៉ុន្តែម្នាក់ៗខំធ្វើអង្ករឥតសំចៃដៃ ។ កាលពីមុនយើងធ្លាប់ដឹកស្រូវដោយរទេះ ឬឌុបដោយកង់ ម៉ូតូ យកទៅកិននៅម៉ាស៊ីនចឹក អាង ព្រែកណ្ដៀង ប៉ុន្តែតាំងពីចាប់ផ្ដើមសង្គ្រាមមកការធ្វើដំណើរដោយកង់ម៉ូតូតាមថ្នល់ជាតិក្ដី តាមផ្លូវលំក្ដី ធ្លាប់រងការបាញ់ប្រហារ និងការឆាបក្រឡឹងដោយយន្តហោះ ដូច្នេះយើងត្រូវតែប្រើត្បាល់កិនដៃ ឬដាន់ស្រូវដោយត្បាល់ត្កៀងតាមទម្លាប់បុរាណវិញ តាំងពីមុនការ ទម្លាក់កម្ទេចម៉ាស៊ីនកិនស្រូវនេះទៅទៀត ។

បានក្រេបរសអម្រិតសន្តិភាពឡើងវិញ មិនទាន់បាន៤៨ ម៉ោងស្រួលបួលផង ស្នូររថយន្ត GMC ពុទ្ធឡើងពីទិសឆ្ងាយសន្ធឹម ដែលធ្វើឲ្យយើងប៉ាន់ប្រមាណថា មានប្រតិបត្តិការ ដឹកទ័ពមកជិតៗនេះទៀតហើយ ។ ក្ដីបារម្ភពីសង្គ្រាមកម្រើកឡើងវិញ ស្ទើរធ្លាក់ថ្លើមម្ដងទៀតហើយ ។ ដូចការប៉ាន់ស្មានមែន ថ្មើរជើងពីភូមិពន្លៃដែលនៅចន្លោះភូមិបាបោង និង ស្ដៅ បាននាំដំណឹងថា ទ័ពរដ្ឋាភិបាល លន់ នល់ កំពុងចូលមកកាន់កាប់បន្ទាយបាបោង លើឡើងវិញហើយ ។ នៅពេលនោះ ស្ទើរតែគ្មានទេការធ្វើដំណើរពីភូមិមួយទៅភូមិមួយ ។ ដោយមនុស្សតែម្នាក់ ឬមួយក្រុមតូច លើកលែងតែមានការចាំបាច់ទៅមើលសុខទុក្ខសាច់ញាតិដែលឈឺរ៉ាំរ៉ៃ ឬការស្វែងរកថ្នាំសង្កូវ ពេទ្យហ្មបម្ដងម្កាលប៉ុណ្ណោះ ។

តាំងពីថ្ងៃត្រង់មក អាស្វាបកាត់ហោះឆ្វែលរ៉ែៗ ទឹៗ តាមបណ្ដោយដងទន្លេមេគង្គ ដែលចម្ងាយ៥គីឡូម៉ែត្រ ខាងលិចភូមិស្ដៅ យើង មិនដឹងជាមានហេតុការណ៍អ្វីទេ យើងថប់អារម្មណ៍ណាស់ថាសង្គ្រាមនឹងបួរទិសដៅចេញពីថ្នល់ជាតិ ទៅកាន់ដងទន្លេមេគង្គវិញម្ដង ។ គ្រាន់តែដាក់ទាហានចូលបាបោង ឯថ្នល់ជាតិ ឯនេះ ហេតុអ្វីត្រូវប្រុងប្រយ័ត្នតាមដងទន្លេ? ឬមួយទ័ពរំដោះកំពុងធ្វើដំណើរតាមរនាមទន្លេ ដើម្បីរៀបចំការវាយប្រហារបន្ទាយបាបោង? ចម្ងល់នេះ វិលវល់ចាក់ស្រេះពេញក្នុងអារម្មណ៍យើង ។

រសៀលម៉ោង៣នៃថ្ងៃទី២ ក្រោយពីការចាកចេញផុតពីភូមិពាមស្ដីវិលមកដល់លំនៅនេះ ស្រាប់តែស្នូរញ័រឌឹកៗកក្រើករំពើកញាប់ញ័រឡើងដូចគេកន្ត្រាក់ព្រះធរណី ម្នាក់ៗស្រវាវេចបង្វេចខោអាវ ចានឆ្នាំង និងអង្ករជាថ្មីទៀតហើយ ។ ពុទ្ធោអើយ! ពេលនេះហើយ យើងស្គាល់ច្បាស់ណាស់នូវការស្រេកឃ្លានសន្តិភាព និងថាតើអ្វីទៅជាគុណតម្លៃនៃសន្តិភាព ប្រធានបទតែងសេចក្ដីថា "ការងារ និងសន្តិភាពជាវត្ថុភ្លោះ" បានស្រែកខ្ទរខ្ទារ ឡើងពេញអារម្មណ៍ខ្ញុំ ធ្វើឲ្យខ្ញុំនឹកសាលារៀន នឹកវិទ្យាល័យ នឹកលោកគ្រូអ្នកគ្រូ និងមិត្តរួមថ្នាក់របស់ខ្ញុំស្ទើរបែកប្រមាត់ស្លាប់ ។ ឆ្នាំនេះ ជាឆ្នាំប្រឡងឌីប្លូម ខ្ញុំបានរៀននៅថ្នាក់ទី៣ ទំនើបជាតិ មកដល់ឆមាសទី២ទៅហើយ ។ ៣ខែទៀតការប្រឡងនឹងមកដល់ ខ្ញុំចង់បានសញ្ញាបត្រឌីប្លូមមួយសន្ធឹកនេះណាស់ វាមានន័យសម្រាប់ខ្ញុំណាស់ ការប្រឹងប្រែង១០ឆ្នាំ គត់ យ៉ាងលំបាកលំបិនរបស់ខ្ញុំ ត្រូវដុតបំផ្លាញខ្ទេចខ្ទីដោយសារសង្គ្រាមអប្រិយ៍នេះហើយ ។ ភ្លើងសង្គ្រាមអើយ! ឯងដុតបំផ្លាញក្ដីសង្ឃឹមរបស់យើងហើយ ឯងនាំយកសេចក្ដី ល្វឹងខ្លោមកគ្របសង្កត់យើង ធ្វើឲ្យយើងរស់នៅជាមនុស្សឥតបានការ

នេះជាសេចក្តីឈឺចាប់របស់ខ្ញុំក្នុងនាមជាសិស្សវិទ្យាល័យម្នាក់ មិត្តក្នុងភូមិជាមួយគ្នា ដទៃទៀតដែលកំពុងរៀននៅវិទ្យាល័យជាមួយគ្នា ក៏ប្រហែលជាមិត្តមានអារម្មណ៍មិនខុសពីខ្ញុំដែរ ។

យើងផ្ទៀងសោតតាមស្តាប់ដេញរកស្នូរញ័រឧឹកៗគគ្រឹកគគ្រាក់នោះ វាធ្វើឲ្យដែនដី ញ័ររញ្ជួយលាន់គ្រឹសៗ ស្ទើរប្រេះរហែកបែកចេញពីគ្នាជាផ្ទាំងៗ យើងញ័រញាក់អស់សារពាង្គកាយ យើងគិតថា វាប្រហែលជាកងរថក្រោះរាប់រយគ្រឿង បរតម្រៀបគ្នាយ៉ាងសាហាវ នឹងមកកិនផ្តាច់ផ្តិលជីវិតយើងឲ្យស្លាប់រង្គាលយ៉ាងគ្មានមេត្តាធម៌ឡើយ ។ ប៉ុន្តែ មួយសន្ទុះមក យើងមើលឃើញថា ជាសំណួរចេញពីលើអាកាសឯណោះទេ។ នោះនៅ យន្តហោះអេសសង់អុង (S១១១) ដ៏ធំមួយគ្រឿងបរក្នុងកម្ពស់ជាង១០ គីឡូម៉ែត្រក្នុងលំហ អាកាសលើមៗមកពីទិសភ្នំពេញមក អូរ។ នៅវាបន្ទាបក្បាលចុះហើយ ទេមិនមែនមួយទេ រាប់សិបគ្រឿងហោះជាក្បួន ១-២-៣-៤-៥-៦-៧-៩-១១ យ៉ាងមានរៀបនិងគំលាតចម្ងាយ ស្មើគ្នាយ៉ាងថេរ ។ វារេព័ទ្ធភូមិពាមស្តី ព្រែកជ្រៃ អន្លង់ទ្រាហើយ យើងចូលលេណដ្ឋាន ។ អូរ។ វាគ្រលែងស្លាបហើយ មើលនៅ វាមានគ្រាប់តែ២ទេ សម្រាប់យន្តហោះនីមួយៗ គឺស្លាប ម្ខាងផ្ទុកបានតែគ្រាប់មួយទេ គឺជាប្រភេទគ្រាប់ធ្ងន់ធំណាស់ មិនមែនធុនតូចដូចគ្រាប់របស់ ពួកអាស្លាបកាត់ និងអាមិចទេ ។

ទេយើងមិនត្រូវចូលលេណដ្ឋានទេ នៅពេលដែលវាដាំក្បាលចុះទម្លាក់គ្រាប់ យើងត្រូវក្រាបចុះ ដោយប្រត់ដៃបង្ហើបទ្រូងឲ្យផុតដែនដី បើពុំនោះទេ យើងនឹងត្រូវប្រេះទ្រូង ហូរឈាមស្លាប់ ពីព្រោះពពួកបុមអេសសង់អុងនេះ វាខ្លាំងជាងបេ-៥២ (ព-៥២) ទៅទៀត ។

ជាមួយនឹងបទពិសោធន៍នៃការទម្លាក់គ្រាប់បែកនៅព្រែកណ្តៀង យើងបានយល់ថា ប្រតិបត្តិការទម្លាក់ គឺផ្តោតទៅលើទីតាំងជាក់លាក់ មានការគូសដែនទីជាក់លាក់ មិនមែន ជាការទម្លាក់តែពីសតែពាសដូចការបាញ់ស្នាទពីមុនៗរបស់យើងនោះទេ ។ ដូច្នេះលើកនេះ យើងតាមឃ្លាំមើលប្រតិបត្តិការវាដោយពេញភ្នែកគ្រាន់បើ ។ អាតូចៗគ្រលែងខ្លួនរមួលខ្លាំងមែនទែនហើយ វាដាំចុះក្នុងចម្ងាយថេរស្របពេលគ្នាទាំងអស់ លើកលែងតែអាមេធំមួយវានៅហើររេតែម្នាក់ឯងជាមួយអាស្លាបកាត់ពិនិត្យមើលកូនចៅវា ។ ហ្វូងអាតូចៗងើបឡើងវិញជាក្បួន ១-២-៣-៥-៧-៩-១១ ដដែល រួចចូលទៅជ្រកក្រោមស្លាបអាធំ រហូតដល់មើលឃើញតែមួយដដែល ទើបវារេក្បាលហោះត្រឡប់ទៅភ្នំពេញវិញ ។ គ្រាប់រាប់សិបផ្ទុះឡើង ប៊ឹមៗប៊ឹមៗ ព្រមៗគ្នារាប់សិបគ្រាប់ក្នុងពេលតែមួយ ព្រះធរណីញ័រដូចគេចាប់អង្រួន ជាមួយនឹងផ្សែងខ្មៅខ្មួលខ្មាញ់ត្របាញ់ឡើងទៅលើអាកាស បាំងបាត់ផ្ទៃមេឃមួយចំហៀង ។ ប្រតិបត្តិការ អេសសង់អុង (S១១១) និង បេ-៥២ ជាប្រភេទបុម (គ្រាប់បែក) ចាក់ដោយក្បួនយន្តហោះជាហ្វូង បែបនេះបន្តឡើង ច្រើនថ្ងៃ ច្រើនខែ នៅតាមភូមិដ្ឋាន បណ្តោយដងទន្លេមេគង្គ ចាប់តាំងពីវាលបន្ទាយដែកខាងត្បូងភូមិពាមស្តីឡើងទៅអន្លង់ទ្រា ជ្រោយជ្រៃ ពោធិ៍រៀង ជាពិសេស វិហារសួគ៌ ព្រែកតាមាក់ជាសមរភូមិក្តៅដែលរងការបាញ់ប្រហារដោយគ្រាប់បែករយៈពេលយូរ ត្រូវទាហានចក្រពត្តិចាក់គ្រាប់បេ-៥២ រង្គើដីទាំងយប់ ទាំងថ្ងៃ ជាពិសេសក្នុងអំឡុងចុងឆ្នាំ១៩៧១ និងពាសពេញឆ្នាំ១៩៧២ ។ ចំពោះ ការទម្លាក់បេ-៥២ ស្នូរផ្ទុះរបស់វាលាន់ឮឡើង៥២គ្រាប់ ក្នុងប្រតិបត្តិការនីមួយៗ ។ អ្នកធ្វើដំណើរកាត់វាលប្រាំង តាមបណ្តោយដៃទន្លេមេគង្គ ដែលហូរកាត់ភូមិពាមស្តី អន្លង់ទ្រា ព្រែកជ្រៃ ពោធិ៍រៀង តែងបានប្រទះឃើញរណ្តៅទាំងនេះ ក្នុងសភាពជាថ្លុកជម្រៅត្រឹមក មនុស្សចាស់ មានអង្កត់ផ្ចិតប្រមាណ៥-៧ម៉ែត្រ និងមានចម្ងាយថេរប្រមាណ៥០ម៉ែត្រ ពីចន្លោះរណ្តៅមួយទៅរណ្តៅមួយទៀត ដូចរន្ធបាយខ្ញុំ ។

**(តទៅលេខក្រោយ)**

**អ៊ិច ចណ្ណា**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ *truthpdara@dccam.org* ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្តល់ព័ត៌មានដូចខាងក្រោម៖**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាស័យដ្ឋាន) ។




**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 216, 2017 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.